ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សន្និបាត

## បូកសរុបលទ្ធផលការងារ
## អប់រំ យុវជន និងកីឡា ខេត្តកំពត
## ឆ្នាំសិក្សា ២០១៦-២០១៧ និងទិសដៅ
## ឆ្នាំសិក្សា ២០១៧-២០១៨

ថ្ងៃទី២៥-២៦ ខែមករា ឆ្នាំ២០១៨

# មាតិកា

ទំព័រ

I- សេចក្តីផ្តើម.......... ១

II- វឌ្ឍនភាព.......... ១

លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា.......... ១

១- លទ្ធផលធៀបទៅនឹងទិសដៅសន្និបាតឆ្នាំ ២០១៧.......... ១២

១.១.ក- ការងារផែនការ-ស្ថិតិ .......... ១២

១.១.ខ- ការងារសហប្រតិបត្តិការ.......... ១៣

១.១.គ- ការងារសំណង់.......... ២៧

១.២- ការងារអធិការកិច្ច.......... ២៨

១.៣- ការងាររដ្ឋបាល .......... ២៩

១.៤- ការងារគណនេយ្យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ.......... ៣០

១.៥- ការងារបុគ្គលិក និងនីតិកម្ម.......... ៣០

១.៦- ការងារបណ្តុះបណ្តាល និងវិក្រឹតការ .......... ៣៣

២- លទ្ធផលតាមអនុវិស័យ.......... ៣៤

២.១- អនុវិស័យអប់រំកុមារតូច.......... ៣៤

២.២- អនុវិស័យបឋមសិក្សា.......... ៣៧

២.៣- អនុវស័យមធ្យមសិក្សា និងអប់រំបច្ចេកទេស.......... ៤១

២.៤- អនុវិស័យអប់រំក្រៅប្រព័ន្ធ.......... ៤៩

២.៥- អនុវិស័យអភិវឌ្ឍយុវជន.......... ៥៥

២.៦- អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា.......... ៥៨

III- វឌ្ឍនភាពនៃសូចនាករផលសម្រេចតាមអនុវិស័យ.......... ៦១

IV- បញ្ហាប្រឈម.......... ៦៧

១- អនុវិស័យអប់រំកុមារតូច.......... ៦៧

២- អនុវិស័យបឋមសិក្សា.......... ៦៧

៣- អនុវស័យមធ្យមសិក្សា និងអប់រំបច្ចេកទេស.......... ៦៨

៤- អនុវិស័យអប់រំក្រៅប្រព័ន្ធ.......... ៦៩

៥- អនុវិស័យអភិវឌ្ឍយុវជន.......... ៦៩

៦- អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា.......... ៧០

V- អនុសាសន៍/ទិសដៅ.......... ៧១

ក.១- ការងារផែនការ.......... ៧១

ក២- ការងារអធិការកិច្ច.......... ៧១

ក.៣- ការងាររដ្ឋបាល........................................................................................................ ៧១
ក.៤- ការងារគណនេយ្យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ.............................................................. ៧១
ក.៥- ការងារបុគ្គលិក និងនីតិកម្ម.......................................................................................... ៧២
ក.៦- ការងារបណ្តុះបណ្តាល និងវិក្រឹតការ.............................................................................. ៧២
២.១- អនុវិស័យអប់រំកុមារតូច............................................................................................. ៧៣
២.២- អនុវិស័យបឋមសិក្សា................................................................................................. ៧៣
២.៣- អនុវស័យមធ្យមសិក្សា និងអប់រំបច្ចេកទេស.................................................................. ៧៤
២.៤- អនុវិស័យអប់រំក្រៅប្រព័ន្ធ........................................................................................... ៧៤
២.៥- អនុវិស័យអភិវឌ្ឍយុវជន.............................................................................................. ៧៤
២.៦- អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា...................................................................... ៧៥
VI- សេចក្តីសន្និដ្ឋាន............................................................................................................... ៧៦

# របាយការណ៍
# សន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៦-២០១៧ និងទិសដៅការងារឆ្នាំសិក្សា២០១៧-២០១៨

## I- សេចក្តីផ្តើម

មន្ទីរអប់រំ យុវជន និង កីឡាខេត្ត បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំខេត្តឆ្នាំ ២០១៥-២០១៧ ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-១៧ នេះឡើងដើម្បីពិនិត្យមើល អំពីការសម្រេចបាននូវសមិទ្ធផលអប់រំ ការអនុវត្តយុទ្ធសាស្ត្រ កម្មវិធី អនុកម្មវិធី និងកត្តាពាក់ព័ន្ធដទៃទៀត រួមទាំងការផ្តល់ធាតុចូលក្នុងវិស័យអប់រំ ព្រមទាំងកំណត់ទិសដៅបន្តទៀត ។ ការបន្សុីក្របខណ្ឌការងារ និងពេលវេលាក៏ត្រូវឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធផងដែរ ជាពិសេសសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាប្រចាំឆ្នាំ និងទិសដៅបន្ទាប់ ។

សន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១៦-២០១៧ និងលើកទិសដៅការងារឆ្នាំសិក្សា ២០១៧-២០១៨ ជាឱកាសថ្មីមួយទៀតក្នុងការពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងពង្រឹងការទទួលខុសត្រូវរវាងគ្នាទៅវិញទៅមករបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងដៃគូអភិវឌ្ឍតាមរយៈការបង្កើតក្រុមបច្ចេកទេសសន្និបាតអប់រំ និងការបង្កើនប្រសិទ្ធភាពនៃលទ្ធផលរបស់សន្និបាត ។

## II- វឌ្ឍនភាព

### លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា

វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល ( ឧបសម្ព័ន្ធទី ១ )

| សូចនាករស្នូល | ស្ថានភាព ២០១៦-១៧ | ចំណុចដៅ ២០១៧-១៨ | ជាក់ស្តែង ២០១៧-១៨ | ស្ថានភាព |
|---|---|---|---|---|
| គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | |
| ១. ភាគរយកុមារអាយុ ៥ ឆ្នាំក្នុងការអប់រំកុមារតូច | ៥៥.៩% | ៦១.០% | ៦២.០% | ⬆ |

| | | | | |
|---|---|---|---|---|
| គ្រប់រូបភាព | | | | |
| ២. ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ ភាគរយ | ៦/៨ | ៨/៨ | ៧/៨ | ➡ |
| ៣. ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ ភាគរយ | ៧/៨ | ៨/៨ | ៨/៨ | ➡ |
| ៤. អត្រាអក្ខរកម្មជនពេញវ័យ ( អាយុ ១៥ឡើង ) | ៨៩.៨៤% | ៩៤.៧៥% | ៩៤.៧៥% | ➡ |
| គោលនយោបាយទី២ ៖ ធានាភាពស័ក្តិនៃភាពជាអ្នកដឹកនាំ គណៈកម្មការគ្រប់គ្រងនិងបែងចែកជំនួយមនុស្សធម៌ | | | | |
| ៥. ចំនួនគ្រូបង្រៀនបានចូលរួមថ្នាក់ពន្លឿន | ២៧ នាក់ | 0 | ៤៥ នាក់ | ⬆ |
| ៦. ភាគរយនៃការទូទាត់ថវិកា | ៩៩% | ១០០% | ៩៥.៣៩% | ⬇ |

វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៧ ( ឧបសម្ព័ន្ធទី២ )

| សកម្មភាពគោល | លទ្ធផល | សកម្មភាពរង | ស្ថានភាពអនុវត្ត | | |
|---|---|---|---|---|---|
| | | | ១ | ២ | ៣ |
| ១. សកម្មភាពគោលទី១ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ២. សកម្មភាពគោលទី២ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៣. សកម្មភាពគោលទី៣ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៤. សកម្មភាពគោលទី៤ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |

| | | | | | |
|---|---|---|---|---|---|
| ៥. សកម្មភាពគោលទី៥ | ៣/៣ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| ៦. សកម្មភាពគោលទី៦ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | | | |
| ៧. សកម្មភាពគោលទី៧ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៨. សកម្មភាពគោលទី៨ | ៣/៣ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| ៩. សកម្មភាពគោលទី៩ | ៤/៤ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| | | ៤. សកម្មភាពរងទី៤ | √ | | |
| ១០. សកម្មភាពគោលទី១០ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ១១. សកម្មភាពគោលទី១១ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ១២. សកម្មភាពគោលទី១២ | ៣/៣ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| ១៣. សកម្មភាពគោលទី១៣ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ១៤. សកម្មភាពគោលទី១៤ | ១/១ | ១. សកម្មភាពរងទី១ | √ | | |

| | | | | | |
|---|---|---|---|---|---|
| ១៥. សកម្មភាពគោលទី១ | ៣/៣ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| ១៦. សកម្មភាពគោលទី១៦ | ១/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | √ | |
| ១៧. សកម្មភាពគោលទី១៧ | ៤/៤ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| | | ៤. សកម្មភាពរងទី៤ | √ | | |
| ១៨. សកម្មភាពគោលទី១៨ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ១៩. សកម្មភាពគោលទី១៩ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ២០. សកម្មភាពគោលទី២០ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ២១. សកម្មភាពគោលទី២១ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ២២. សកម្មភាពគោលទី២២ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ២៣. សកម្មភាពគោលទី២៣ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ២៤. សកម្មភាពគោលទី២៤ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ២៥. សកម្មភាពគោលទី២៥ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ២៦. សកម្មភាពគោលទី២៦ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ២៧. សកម្មភាពគោលទី២៧ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ២៨. សកម្មភាពគោលទី២៨ | ២/២ | ១. សកម្មភាពរងទី១ | √ | | |

| | | | | | |
|---|---|---|---|---|---|
| | | ២. សកម្មភាពរងទី២ | √ | | |
| ២៩. សកម្មភាពគោលទី២៩ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៣០. សកម្មភាពគោលទី៣០ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | | | |
| ៣១. សកម្មភាពគោលទី៣១ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៣២. សកម្មភាពគោលទី៣២ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៣៣. សកម្មភាពគោលទី៣៣ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៣៤. សកម្មភាពគោលទី៣៤ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៣៥. សកម្មភាពគោលទី៣៥ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៣៦. សកម្មភាពគោលទី៣៦ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៣៧. សកម្មភាពគោលទី៣៧ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៣៨. សកម្មភាពគោលទី៣៨ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៣៩. សកម្មភាពគោលទី៣៩ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៤០. សកម្មភាពគោលទី៤០ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៤១. សកម្មភាពគោលទី៤១ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៤២. សកម្មភាពគោលទី៤២ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៤៣. សកម្មភាពគោលទី៤៣ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៤៤. សកម្មភាពគោលទី៤៤ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |

| | | | | | |
|---|---|---|---|---|---|
| ៤៥. សកម្មភាពគោលទី៤៥ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៤៦. សកម្មភាពគោលទី៤៦ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៤៧. សកម្មភាពគោលទី៤៧ | ៣/៣ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| ៤៨. សកម្មភាពគោលទី៤៨ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៤៩. សកម្មភាពគោលទី៤៩ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៥០. សកម្មភាពគោលទី៥០ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៥១. សកម្មភាពគោលទី៥១ | ៤/៤ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| | | ៤. សកម្មភាពរងទី៤ | √ | | |
| ៥២. សកម្មភាពគោលទី៥២ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៥៣. សកម្មភាពគោលទី៥៣ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៥៤. សកម្មភាពគោលទី៥៤ | ៤/៤ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| | | ៤. សកម្មភាពរងទី៤ | √ | | |

| | | | | | |
|---|---|---|---|---|---|
| ៥៥. សកម្មភាពគោលទី៥៥ | ៤/៤ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| | | ៣. សកម្មភាពរងទី៣ | √ | | |
| | | ៤. សកម្មភាពរងទី៤ | √ | | |
| ៥៦. សកម្មភាពគោលទី៥៦ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៥៧. សកម្មភាពគោលទី៥៧ | ២/២ | ១. សកម្មភាពរងទី១ | √ | | |
| | | ២. សកម្មភាពរងទី២ | √ | | |
| ៥៨. សកម្មភាពគោលទី៥៨ | ១/១ | ១. សកម្មភាពរងទី១ | √ | | |
| ៥៩. សកម្មភាពគោលទី៥៩ | ១/១ | ១. សកម្មភាពរងទី១ | √ | | |

វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ២០១៧ ( ឧបសម្ព័ន្ធទី៣ )

| **អនុវិស័យ/ឆ្លងអនុវិស័យ** | **សកម្មភាព** | **ស្ថានភាព** | **សេចក្ដីបញ្ជាក់** |
|---|---|---|---|
| **១. អនុវិស័យ** | | | |
| ១.១ ការអប់រំកុមារតូច | ១.កិច្ចដំណើរការអង្គភាព<br>២.ថវិកាដំណើរការសាលារៀន<br>៣.ពង្រឹងសមត្ថភាពលើគុណភាពសេវាអប់រំកុមារតូច<br>៤.ការពិនិត្យតាមដាន | ១<br>១<br>១<br><br>១ | |
| ១.២ ការអប់រំបឋមសិក្សា | ១.កិច្ចដំណើរការអង្គភាព<br>២.អាហារូបករណ៍សិស្សក្រីក្រ<br>៣.ថវិកាដំណើរការសាលារៀន<br>៤.ថិកាពង្រឹងគុណភាពបង្រៀននិងរៀន<br>៥.ថវិកាពង្រឹងការពិនិត្យតាមដានកសាងសមត្ថភាព និងការលើកទឹកចិត្ត | ១<br>១<br>១<br>១<br><br>១ | |
| ១.៣ ការអប់រំមធ្យមសិក្សា | ១.កិច្ចដំណើរការអង្គភាព | ១ | |

| | | | |
|---|---|---|---|
| | ២.អាហារូបករណ៍សិស្សក្រីក្រ<br>៣.ថវិកាដំណើរការសាលារៀន<br>អគារធនធាន<br>៤.ការពង្រឹងសមត្ថភាពគ្រប់គ្រងនិង<br>ការបង្រៀន<br>៥.ការប្រឡងសញ្ញាបត្រសិស្សមធ្យម<br>សិក្សាបឋមភូមិ<br>៦.ការពិនិត្យតាមដាន និងឡើងទៅ<br>ក្រសួង<br>៧.ថវិកាដំណើរការវិទ្យាល័យចំណេះ<br>ទូទៅ បច្ចេកទេស<br>៨.លើកកម្ពស់សមត្ថភាពផ្នែកអប់រំ<br>បច្ចេកទេស | ១<br>១<br><br>១<br><br>១<br><br>១<br><br>១<br><br>២ | |
| ១.៤ ការអប់រំក្រៅប្រព័ន្ធ | ១.កិច្ចដំណើរការអង្គភាព<br>២.ពង្រីកដំណើរការវិវត្តកម្មវិធីអក្ខរ<br>កម្ម និងកម្មវិធីបំណិនជីវិត<br>៣.អភិវឌ្ឍ និងការរីកចម្រើននៃកម្ម<br>វិធីចូលរៀនឡើងវិញ និងសមមូល<br>៤.ការពិនិត្យតាមដាន និងវាយតម្លៃ<br>កម្មវិធី | ១<br>១<br><br>១<br>១<br>១ | |
| ១.៥ ការអប់រំយុវជន | ១.កិច្ចដំណើរការអង្គភាព<br>២.បំប៉នចំណេះដឹង ការបង្ការទប់ស្កាត់<br>ការរីករាលដាលមេរោគអេដស៍<br>ជំងឺអេដស៍ និងគ្រឿងញៀន<br>៣.បំប៉នសមត្ថភាពមន្ត្រីទទួល<br>បន្ទុកយុវជន-កុមារ<br>៤.ការប្រារព្វទិវាអន្តរជាតិ<br>៥.ពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១<br><br><br>១<br><br>១<br>១ | |

| | | | |
|---|---|---|---|
| | ៦.អភិវឌ្ឍមជ្ឈមណ្ឌលយុវជន<br>៧.កសាងសមត្ថភាព និងជំនាញវិជ្ជាជីវៈ<br>៨.ពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១<br><br>១ | |
| ១.៦ ការអប់រំកីឡា | ១.ប្រកួតកីឡាមហាជន<br>២.កិច្ចដំណើរការអង្គភាព<br>៣.ជួសជុលហេដ្ឋារចនាសម្ព័ន្ធកីឡាក្នុងគ្រឹះស្ថានសិក្សា<br>៤.ការប្រកួត និងអភិវឌ្ឍសមាគមន៍កីឡាក្នុងជួរសិស្ស-និស្សិត<br>៥.ការពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១<br>១<br><br>១<br><br>១ | |
| **២. ឆ្លងអនុវិស័យ/អង្គភាពគាំទ្រ** | | | |
| ២.១ ការិយាល័យផែនការ | ១.កិច្ចដំណើរការអង្គភាព<br>២.អភិវឌ្ឍប្រព័ន្ធកសាងផែនការអប់រំ<br>៣.ពិនិត្យតាមដានថ្នាក់ខេត្ត<br>៤.ពិនិត្យតាមដានការផ្គត់ផ្គង់ និងប្រើប្រាស់សៀវភៅសិក្សាគោល<br>៥.កិច្ចដំណើរការអង្គភាព<br>៦.ពង្រឹងសមត្ថភាពដល់នាយកកម្រងសាលា<br>៧.ពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១<br>១<br>១<br><br>១<br>១<br><br>១ | |
| ២.២ ការិយាល័យគណនេយ្យ | ១.កិច្ចដំណើរការអង្គភាព<br>២.ការពិនិត្យតាមដាន | ១<br>១ | |
| ២.៣ ការិយាល័យបុគ្គលិក | ១.កិច្ចដំណើរការអង្គភាព<br>២.កម្មវិធីគាំទ្រការងារពង្រាយគ្រូ<br>៣.ឧបត្ថម្ភជីវភាពគ្រូតំបន់ជួបការលំបាកដែលអនុវត្តការងារបានល្អ | ១<br>១<br>១ | |

| | | | |
|---|---|---|---|
| | ៤.បៀវត្សមូលដ្ឋាន លាភការ និងប្រាក់បំណាច់បុគ្គលិក<br>៥.ពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១ | |
| ២.៤ ការិយាល័យអធិការកិច្ច | ១.កិច្ចដំណើរការអង្គភាព<br>២.ចុះពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១ | |
| ២.៥ ការិយាល័យរដ្ឋបាល | ១.កិច្ចដំណើរការអង្គភាព<br>២.ការគាំទ្រសេវាអប់រំ<br>៣.ពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១<br>១ | |
| ២.៦ សាលាគរុកោសល្យ និងវិក្រឹតការ | ១.កិច្ចដំណើរការអង្គភាព<br>២.ថវិកាដំណើរការសាលាគរុកោសល្យ<br>៣.ការពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១<br>១ | |
| ការិយាល័យយុវជន (សុខភាព) | ១.ការអភិវឌ្ឍកម្មវិធីលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា<br>២.ការអភិវឌ្ឍសម្ភារៈ និងឯកសារសម្រាប់សុខភាពសិក្សា<br>៣.ការពិនិត្យតាមដាន និងវាយតម្លៃ | ១<br>១<br>១ | |

វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ ១៥ ចំណុច

**កំណែទម្រង់ទី១៖** បានបង្កើនប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសិក្សាសហគមន៍ពី១៥០.០០០ រៀល ដល់ ៤០០.០០០ រៀល បានចំនួន ៩ ភូមិ ក្នុងឃុំ បានៀវ ត្រពាំងបី នារាយណ៍ មានជ័យ និងល្បើក ក្នុងស្រុកឈូក និងបានបញ្ចូលក្នុងប្រព័ន្ធធនាគាររបស់សាមីជន ។

**កំណែទម្រង់ទី៤៖** ចុះណែនាំពីរបៀបបញ្ចូលល្បែងសេរី និងមុខវិជ្ជាបុរេគណិតតាមរយៈការប្រជុំបច្ចេកទេសប្រចាំខែ ។

**កំណែទម្រង់ទី៥៖** ការងារអធិការកិច្ចចុះអធិការកិច្ចតាមកាលកំណត់រយៈពេល ២ថ្ងៃ ផ្តោតលើ :

១- ការងារគ្រប់គ្រង និងដឹកនាំ

២- ការងារបង្រៀន និងរៀន

៣- លទ្ធផលសិក្សារបស់សិស្ស

៤- ស្វ័យវាយតម្លៃសាលារៀន

**កំណែទម្រង់ទី៦៖** បានធ្វើតេស្តកុមារអាយុ៥ ឆ្នាំ ចំនួន ៣លើកស្មើនឹង ៩៦,៣៥%

**កំណែទម្រង់ទី៨៖ កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ៖** ក្រសួងអប់រំ យុវជន និងកីឡាកំពុងកែសម្រួលឡើងវិញគ្រប់កម្រិតថ្នាក់។ ចំណែកសៀវភៅសិក្សាគោល និង សៀវភៅរឿងនិទានផ្សេងៗក៏នាយកដ្ឋានអប់រំកុមារតូច គ្រោងតាមតម្រូវការជាក់ស្តែងរបស់សាលារៀននីមួយៗដើម្បីបោះពុម្ព ។

**កំណែទម្រង់ទី៩៖** បានសាងសង់អគារសិក្សាចំនួន ១៣ខ្នង ៧២បន្ទប់ ក្នុងនោះផ្នែកកុមារតូច ៤ ខ្នង ២១ បន្ទប់ បឋមសិក្សា ១ ខ្នង ២ បន្ទប់ និងជួសជុលអគារអនុវិទ្យាល័យ ហ៊ុន សែនក្រាំងអំពិល ២ខ្នង ១២បន្ទប់ ។

**១- លទ្ធផលធៀបទៅនឹងទិសដៅសន្និបាតឆ្នាំ ២០១៧**

**១.១.ក- ការងារផែនការ-ស្ថិតិ**

-រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ

-ធ្វើផែនការចំណាយថវិកាកម្មវិធី

-រៀបចំផែនការយុទ្ធសាស្ត្រថវិការយះពេលមធ្យម

-រៀបចំផែនការអភិវឌ្ឍខេត្ត និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត

-រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ

-ប្រមូល និងបូកសរុបរបាយការណ៍អប់រំ យុវជន និងកីឡា តាមដំណាក់កាល

-បូកសរុបរបាយការណ៍សន្និបាតអប់រំ យុវជន និងកីឡា

-ធ្វើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ

-បែងចែកតារាងជំរឿនស្ថិតិសាលារៀនសាធារណៈ និងឯកជន ជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ។

-បំពេញតារាង PRO

-ប្រមូល និងពិនិត្យតារាងជំរឿន ផ្ទៀងផ្ទាត់ ដាក់លេខកូដ និងបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ។

-បូកសរុប និងចងក្រងស្ថិតិ អគារ បន្ទប់ សិស្ស ថ្នាក់រៀន និងបុគ្គលិកអប់រំតាមសាលាបឋមសិក្សា និងមធ្យមសិក្សា ។

-ផលិតស្ថិតិ និងសូចនាករអប់រំ

-ផលិតអត្រាលំហូរសិស្សតាមសាលាបឋមសិក្សា និងមធ្យមសិក្សា

-ប្រមូល និងបូកសរុបសៀវភៅសិក្សាគោលចុងឆ្នាំ និងតម្រូវការសៀវភៅ

-ចុះពិនិត្យតាមដានប្រសិទ្ធភាព នៃការអនុវត្តផែនការ និងផលប៉ះពាល់តាមសាលាបឋមសិក្សា ។

-ចុះពិនិត្យតាមដានការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល

-បើកវគ្គបំប៉នដល់មន្ត្រីផែនការក្រុង ស្រុកស្តីពីរបាយការណ៍សមិទ្ធកម្ម

-សហការ និងសម្របសម្រួលការងារសំណង់

**បញ្ហាប្រឈម**

-ការងាររបស់ផែនការកាន់តែច្រើនឡើងៗសមត្ថភាពនៅមានកម្រិត

-មន្ត្រីផែនការក្រុង/ស្រុកមានចំនួនតិច សមត្ថភាពនៅមានកម្រិត

-ខ្វះកុំព្យូទ័រសម្រាប់ប្រើប្រាស់ក្នុងការិយាល័យមន្ទីរ និងក្រុង/ស្រុក

-នាយកសាលាមួយចំនួន សមត្ថភាពនៅមានកម្រិត ក្នុងការបំពេញតារាងជំរឿនស្ថិតិសាលារៀន សូចនាករមួយចំនួន ។

**១.១.ខ- ការងារសហប្រតិបត្តិការ**

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានសហការជាមួយដៃគូរអភិវឌ្ឍន៍ និង អង្គការនានាដូចជា ៖

**អង្គការបំប៉នវិជ្ជាជីវៈ ( OREDA )**

-បានសាងសង់បង្គន់អនាម័យ នៅបឋមសិក្សាអង្គល្បើកចំនួន ១បន្ទប់ និងកន្លែងលាងដៃ ១កន្លែង ។

-គាំទ្រថវិកាសម្រាប់អាហារូបត្ថម្ភដល់សាលាមត្តេយ្យសហគមន៍ ត្រពាំងបី ត្រពាំងល្បើក តាព្រុំ និងភូមិពន្លៃ ឃុំដានគោម ស្រុកអង្គរជ័យ ។

-ផ្តល់សម្ភារកីឡា និងសៀវភៅសរសេរ ជូនដល់សាលាបឋមសិក្សា អង្គល្បើកត្រពាំងថ្ម សុវណ្ណគីរីរស្មី និងអនុវិទ្យាល័យអង្គល្បើក និងសុវណ្ណគីរីរស្មី ។

-សាងសង់អាងទឹកស្អាត និងកន្លែងលាងដៃ ១ កន្លែងនៅបឋមសិក្សាត្រពាំងថ្ម

-ពិនិត្យមាត់ធ្មេញជូនកុមារនៅបឋមសិក្សាត្រពាំងថ្មចំនួន ២ លើក

-ផ្តល់សៀវភៅសិក្សា ប៊ិច ដល់សាលាបឋមសិក្សាសុវណ្ណគីរីរស្មី

- ផ្តល់សម្ភារអនាម័យមានថ្នាំដុសធ្មេញ ច្រាសដុសធ្មេញដល់មត្តេយ្យសហគមន៍ ភូមិតាព្រុំ ភូមិពន្លៃ ភូមិត្រពាំងបី និងត្រពាំល្បើក ។

- ផ្តល់សម្ភារសុខភាពអនាម័យមានដូចជាថ្នាំដុសធ្មេញ ច្រាសដុសធ្មេញជូនដល់សាលាបឋមសិក្សា អង្គទុល្ល បឋមសិក្សាអង្គស្វាយ បឋមសិក្សាអង្គល្បើក បឋមសិក្សាត្រពាំងថ្ម បឋមសិក្សាសុវណ្ណគីរីរស្មី ។

- ទិវាសិទ្ធិកុមារនៅបឋមសិក្សាអង្គទុល្ល បឋមសិក្សាអង្គស្វាយ បឋមសិក្សាត្រពាំថ្ម បឋមសិក្សាសុវណ្ណគីរីរស្មី បឋមសិក្សាអង្គពន្លៃ ។

- ទិវាលាងដៃនៅបឋមសិក្សាអង្គទុល្ល បឋមសិក្សាអង្គស្វាយ បឋមសិក្សាត្រពាំថ្ម បឋមសិក្សាសុវណ្ណគីរីរស្មី បឋមសិក្សាអង្គពន្លៃ ។

- ពង្រឹងសមត្ថភាពដល់លោកគ្រូ អ្នកគ្រូ នូវជំនាញការអប់រំរួមបញ្ចូលដល់លោកគ្រូ អ្នកគ្រូនៃសាលាបឋមសិក្សាអង្គទុល្ល បឋមសិក្សាអង្គស្វាយ បឋមសិក្សាត្រពាំថ្ម បឋមសិក្សាសុវណ្ណគីរីរស្មី បឋមសិក្សាអង្គពន្លៃ ហើយកម្មវិធីនេះសម្របសម្រួលដោយការិយាល័យអប់រំស្រុកឈូក ។

- ផ្តល់វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់ទឹកស្អាតដល់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាត្រពាំងថ្ម ។

- ទិវាបរិស្ថាននៅសាលាបឋមសិក្សាអង្គទុល្ល បឋមសិក្សាអង្គស្វាយ បឋមសិក្សាត្រពាំងថ្ម បឋមសិក្សាសុវណ្ណគីរីរស្មី បឋមសិក្សាអង្គពន្លៃ ។

**អង្គការសោមគ្គី**

- សង់អគារសិក្សាជូនសាលាបឋមសិក្សា ចង្ហួន ១ ខ្នង ៣ បន្ទប់ដែលបំពាក់សម្ភារបរិក្ខារ ដូចជា តុគ្រូ ៣ កៅអីគ្រូ ៣ តុសិស្ស ៦០ ក្តារខៀន ៣ ។ ក្រៅពីបានផ្តល់អណ្តូងទឹក ១ និងម៉ូទ័របូមទឹក ១ រៀបចំកន្លែងចាក់សំរាម បង្គន់នោមសម្រាប់កុមារា ទោងកុមារ ៨ តារាងបាល់ទាត់ ១ កន្លែងលាងដៃ ៣ និងជួសជុលបន្ទប់ទឹកខូច ២ បន្ទប់ ចំណាយថវិកា សរុប ៥៦៥៥០.៣៩ ដុល្លារ ។

- ផ្តល់ជូនប្រអប់គណនេយ្យភាពដល់សាលាបឋមសិក្សាចំនួន ១០ រួមមាន បឋមសិក្សាទទឹងថ្ងៃ បឹងទូក រលួស រស្មីខេមរៈ កោះតូច ព្រៃកអំពិល ក្តាត ចង្ហួន ព្រៃកត្នោត និងត្រពាំងរពៅ អស់ថវិកាសរុប ៧៥ ដុល្លារ ។

- បណ្តុះបណ្តាលស្តីពីយេនឌ័រដល់កុមារចំនួន ៣៧៥ នាក់ ស្រី ១៩៩ នាក់ជាសិស្សថ្នាក់ទី ៦ក្នុងសាលាបឋមសិក្សាចំនួន ១០ រួមមាន បឋមសិក្សា ទទឹងថ្ងៃ បឹងទូក រលួស រស្មីខេមរៈ កោះតូច ព្រែកអំពិល ក្តត ចង្ហួន ព្រែកត្នោត និងត្រពាំងរពៅ អស់ថវិកាសរុប ៥៦២.៥៦ ដុល្លារ ។

- គាំទ្រដល់ការរៀបចំផែនទីអភិវឌ្ឍសាលារៀនឡើងវិញសម្រាប់ឆ្នាំ ២០១៧ ចំនួន ១០ សាលា នៅឃុំបី ( បឹងទូក កោះតូច និងព្រែកត្នោត ) ស្រុកទឹកឈូ ( បឋមសិក្សា ទទឹងថ្ងៃ បឹងទូក រលួស រស្មីខេមរៈ កោះតូច ព្រែកអំពិល ក្តត ចង្ហួន ព្រែកត្នោត និងត្រពាំងរពៅ ) អស់ថវិកាសរុប ១៣០ ដុល្លារ ។

- គាំទ្រកញ្ចប់ថវិកាដើម្បីអនុវត្តសកម្មភាពមួយចំនួនក្នុងផែនការអភិវឌ្ឍសាលាដល់សាលាបឋមសិក្សាចំនួន ១០ ( សាលាបឋមសិក្សា ទទឹងថ្ងៃ បឹងទូក រលួស រស្មីខេមរៈ កោះតូច ព្រែកអំពិល ក្តត ចង្ហួន ព្រែកត្នោត និងត្រពាំងរពៅ ) នៅឃុំបី ( បឹងទូក កោះតូច និងព្រែកត្នោត ) ក្នុងស្រុកទឹកឈូ ចំណាយអស់ថវិកាសរុប ១០០០ ដុល្លារ ។

- គាំទ្រដល់ការចុះស្រង់ស្ថិតិផែនទីខ្នងផ្ទះដល់សាលាបឋមសិក្សាចំនួន ១០(សាលាបឋមសិក្សា ទទឹងថ្ងៃ បឹងទូក រលួស រស្មីខេមរៈកោះតូច ព្រែកអំពិល ក្តត ចង្ហួន ព្រែកត្នោត និងត្រពាំងរពៅ )នៅឃុំបី ( បឹងទូកកោះតូច និងព្រែកត្នោត ) ក្នុងស្រុកទឹកឈូ ចំណាយអស់ថវិកាសរុប ១៥០ ដុល្លារ ។

- គាំទ្រសកម្មភាពយុទ្ធនាការចុះឈ្មោះចូលរៀនដល់សាលាបឋមសិក្សាចំនួន ១០ ( សាលាបឋមសិក្សា ទទឹងថ្ងៃ បឹងទូក រលួស រស្មីខេមរៈកោះតូច ព្រែកអំពិល ក្តត ចង្ហួន ព្រែកត្នោត និងត្រពាំងរពៅ ) នៅឃុំបី ( បឹងទូកកោះតូច និងព្រែកត្នោត ) ក្នុងស្រុកទឹកឈូ ចំណាយអស់ថវិកាសរុប ៥០០ ដុល្លារ ។

- ឧបត្ថម្ភថវិកាសង់ទ្វារបងសាលាបឋមសិក្សាកោះតូច អាងទឹកសាលាបឋមសិក្សាទទឹងថ្ងៃ កន្លែងលាងដៃ ជួសជុលបង្គន់ ជួសជុលបង្អួច និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតដល់សាលាបឋមសិក្សាចំនួន ១០ ( សាលាបឋមសិក្សា ទទឹងថ្ងៃ បឹងទូក រលួស រស្មីខេមរៈកោះតូច ព្រែកអំពិល ក្តត ចង្ហួន ព្រែកត្នោត និងត្រពាំងរពៅ ) នៅឃុំបី ( បឹងទូក កោះតូច និងព្រែកត្នោត ) ក្នុងស្រុកទឹកឈូ ចំណាយអស់ថវិកាសរុប ១០០០ ដុល្លារ ។

- គាំទ្រដល់ការប្រជុំម៉ែៗ ដល់សាលាបឋមសិក្សាចំនួន ១០ ( សាលាបឋមសិក្សា ទទឹងថ្ងៃ បឹងទូក រលួស រស្មីខេមរៈកោះតូច ព្រែកអំពិល ក្តាត ចង្ហួន ព្រែកត្នោត និងត្រពាំងរពៅ ) នៅឃុំបី ( បឹងទូកកោះតូច និងព្រែកត្នោត ) ក្នុងស្រុកទឹកឈូចំណាយអស់ថវិកាសរុប ៥៤០ ដុល្លារ ។

**អង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា (CWDCC)**

- សាងសង់អគារ ១ ខ្នង ៥ បន្ទប់ បន្ទប់ទឹក ១ ខ្នង ៤ បន្ទប់ និង បំពាក់សម្ភារតុសិស្ស៨០ តុគ្រូ ៥ កៅអីគ្រូ៥ និង ក្តារខៀនបង្រៀនចំនួន ៥ ដែលចំណាយថវិកាសរុប ៦១.៩០០ ដុល្លារ ដែលមានទីតាំងក្នុងភូមិ ទួលដូនី្ត ឃុំត្រពាំងភ្លាំង ស្រុកឈូក ។

- គាំទ្រការប្រជុំជាត្រីមាសសម្រាប់គណៈកម្មការទ្រទ្រង់សាលាចំនួន ៧ រួមមាន៖ បឋមសិក្សា អណ្តែងសាង ជ័យសេនា ត្រពាំងរុន វត្តទឹកថ្លា កោះស្លា ទួលដូនី្ត ស្រែព្រីង និងបឋមសិក្សា ត្រពាំងស្ដៅ ។

- គាំទ្រកញ្ចប់ថវិកាសម្រាប់ការអភិវឌ្ឍសាលារៀនចំនួន ៦ សាលា ក្នុងមួយសាលាថវិកាចំនួន ១០០ ដុល្លារ រួមមាន៖ សាលាអណ្តែងសាង ជ័យសេនា ត្រពាំងរុន កោះស្លា ស្រែព្រីង និងបឋមត្រពាំងស្ដៅ ។

- សាងសង់ក្លឹបកុមារតាមភូមិបានចំនួន ៣ កន្លែង ស្ថិតក្នុងភូមិគំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ និងភូមិបុស្សញិញ ឃុំកូនសត្វ ១ កន្លែង ព្រមទាំងក្នុងភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ១ កន្លែងទៀត ដែលប្រើទឹកប្រាក់អស់ចំនួន ២.១០០ ដុល្លារ ។

- គាំទ្រការប្រជុំក្លឹបកុមារចំនួន ១២ កន្លែងផ្សេងទៀតដែលមានទីតាំងនៅតាមផ្ទះគ្រូបង្គោល ដែលការប្រជុំនោះយើងបានអប់រំអំពីសិទ្ធិកុមារ សិទ្ធិមនុស្ស អំពីអនាម័យ មាត់ធ្មេញ ការប្រឡងប្រណាំងគូគំនូរ ដែលមានកុមារចូលរួមសរុប១,៦៥៨នាក់ ស្រី ៩៥១នាក់

- ធ្វើយុទ្ធនាការបញ្ជ្រាបការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ តាមសាលារៀនបឋមសិក្សាចំនួន ៧ រួមមាន ៖ សាលបឋមសិក្សា ហ៊ុន សែន វត្តកំពត ហ៊ុន សែន ១ មករា បឹងតាព្រាម អូតូច ពិជ័យឧត្តុង្គ មហាសាមគ្គី និងសាលាសុវណ្ណសាគរ ។

- ជួយរៀបចំចងក្រង សៀវភៅផែនការឆ្លើយតបគ្រោះអាសន្នតាមសាលារៀនទាំង ៧ ខាងលើ ។

**អង្គការសាលាភាសាបរទេសជុំគៀល**

- បានបើកមណ្ឌលសិក្សាសម្រាប់ផ្តល់ការអប់រំដោយឥតគិតថ្លៃដល់សិស្សានុសិស្ស និងសហគមន៍ មណ្ឌលសិក្សាមានបុគ្គលិកចំនួន ១៦ នាក់ និងអ្នកស្ម័គ្រ ។ មណ្ឌលមានសិស្សចំនួន ១០០ នាក់ ស្រី ៦៥ នាក់ ក្នុងនោះសិស្សមកពីគ្រួសារដែលងាយរងគ្រោះចំនួន ៦០ នាក់ ស្រី ៤៨ នាក់ ។ ក្នុងនោះអង្គការបានផ្តល់អាហារូបករណ៍សិស្សដែលជួបការលំបាក ចំនួន ៧០ នាក់ ផ្តល់ជាសំលៀកបំពាក់ ស្បែកជើង កាតាប សៀវភៅ ប៊ិច និងសម្ភារសិក្សា ក្នុងមណ្ឌលមាន បង្រៀនភាសាអង់គ្លេស គណិតវិទ្យា ភាសាខ្មែរ បណ្ណាល័យ និងការអាន អនាម័យ និងសុខភាព កីឡា និងសិល្បៈ ។

- បើកថ្នាក់កុំព្យូទ័រ សម្រាប់សិស្សថ្នាក់ទី៧ ទី៨ និងទី៩ ដល់សិស្សអនុវិទ្យាល័យជុំគ្រៀលចំនួន ២២៣ នាក់ ។

- បានជួយបំប៉នចំណេះដឹងផ្នែកកុំព្យូទ័រដល់គ្រូអនុវិទ្យាល័យ និងបឋមសិក្សាហ៊ុនសែនជុំគ្រៀល ។

- បានបើកថ្នាក់ភាសាអង់គ្លេសដល់សហគមន៍ចំនួន ១៨ ថ្នាក់ដែលមានសិស្សសរុប ៥៥០ នាក់ និងគ្រូចំនួន ៨ នាក់ ព្រមទាំងអ្នកស្ម័គ្រចិត្តបរទេសជនជាតិដើម ។ ក្នុងនោះអង្គការបានផ្តល់អាហារូបករណ៍ដល់សិស្សជួបការលំបាកចំនួន៤០ នាក់ ( សំលៀកបំពាក់ ស្បែកជើង កាតាប សៀវភៅ ប៊ិច និងសម្ភារសិក្សា ) និងផ្តល់អាហារូបករណ៍ដល់សិស្ស ៣៨០ នាក់ ផ្សេងទៀតឱ្យរៀនភាសាបរទេសដោយឥតគិតថ្លៃ ។

- បានបង្រៀនពីការលាងដៃ ការសម្អាតមាត់ធ្មេញ ព្រមទាំងវិធីការពារជំងឺផ្សេងៗ ដល់សិស្សចំនួន ១៥០ នាក់ ព្រមទាំងចែកថ្នាំ និងច្រាសដុសធ្មេញរៀងរាល់ បីខែម្តង ។ អង្គការបានគាំទ្រកម្មវិធីសុខភាពសិក្សានៅសាលាបឋមសិក្សា និងអនុវិទ្យាល័យហ៊ុនសែនជុំគ្រៀល និងសាលាអង្គប្រិយ៍ដោយផ្តល់សម្ភារអនាម័យ និងបរិស្ថាន ( សាប៊ូ ថ្លៃទឹក ធុងសម្រាម សួនបន្លែ ) កសាងកន្លែងលាងដៃដើម្បីឱ្យសិស្សមានភាពងាយស្រួល ។

- បើកបណ្ណាល័យសម្រាប់សហគមន៍អាន និងខ្ចីសៀវភៅ ក្នុងមួយថ្ងៃសិស្សចូលអានពី ១០០ នាក់ឡើងទៅដែលសិស្សមកពីអនុវិទ្យាល័យ និងបឋមសិក្សាហ៊ុន សែន ជុំគ្រៀល ។ ផ្តល់សៀវភៅអង់គ្លេសចំនួន ២៣៤ ក្បាល សៀវភៅខ្មែរចំនួន ៦៥៥ ក្បាល វចនានុក្រមខ្មែរចំនួន ២០ និងវចនានុក្រមភាសាអង់គ្លេសចំនួន៤២ ក្បាលដល់បណ្ណាល័យចំនួន ៥ក្នុងស្រុកទឹកឈូ ។ ឧបត្ថម្ភតុសម្រាប់សិស្សអង្គុយអានសៀវភៅចំនួន ៤ និងទូដាក់

សៀវភៅចំនួន ៧ ដល់សាលាបឋមសិក្សាបុះត្របែក ។ បានជួយកែលម្អបណ្ណាល័យ ដោយក្រាលការ៉ូនៅបឋមសិក្សាបុះត្របែក និងបឋមសិក្សាហ៊ុន សែន ជុំគ្រៀល និងផ្តល់ប្រាក់បៀវត្សបន្ថែមដល់បណ្ណារក្ស និងគាំទ្រសម្ភារបណ្ណាល័យ ។

- ផ្តល់នូវប្រាក់សម្រាប់បង់ថ្លៃសាលាដល់សិស្សដែលរៀនចប់មធ្យមសិក្សាទុតិយ. ភូមិដែលគ្មានលទ្ធភាពក្នុងការបង់ថ្លៃសាលាខ្លួនឯង បានជួយសិស្សចំនួន៣ នាក់ឱ្យបន្តទៅសិក្សានៅសាកលវិទ្យាល័យ ។

- គាំទ្រសកម្មភាពកីឡានៅអនុវិទ្យាល័យហ៊ុន សែនជុំគ្រៀល នៅសម្ភារកីឡា និងប្រាក់ឧបត្ថម្ភដល់គ្រូកីឡាចំនួន ២០ ម៉ឺនរៀលក្នុងមួយខែ។ សាងសង់ទីលានកីឡាសម្រាប់សិស្សអនុវិទ្យាល័យមកហាត់កីឡា និងការប្រកួតផ្សេង ។

- គាំទ្រឱ្យមានគណៈកម្មការទ្រទ្រង់សាលាដើម្បីជួយអភិវឌ្ឍន៍ និងមើលការខុសត្រូវនៅសាលាព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការប្រជុំប្រចាំខែ និងជួយគាំទ្រថវិកាក្នុងការធ្វើយុទ្ធនាការប្រមូលកុមារចូលរៀនក្នុងស្រុកទឹកឈូ ។

- គាំទ្រដល់សិស្សានុសិស្សតំបន់ស្រែអំបិល ( បឹងរូង )ចំនួន ៣៧ នាក់ផ្តល់សំលៀកបំពាក់ សម្ភារសិក្សា និងដឹកសិស្សចំនួន ២៤ នាក់ ដោយរថយន្តមករៀននៅសាលាបឋមសិក្សា ហ៊ុន សែនជុំគ្រៀល និង ពិសារបាយថ្ងៃត្រង់នៅសាលា ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រក្នុងគោលបំណងដើម្បីឱ្យពួកគេរៀននៅសាលារដ្ឋឱ្យបានទៀងទាត់ និងមានសុខភាពល្អ ។ បានបើកថ្នាក់បំប៉នសិស្ស ព្រមទាំងសាងសង់កន្លែងក្មេងលេង និង ទីលានកីឡាសម្រាប់ក្មេងលេងនៅតំបន់ស្រែអំបិល ។

**អង្គការអេពិកអាត**

- មានសិស្សពិការសតិបញ្ញា និងរាងកាយចំនួន ១៣៣ នាក់ ស្រី ៦៥ នាក់ ទទួលបានការអប់រំ ។

**អង្គការ CCT**

- លោកគ្រូ អ្នកគ្រូនៅក្នុងសាលាគោលដៅបានទទួលការបណ្តុះបណ្តាលផ្នែកវិធីសាស្ត្រ និងបច្ចេកទេសបង្រៀនជារៀងរាល់ខែទៅតាមផែនការដែលបានគ្រោងទុក ។មានបឋមសិក្សា ហ៊ុន សែន នារាយណ៍ ក្រាំងស្នាយ តាទែន បាក់នឹម និងបឋមសិក្សាអង្គជុំ ។

- គាំទ្រដល់ការបណ្តុះបណ្តាល និងប្រជុំបច្ចេកទេសប្រចាំខែដល់អនុវិទ្យាល័យ

ចំនួន ២( អនុវិទ្យាល័យហ៊ុន សែន នារាយណ៍ ស្រុកឈូក អនុវិទ្យាល័យអង្គជុំ ស្រុកជុំគិរី )

- គាំទ្រថ្នាក់បង្រៀនភាសាអង់គ្លេសសម្រាប់បឋមសក្សា និង អនុវិទ្យាល័យដោយបង្រៀនបន្ថែមលើកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ។ បង្រៀនភាសាអង់គ្លេសត្រូវបានអនុវត្ត ២ម៉ោងជារៀងរាល់ថ្ងៃ ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសៅ ក្នុងមួយសប្តាហ៍ ១២ ម៉ោង ។

- ផ្តល់សម្ភារមួយចំនួនដល់សាលាគោលដៅមានក្រដាសរ៉ាមស ក្រដាសរ៉ាមពណ៌សឺមី កន្ត្រៃ កាវ ក្រូណូ ម្ទុលដោតក្តារ ប្រដាប់កិប ហ្វឺតសរសេរ ស្កុត ក្រដាសកាតុង

- ផ្តល់សំលៀកបំពាក់ដល់សិស្សជួបការលំបាកក្នុងមួយឆ្នាំមួយកំប្លេរនៅសាលាគោលដៅ ។

- ផ្តល់ឯកសណ្ឋានរួមមួយសម្រាប់លោកគ្រូ អ្នកគ្រូ ក្រៅពីនេះលោកគ្រូ អ្នកគ្រូបានបានទទួលសំពៀតសម្រាប់ដាក់សម្ភារមកបង្រៀនម្នាក់មួយទៀតផង ។

- ផ្តល់សម្ភារសិក្សាដល់សិស្សានុសិស្សគ្រប់រូបនៅកម្រិត មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសក្សាគ្រប់កម្រិតថ្នាក់ទទួលបាន ប៊ិចខៀវ ប៊ិចក្រហម ខ្មៅដៃ ប្រដាប់ខ្វងបន្ទាត់ ក្តារឆ្នួន សៀវភៅសរសេរ ដីស ។ ល ។

- ជួយគាំទ្រផ្នែកសម្ភារ សៀវភៅសម្រាប់សកម្មភាពបណ្ណាល័យនៅគ្រប់សាលាគោលដៅ ។

**អង្គការពុទ្ធិក:បណ្ណាល័យកម្ពុជា**

- សាងសង់អគារសិក្សា ១ ខ្នង ២ បន្ទប់ នៅបឋមសិក្សាបឹងទូក ស្រុកទឹកឈូ អស់ទឹកប្រាក់ ៨៨,០០០,០០០ រៀល ។

- គាំទ្រមត្តេយ្យសិក្សាសហគមន៍ ២ ឃុំ ត្រពាំងព្រីង និងឃុំកណ្តោល ស្រុកទឹកឈូ អស់ទឹកប្រាក់ ៨,៦០០,០០០ រៀល ។

- គាំទ្រការបង្រៀនថ្នាក់បំប៉នសម្រាប់បឋមសិក្សា ដែលមានកុមារចូលរៀនបំប៉ន ១៨៥ នាក់ អស់ទឹកប្រាក់ ៩៦,២៣០,០០០ រៀល ។

- គាំទ្រការលើកកម្ពស់សុខភាពសិក្សាតាមសាលារៀន ដែលមានកុមារចូលរួមចំនួន ៦,០០០ នាក់ អស់ទឹកប្រាក់ ៩០៦,០៩០,០០០ រៀល ។

- គាំទ្រសកម្មភាពបណ្ណាល័យ ១ និងបណ្ណាល័យចល័ត ២ ដែលមានកុមារអាន និង

ខ្វីសៀវភៅ ៩០,៩០០ នាក់ នៅស្រុក ទឹកឈូ និង ស្រុក កំពង់ត្រាច អស់ទឹកប្រាក់ ៩៩,៦៨០,០០០ រៀល ។

- ឧបត្ថម្ភការបង្រៀនភាសាអង់គ្លេស និងបង្រៀនកុំព្យូទ័រ នៅស្រុក ទឹកឈូ និង ស្រុក កំពង់ត្រាច អស់ទឹកប្រាក់ ៣៨០,៨៨០,០០០ រៀល ។

**អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ ( COCD )**

- បានបណ្តុះបណ្តាលឪពុកម្តាយជំនាញគំរូដើម្បីអប់រំកូនរបស់គាត់ឱ្យក្លាយទៅជាក្មេងល្អ សម្រេចបានចំនួន ១៣ ដង ក្នុង១៣ ភូមិគោលដៅ ដែលមានអ្នកចូលរួមចំនួន ៣៩៧ នាក់ ក្នុងនោះស្រី ២៩៧ នាក់ ។

- បានរៀបចំកិច្ចប្រជុំជាមួយកុមារកំព្រា កុមារងាយរងគ្រោះ និងអាណាព្យាបាលសិស្សស្តីពីការកំណត់គោលដៅកុមារ និងចែកជាសំលៀកបំពាក់សិក្សាដូចជា ខោ អាវសំពត់ស សម្ភារសិក្សា និងឧបត្ថម្ភថវិកាចំនួន ៣ ដុល្លារដល់សិស្សប្រចាំខែ ។ កុមារសរុប ៧៧៧ នាក់ ស្រី ២៥០ នាក់ ។

- គាំទ្រដល់លោកគ្រូ អ្នកគ្រូ ចុះតាមដានការសិក្សារបស់សិស្សប្រចាំខែ បានគាំទ្រថវិកា ៥ ដុល្លារ ដល់លោកគ្រូ អ្នកគ្រូ និង ៨ ដុល្លារ ដល់ គកនកដើម្បីចុះតាមដានការសិក្សារបស់សិស្សប្រចាំខែក្នុង ៦ ឃុំគោលដៅ និង២០ សាលាគោលដៅក្នុងស្រុកឈូក ។

- គាំទ្រដល់មត្តេយ្យសហគមន៍ក្នុងស្រុកឈូក និងស្រុកជុំគីរី

- បណ្តុះបណ្តាលសមត្ថភាពដល់គ្រូមត្តេយ្យសហគមន៍

- ជួសជុល និងថែទាំអគារសាលាមត្តេយ្យសហគមន៍

- ផ្តល់សំលៀកបំពាក់ឯកសណ្ឋាន សម្ភារសិក្សា និងប្រដាប់ក្មេងលេងដល់សិស្សមត្តេយ្យសហគមន៍ដែលមានសិស្សចំនួន ៥៨២ នាក់ ស្រី ២៨៧ នាក់ មត្តេយ្យចំនួន ១៧ នៅឃុំគោលដៅ ក្នុងស្រុកឈូក និងស្រុកជុំគីរី ។ សម្ភារទាំងនេះមាន ប៊ិច គូល័រផាត់ក្រដាសពណ៌ កាបូប ខ្មៅដៃ និងប្រដាប់ក្មេងលេង ។

- ឧបត្ថម្ភអាហារសម្រន់សិស្សមត្តេយ្យសហគមន៍ចំនួន ៥៥២ នាក់ ស្រី ២៨៧ នាក់ រៀងរាល់ខែសិស្សម្នាក់ទទួលបាន ៥០០ រៀល ។

- សហការជាមួយមណ្ឌលសុខភាពគោលដៅនឹងបានគាំទ្រ ១២ ដុល្លារដល់បុគ្គលិកមណ្ឌលដើម្បីចុះពិនិត្យសុខភាពកុមារតាមសាលាមត្តេយ្យសហគមន៍គោលដៅចំនួន២ដង

ក្នុងមួយឆ្នាំ ។

- ឧបត្ថម្ភប្រចាំខែដល់គ្រូមត្តេយ្យសហគមន៍ ស្រុកឈូក និងស្រុកជុំគីរី

- បណ្តុះបណ្តាលដល់គណៈកម្មការអនាម័យសិក្សាស្តីពីកម្មវិធីទឹកស្អាត និងអនា. ម័យតាមសាលា ។

- ផ្សព្វផ្សាយកម្មវិធីទឹកស្អាត និងអនាម័យតាមសាលាគោលដៅ

- សាងសង់បង្គន់អាម័យភ្លោះនៅតាមសាលាគោលដៅ ៨ សាលា ស្ថិតក្នុងស្រុកឈូក និងស្រុកជុំគីរី ។

- គាំទ្រមន្ត្រី មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាចុះអនាម័យតាមសាលាគោលដៅ ថវិកា ៣៩ ដុល្លារដល់មន្ទីរអប់រំ និង ១៨ ដុល្លារ មន្ត្រីការិយាល័យអប់រំ ។

**បញ្ហាប្រឈម**

**អង្គការបំប៉នវិជ្ជាជីវៈ ( OREDA )**

- គ្រូនៅបឋមសិក្សាត្រពាំងថ្មមិនសូវមានការសហការល្អ

- សាលាគោលដៅភាគច្រើនមិនមានបន្ទប់បណ្ណាល័យល្អ

- បរិវេណសាលាបឋមសិក្សាអង្គល្បើកផ្នែកខាងលិចសាលាគ្មានរបង និងប្រជាពលរដ្ឋបានរំលោភយកទីធ្លាសាលា ។

**អង្គការសាមគ្គី**

- នាយកសាលា និងគ្រូនៅមានផ្នត់គំនិតថារាល់សម្ភារ ឬការប្រជុំផ្សេងៗជាកម្មវិធី ឬ សម្ភារជារបស់អង្គការ មិនមែនជារបស់រួម ឬរបស់សាលា ។

**អង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា (CWDCC)**

- មានគណៈកម្មការទ្រទ្រង់សាលាមួយចំនួនមិនទាន់យល់ពីតួនាទីរបស់ខ្លួន

- សាលារៀនដែលបានសាងសង់រួច នៅភូមិទួលដូនី ឃុំត្រពាំងភ្លាំង មិនទាន់បានដាក់បញ្ចូលឈ្មោះក្នុងក្រសួងនៅឡើយ ។

- មានសាលារៀនមួយចំនួនតូច ក្នុងឃុំ ត្រពាំងភ្លាំង នាយកមិនសូវបានចុះពិនិត្យការបង្រៀនរបស់គ្រូ ។

**អង្គការសាលាភាសាបរទេសជុំគ្រៀល**

- សិស្សអាហារូបករណ៍អវត្តមានច្រើន និងបោះបង់ការសិក្សាជាបន្តបន្ទាប់

- អាណាព្យាបាល និងសហគមន៍មិនទាន់បានចូលរួម ជំរុញ និងលើកទឹកចិត្តកូនៗ

ឱ្យមករៀនឱ្យបានទៀងទាត់នៅឡើយ ។

- សហគមន៍មិនទាន់ជ្រាបច្បាស់ពីសារៈសំខាន់នៃការអប់រំ

**អង្គការអេពិកអាត**

- មិនមានថវិកាដើម្បីបន្តគម្រោង

- គ្រួសាររបស់អ្នកពិការមួយចំនួនមិនសហការ

**អង្គការ CCT**

- អនវិទ្យាល័យអង្គជុំខ្វះបន្ទប់រៀន ២ បន្ទប់ ដោយសិស្សកើនឡើងនៅកម្រិតថ្នាក់ទី ៧ និងទី ៩ ។

- សាលាបឋមសិក្សាតាទែនខ្វះគ្រូ ដោយអនុវត្តថ្នាក់គួបទី១ជាមួយទី២ និងថ្នាក់ទី៣ ជាមួយថ្នាក់ទី៤ ។

- គ្រូភាសាអង់គ្លេសតាមសាលាគោលដៅមួយចំនួនមិនទាន់មានសមត្ថភាព និងបទពិសោធន៍សម្រាប់អនុវត្តកម្មវិធីបង្រៀនភាសាអង់គ្លេស ។

- បណ្ណាល័យតាមសាលាមួយចំនួនមិនទាន់ដំណើរការល្អ ដោយសារបណ្ណារក្សមានការផ្លាស់ប្តូរ ។

- ដំណើរការថ្នាក់ជួយសិស្សរៀនយឺតមិនទាន់បានលទ្ធល្អដោយសិស្សមានបញ្ហាក្នុងការមករៀន២ ពេល និងពុំមានការយល់ដឹង និងជំរុញពីអាណាព្យាបាលសិស្ស ។

**អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ ( COCD )**

- នាយកសាលាបឋមសិក្សាឈើទាលជ្រុំ ឃុំត្រមែង មិនសូវសហការជាមួយអង្គការក្នុងការអនុវត្តគម្រោង ។

**ការងារគណៈកម្មការសុខភាពសិក្សា**

**ការងារត្រួតពិនិត្យតាមដាន ( PB- ២០១៧ )**

-បានចុះពិនិត្យតាមដានការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពសិក្សាចំនួន ១១ លើក នៅ តាមបណា្តសាលាបឋមសិក្សា ចំនួន ៣៤ សាលា ។

**ការងារសិក្ខាសាលា និងវគ្គបំប៉ន( PB- ២០១៧ )**

-បានបើកវគ្គបំប៉នមន្ត្រីសុខភាពសិក្សាថ្នាក់ក្រោមជាតិ ស្តីពីសុខភាព អនាម័យ អាហារូបត្ថម្ភ ការប្រើប្រាស់សម្ភារៈ និងវិធីសាស្ត្រសង្គ្រោះបឋម បាន២ វគ្គ នៅស្រុក ដង.

ទង់ និង ស្រុកជុំគីរី មានសមាជិកចូលរួមសរុប ៦២ នាក់ ។

- ការងារសាងសង់បង្គន់អនាម័យ ( PB ២០១៧ ) បានសាងសង់បង្គន់អនាម័យ ចំនួន ៨ បង្គន់ នៅក្រុងកំពត ១ ស្រុកឈូក ៣ ជុំគីរី ១ អង្គរជ័យ ២ និងស្រុកកំពង់ត្រាច ១ ។

- ផ្តល់សម្ភារដាក់ក្នុងប្រអប់សង្គ្រោះបឋមដល់សាលាចំនួន ២០ សាលា

**កិច្ចសហការជាមួយនាយកដ្ឋានសុខភាពសិក្សា អង្គការជាតិ-អន្តរជាតិ**

**១-គម្រោងគាំទ្រវិស័យអប់រំទី២ ( SESSP )**

-បានចុះពិនិត្យសុខភាព និងកាយសម្បទាសិស្ស ថ្នាក់ ទី១ មាន ២ជំហាន បាន ៣០៨សាលាបឋម សិក្សានៅក្នុងក្រុង/ស្រុកគោលដៅចំនួន ៨ ទូទាំងខេត្តកំពត សរុប ១៩,៥៧៨នាក់ ស្រី ៦,៧៥៧ នាក់ ដោយប្រើប្រាស់ថវិការកម្មវិធីសុខភាពសិក្សានៃគម្រោងគាំទ្រវិស័យ អប់រំទី២ (SESSP ) ឆ្នាំ២០១៧ ។

- សហការជាមួយសិក្ខាកាមជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាលដាំដើមឈើចំនួន ២០០ ដើមនៅសាលាបឋមសិក្សាភ្នំខ្យង ។

-បានបញ្ជូនមន្ត្រីការងារសុខភាពសិក្សាថ្នាក់ខេត្ត ក្រុង ស្រុក ចំនួន ១០ នាក់ ស្រី ០១ នាក់ ទៅ ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពិនិត្យឡើងវិញនៃការអនុវត្តកម្មវិធី សុខភាពសិក្សា នៅរាជធានី ភ្នំពេញ ។

**កិច្ចសហការជាមួយ អង្គការ Water Aid**

-បានបញ្ជូនមន្ត្រី៥ រូប ទៅចូលរួមក្នុងកិច្ចប្រជុំឆ្លុះបញ្ចាំងកម្មវិធីលើកកម្ពស់អនាម័យជនបទនៅ កម្ពុជា ដំណាក់កាលទី២ ) ខេត្តកែប ។

**កិច្ចសហការជាមួយ អង្គការ GIZ**

-បានចូលរួមដំណើរទស្សនៈកិច្ចសិក្សា ៧ លើក ស្តីពីការអនុវត្តគម្រោងអនាម័យគំរូតាមសាលារៀន នៅសាលាបឋមសិក្សាក្នុងស្រុកគោលដៅទាំង ៣ គឺៈ ស្រុកអង្គរជ័យ

ក្រុងកំពត ស្រុកបន្ទាយមាស ដោយមានការចូលរួមដំណើរទស្សនៈកិច្ចសិក្សានេះរួមមាន ព្រះអនុគុនស្រុក ព្រះចៅ អធិការវត្ត និងលោកអភិបាលក្រុង/ស្រុក ប្រធាន និងអនុប្រធាន ក្រុមប្រឹក្សាក្រុង/ស្រុក លោកប្រធាន អនុប្រធានការិ. គណៈកម្មការសុខភាពសិក្សា ក្រុង/ស្រុក លោកនាយកសាលា លោកគ្រូ អ្នកគ្រូ មេឃុំ ក្រុមប្រឹក្សាឃុំ សហាគមន៍ និងគណៈកម្មការទ្រទ្រង់សាលាសរុប ១៦៥ នាក់ ។

- បានប្រារព្ធទិវាលាងសម្អាតដៃ និងទិវាអនាម័យជនបទឆ្នាំ២០១៧ មានអ្នកចូលរួម ៣៧០ នាក់ ។

-ចុះត្រួតពិនិត្យតាមដាន លើគោលការណ៍ អប្បរមារទឹកស្អាត និងអនាម័យតាមសាលារៀន តាម បណ្ដុគ្រឹះស្ថានបឋមសិក្សា បានចំនួន ៣២ សាលា នៅក្រុង/ស្រុកគោលដៅទាំង៨ ក្នុងខេត្តកំពត ។

-បើកកិច្ចប្រជុំ ពិគ្រោយោបល់ ស្ដីពីការលើកកម្ពស់ ការអនុវត្តទឹកស្អាតនិងអនាម័យ តាម សាលា រៀន មានសមាជិកចូលរួមសរុប ៤២ នាក់ ស្រី ០៦ នាក់ ។

**កិច្ចសហាការជាមួយ អង្គការ UNICEF**

-បានសហាការជាមួយនាយកដ្ឋានសុខភាព ចុះពិនិត្យតាមដាន ស្ដីពីការអនុវត្ត គម្រោងអនាម័យ គំរូតាមសាលារៀន តាមសាលាបឋមសិក្សាគោលដៅទាំង ២៩ក្នុងក្រុង. កំពត និងស្រុកអង្គរជ័យដើម្បីតាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគម្រោង ។

-បានបញ្ជូនមន្ត្រីចំនួន ០៤នាក់ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងកម្ម វិធីសិក្សា លម្អិតមុខវិជ្ជាសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា។

**កិច្ចសហាការជាមួយ អង្គការ RHAC**

-បានទៅចូលរួមប្រជុំប្រចាំត្រីមាស ជាមួយគណៈនាយក នាយិកាសាលា និងការិ. យាល័យអប់រំ យុវជន និងកីឡាស្រុក ស្ដីពីសុខភាពបន្តពូជ និង សុខភាពផ្លូវនៅក្រុង/ស្រុក គោលដៅទាំង ៨ មានសមាជិកចូលរួមសរុប ៣៨៧ នាក់ ស្រី ២៩ នាក់ ។

-បានទៅចូលរួមក្នុងសកម្មភាព ចុះពង្រឹងសមត្ថភាពគ្រូបន្ទុកថ្នាក់ ចំនួន ៦៧៧ នាក់ បាន ២ ជំហាន នៅក្រុង/ស្រុក គោលដៅទាំង ៨ លើប្រធាន បទការអប់រំបំណិន ជីវិត ស្តីពី សុខភាពបន្តពូជ និង សុខភាពផ្លូវភេទមានសិស្សានុសិស្សទទួលការអប់រំផ្សព្វផ្សាយដូច ខាងក្រោមៈ

**ផ្នែកបឋមសិក្សា**

-សិស្សថ្នាក់ទី៥ ៖ សរុប ១២,៣៦៥ នាក់ ស្រី ៦,១១៦ នាក់

-សិស្សថ្នាក់ទី៦ ៖ សរុប ១២,៣៦៣ នាក់ ស្រី ៦,២៣៤ នាក់

**ផ្នែកមធ្យមសិក្សា**

-សិស្សថ្នាក់ទី៧៖ សរុប ១១,៤៧១ នាក់ ស្រី ៥,៧៣៧ នាក់

-សិស្សថ្នាក់ទី៨៖ សរុប ៩,៦៥៧ នាក់ ស្រី ៤,៨៨៥ នាក់

-សិស្សថ្នាក់ទី១០៖ សរុប ៥,៥៧៧ នាក់ ស្រី ២,៨៣៤ នាក់

-សិស្សថ្នាក់ទី១១៖ សរុប ៤,៤៦២ នាក់ ស្រី ២,២៤២ នាក់

-បានបើកវគ្គបណ្តុះបណ្តាលស្តីពីសៀវភៅលំហាត់សម្រាប់គ្រូបង្រៀន ការអប់រំរឿង ផ្លូវភេទ ក្នុង គម្រោង អប់រំបំណិនជីវិត ស្តីពី សុខភាពផ្លូវភេទ និង សុខភាពបន្តពូជចំនួន ២វគ្គ មានសមាជិកចូលរួម សរុប ៦៥ នាក់ ស្រី ១១ នាក់ ។

-បានបញ្ជូនថ្នាក់ដឹកនាំគណៈកម្មការសុខភាពសិក្សាថ្នាក់ខេត្ត និង ក្រុង ស្រុក ចំនួន ០៥ នាក់ ស្រី០១ នាក់ ចូលរួមសិក្ខាសាលា ការអភិវឌ្ឍន៍កម្មវិធីសិក្សាលម្អិត ស្តីពីសុខភាព បន្តពូជ សុខភាព ផ្លូវភេទ ។

-បានបញ្ជូនមន្ត្រីចំនួន ១១ នាក់ ឱ្យទៅចូលរួមក្នុងសកម្មភាពចុះពង្រឹងសមត្ថភាព គ្រូបន្ទុកថ្នាក់ នៅស្រុក/ ក្រុងគោលដៅទាំង៨បានចំនួន ៨ លើក ២៤០ នាក់លើប្រធានបទ ការអប់រំបំណិនជីវិត ស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទដល់សិស្សានុសិស្ស ។

-បានបើកសិក្ខាសាលា ស្តីពីការអប់រំរឿងផ្លូវភេទ ក្នុងគម្រោងអប់រំបំណិនជីវិត សុខ

ភាពបន្តពូជ និងសុខភាពផ្លូវភេទនៅតាមបណ្តុក្រុង/ស្រុកគោលដៅទាំង ៨ ក្នុងខេត្តកំពត មានសិក្ខាកាមចូលរួម សរុប ២៥៧ នាក់ ស្រី ១២៦ នាក់ ។

**កិច្ចសហការជាមួយ អង្គការ COCD**

-បានចុះត្រួតពិនិត្យតាមដាន និងផ្សព្វផ្សាយចំនួន ៩ លើក នៅតាមបណ្តុសាលាបឋសិក្សា នៅស្រុកឈូកចំនួន១១សាលាពិនិត្យតាមដានអប់រំណែនាំ អំពីការលាងសម្អាតដៃ ជាមួយសាប៊ូ ការប្រប្រាស់ទឹកសុវត្ថិភាព ការបន្ទោបង់ក្នុងបង្គន់ និងការប្រើប្រាស់បង្គន់អនាម័យប្រចាំរបស់សិស្សនៅសាលា និង នៅគេហដ្ឋាន ។

-បានចូលរួមបើកវគ្គតម្រង់ទិស ស្តីពី បង្គន់អនាម័យ និង ទឹកស្អាតនៅតាមសាលារៀន ក្នុងឈូក មានសិក្ខាកាមចូលរួម សរុប ២៧ នាក់ ស្រី ១២ នាក់ ។

-បានចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពី បង្គន់អនាម័យ និង ទឹកស្អាតនៅតាមសាលារៀន ក្នុងស្រុក ដងទង់ មានអ្នកចូលរួម សរុប ៣៣នាក់ ស្រី ១៣ នាក់។

**កិច្ចសហការជាមួយ ក្រសួងសុខាភិបាល (អង្គការសុខភាពពិភពលោក)**

-បានបញ្ជូនថ្នាក់ដឹកនាំមន្ទីរ,ការិយាល័យអប់រំ យុវជន និងកីឡាក្រុងកំពត និង គណៈនាយក សាលាបឋម និងមធ្យមសិក្សា សរុបចំនួន ១៩ នាក់ ចូលរួមសិក្ខាសាលា ស្តីពី ភាពជាអ្នកដឹកនាំក្នុងការ អនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ នានា ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ដល់ អាជ្ញធរថ្នាក់ ក្រោមជាតិ។

**លទ្ធផលធៀបទៅនឹងទិសដៅឆ្នាំសិក្សាកន្លងមក**

**ការងារបានអនុវត្ត**

**ការអនុវត្តថវិកាតាមកម្មវិធីសកម្មភាព PB-២០១៧**

-បានអនុវត្តនិងពិនិត្យតាមដានកម្មវិធីសកម្មភាពវិស័យការងារលើកកម្ពស់សុខភាពសិក្សា នៅ តាម បណ្តុក្រុង / ស្រុក និងសាលារៀនទាំងអស់នៅទូទាំងខេត្តកំពតទទួលលទ្ធផល ធៀប និងទិសដៅ ប្រចាំឆ្នាំ ២០១៧ នេះបាន ១០០ % ។

-បានបើកវគ្គបំប៉នស្តីពីសុខភាពអនាម័យ អាហារូបត្ថម្ភ វិធីសាស្ត្រ និងការប្រើប្រាស់ប្រអប់ សង្គ្រោះបឋមសម្រេចលទ្ធផលធៀបនិងទិសដៅក្នុងឆ្នាំសិក្សាកន្លងទៅបាន១០០%

-ផ្តល់សម្ភារ និង ប្រអប់សង្គ្រោះបឋមសម្រេចលទ្ធផលធៀបនឹងទិសដៅក្នុងឆ្នាំសិក្សាកន្លង ទៅបាន ១០០% ។

- ការសាងសង់បង្គន់អនាម័យ លទ្ធផលធៀបនឹងទិសដៅប្រចាំឆ្នាំ ២០១៧ បាន ១០០% ។

**បញ្ហាប្រឈម**

**ការងារគណៈកម្មការសុខភាពសិក្សាខេត្ត**

-មន្ត្រីទទួលបន្ទុកការងារសុខភាពសិក្សាតាមបណ្តាក្រុង/ស្រុកនិងសាលារៀន មួយចំនួនមិនទាន់ យកអស់ស្មារតីទទួលខុសត្រូវ និងបំពេញភារកិច្ចរបស់ខ្លួនឱ្យបានល្អនៅឡើយ។

-នៅក្នុងថវិកាPBរបស់សាលារៀននីមួយៗគ្មានខ្ទង់សម្រាប់ចំណាយទៅលើការងារអប់រំ សុខភាពនៅឡើយ ។

-ពុំទាន់មានគម្រោងកម្មវិធីសកម្មភាព PB របស់គណៈកម្មការសុខភាពសិក្សាសម្រាប់ធ្វើ ការងារអប់រំ ផ្សព្វផ្សាយអំពីសុខភាពទូទៅ ដល់យុវជនក្នុង និង ក្រៅសាលារៀន ។

**១.១.គ- ការងារសំណង់**

មន្ទីរអប់រំ យុវជន និងកីឡាខេត្តបានទទួលការសាងសង់រួមមាន ៖

- អង្គការពុទ្ធិកៈបណ្ណាល័យកម្ពុជាបានសាងសង់អគារ ១ ខ្នង ២ បន្ទប់ នៅសាលាបឋមសិក្សាបឹងទូក ស្រុកទឹកឈូ ។

- សាងសង់អគារ ១ ខ្នង ៥ បន្ទប់ នៅបឋមសិក្សាសិក្សាកោះតូច ស្រុកទឹកឈូ ជាអំណោយរបស់អង្គការសាមគ្គី ។

- សាងសង់អគារ ១ ខ្នង ១៥ បន្ទប់ បីជាន់ នៅបឋមសិក្សាមហាសាមគ្គី ក្រុងកំពតថវិការបស់ក្រសួងអប់រំ ។

- សាងសង់អគារ ១ ខ្នង ៥ បន្ទប់ នៅបឋមសិក្សារោងចក្រស៊ីម៉ងដ៍ ស្រុកទឹកឈូ

ថវិកាធនាគារពិភពលោក ។

- សាងសង់អគារ ១ ខ្នង ៥ បន្ទប់ នៅបឋមសិក្សាឧត្តមមានជ័យ ស្រុកទឹកឈូ ថវិកាធនាគារពិភពលោក ។

- ព្រះចៅអធិការវត្តកំពូលមាសបានសាងសង់អគារ ១ ខ្នង ៥ បន្ទប់ នៅបឋមសិក្សាកំពូលមាស ស្រុកកំពង់ត្រាច ។

- អង្គការតាប៊ីតាបានសាងសង់អគារ ១ ខ្នង ៦ បន្ទប់នៅបឋមសិក្សាអង្គគ្រូង ស្រុកកំពង់ត្រាច ។

- អង្គការស៊ីប៉ាបានសាសង់អគារ ១ ខ្នង ៥ បន្ទប់ នៅបឋមសិក្សាកោះត្នោត ស្រុកកំពង់ត្រាច ។

- ជួសជុលអគារ អនុវិទ្យាល័យ ហ៊ុន សែន ក្រាំងអំពិល ក្រុងកំពត ២ ខ្នង ១២ បន្ទប់ ថវិការបស់មន្ទីរអប់រំ ។

- សាងសង់អគារ ១ ខ្នង ៥ បន្ទប់ នៅបឋមសិក្សាកំពង់ត្រាច ស្រុកកំពង់ត្រាច ថវិការបស់ធនាគារពិភពលោក ។

**១.២ ការងារអធិការកិច្ច**

- បានចុះធ្វើអធិការកិច្ចតាមកាលកំណត់បានចំនួន ០៨ ក្រុង/ស្រុក ស្មើនឹង ៣៧ សាលា ក្នុងនោះបឋមសិក្សា ២៣ សាលា អនុវិទ្យាល័យ ១៤ សាលា បានសង្កេតគ្រូ ១៣៩ នាក់ បានសម្ភាសន៍សហគមន៍ ៦៥ នាក់ បានសម្ភាសន៍សិស្ស ២៥២ នាក់ បានសម្ភាសន៍គ្រូ ១៩៥ នាក់ បានសម្ភាសន៍គណៈគ្រប់គ្រងសាលា ៥៩ នាក់ បើធៀបនឹងឆ្នាំ ២០១៦ កើនឡើង ០៤ សាលា ។

- បានសហការជាមួយនាយកដ្ឋានធានាគុណភាពអប់រំ រៀបចំស្ថិតិគ្រូ សិស្សសម្រាប់ការធ្វើតេស្ត PISA-D បាន១២ សាលា ។

- បានចុះប្រមូលទិន្នន័យស្តីពីស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់បាននៃយុទ្ធ. សាស្ត្រកំណែទម្រង់ការគ្រប់គ្រងវិស័យអប់រំ ដើម្បីពង្រឹងគុណភាពពលរដ្ឋនៅកម្ពុជា នៅវិទ្យាល័យកន្សោមអក ហ៊ុន សែនឈូក និងវិទ្យាល័យព្រះបិតាជាតិ ។

– បានចូលរួមសិក្ខាសាលាស្តីពីអត្រាកំណែ ការបង្កើតវិញ្ញាសាតេស្ត ការគ្រប់គ្រងការបញ្ចូលទិន្នន័យតេស្ត PISA-D ។

- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សាថ្នាក់

ជាតិថ្នាក់ទី៦ និងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីគម្រោងលម្អិត និងកម្រងសំណួរតេស្ត វាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិថ្នាក់ទី៨ ។

**បញ្ហាប្រឈម**

- ថវិកាចុះធ្វើអធិការកិច្ចតាមកាលកំណត់មានចំនួនតិចតួចមិនឆ្លើយតបនឹងវដ្ត អធិការកិច្ច ( ៥ ឆ្នាំ ) ។
- ខ្វះមធ្យោបាយធ្វើដំណើរដើម្បីចុះអធិការកិច្ចតាមកាលកំណត់នៅតាមបណ្ដុំសាលារៀន ។
- ពុំមានកញ្ចប់ថវិការៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលការងារអធិការកិច្ចតាម កាលកំណត់ជូនគណៈគ្រប់គ្រងសាលា និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក
- ពុំមានកញ្ចប់ថវិកាសម្រាប់ការសហការជាមួយនាយកដ្ឋានធានាគុណភាពអប់រំ ក្នុងការចុះធ្វើតេស្តថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ។
- ខ្វះកុំព្យូទ័រ ០៣ គ្រឿង សម្រាប់រៀបចំរបាយការណ៍ និងប្រតិបត្តិការងារ
- ខ្វះបន្ទប់សម្រាប់អង្គុយធ្វើការងារ ព្រោះចំនួនអធិការមានកំណើនឡើង

**១.៣ ការងាររដ្ឋបាល**

- បែងចែកភារៈកិច្ចជូនមន្ត្រីបុគ្គលិកទទួលខុសត្រូវតាមផ្នែក
- បានធ្វើផែនការ ការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បានលើកសំណើសុំយោបល់ពីថ្នាក់ដឹកនាំ ដើម្បីប្រជុំដោះស្រាយការងារបន្ទាន់ឬ ការងារដែលត្រូវផ្សព្វផ្សាយ ។
- រៀបចំកម្មវិធីប្រជុំ ត្រួតពិនិត្យលទ្ធផលការងាររបស់ថ្នាក់ដឹកនាំតាមកាលកំណត់
- បានយកចិត្តទុកដាក់គ្រប់គ្រងឯកសារ ដោយស្មារតីទទួលខុសត្រូវខ្ពស់
- បានលើកកម្ពស់ការគ្រប់គ្រងសម្ភាររដ្ឋ
- ទទួលលិខិតរបស់ក្រសួងអប់រំ យុវជន និងកីឡា បានចំនួនៈ ៨៨៩ ច្បាប់
- ទទួលលិខិតរបស់មន្ទីរនានាជុំវិញខេត្ត បានចំនួនៈ ១០០ ច្បាប់
- ទទួលលិខិតរបស់សាលាខេត្ត បានចំនួនៈ ១៣៩ ច្បាប់
- ទទួលលិខិតរបស់ការិយាល័យអប់រំ យុវជន និង កីឡាក្រុង/ស្រុកបានចំនួនៈ ៧៤ ច្បាប់ ។
- លិខិតចេញ បានចំនួនៈ ១៧០២ ច្បាប់

- បញ្ជូនលិខិតបានចំនួន : ៦៣ ច្បាប់

- បានចុះពង្រឹងការងារគ្រប់គ្រងរដ្ឋបាល និងបណ្ណសារដល់ថ្នាក់សាលារៀនក្នុងក្រុង/ស្រុកទាំង ៨ បានចំនួន ៥៦ សាលា ក្នុងនោះមានវិទ្យាល័យ ០៧ សាលា អនុវិទ្យា. ល័យ ១៦ សាលា និងបឋមសិក្សា ៣៣ សាលា ។

**បញ្ហាប្រឈម:**

- សមត្ថភាពលើការងារគ្រប់គ្រង និងកិច្ចការរដ្ឋបាលនៅមានកម្រិត
- សមត្ថភាពលើការប្រើប្រាស់ Computer, Email, Internet នៅមានកម្រិត
- សមត្ថភាពលើកិច្ចការពិធីការ និង MC នៅមានកម្រិត
- ការទុកដាក់ឯកសារ តាមលក្ខណៈបច្ចេកទេសបណ្ណសារ នៅមានកម្រិត ។

### ១.៤ ការងារគណនេយ្យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

- ថវិកាឆ្នាំ ២០១៧ មានចំនួន ៩២,១៥១,០០០,០០០ រៀល ឥណទានកែតម្រូវ ៩៧,៥៧២,៣៨៧,០០០ រៀល ។

- អនុវត្តបាន ៨២,១៨៧,២៣៧,៦៨៣ រៀល ស្មើនឹង៨៤.២៣%

- មានការផ្សព្វផ្សាយនូវលិខិតបទដ្ឋានផ្សេងៗដល់ ថ្នាក់ក្រុង/ស្រុក និងមន្ទីរពេលមានការប្រជុំបូកសរុបប្រចាំខែ និងពេលប្រជុំការងារផ្សេងៗ ។

- ការពិនិត្យតាមដាន មានការចុះជួយជាប្រចាំដល់ថ្នាក់ក្រុង/ស្រុក និងសាលារៀនដែលពុំទាន់យល់ច្បាស់ពីការរៀបចំកិច្ចបញ្ជីការ និងជាពិសេសចំពោះសាលាដែលមានការផ្លាស់ប្តូរគណៈកម្មការ ។

**បញ្ហាប្រឈម**

- កញ្ចប់ថវិកាផ្តល់មិនបានតាមការស្នើសុំ

- មន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុតាមក្រុង/ស្រុក និងសាលារៀនមានការផ្លាស់ប្តូរញឹកញាប់ ។

- មន្ត្រីនៅតាមការិយាល័យអប់រំក្រុង/ស្រុក និងសាលាពុំទាន់យល់ច្បាស់ពីនិតិវិធីទូទាត់ថវិការដ្ឋទេយ្យបុរេប្រទាន ( មានការប្រែប្រួលតាមតម្រូវការទូទាត់របស់មន្ទីរហិរញ្ញវត្ថុ ។

- ឯកសារមួយចំនួនដែលបានបញ្ជូនពីក្រុង/ស្រុក និងសាលានៅមានកំហុសឆ្គងមួយចំនួន និងមានការយឺតយ៉ាវ ។

### ១.៥ ការងារបុគ្គលិក និងនីតិកម្ម

ក្របខ័ណ្ឌសរុបប្រចាំឆ្នាំសិក្សា ២០១៦-២០១៧ ( គិតក្នុង ខែ វិច្ឆិកា ឆ្នាំ ២០១៦ ) មានចំនួន ៥,៨១៤ នាក់ ស្រី ២,៩៣៣ នាក់(ក្នុងនោះគ្រូចេញថ្មី ឆ្នាំ២០១៦ ចំនួន១៩០ នាក់ ស្រី ៩៩ នាក់ ) និង មន្ត្រីជាប់កិច្ចសន្យា ចំនួន ០៦ នាក់ ស្រី ០៤ នាក់ ធៀបនឹងឆ្នាំសិក្សាចាស់ ២០១៥-២០១៦ មាន ចំនួន ៥,៧០១ នាក់ ស្រី ២,៣៧៦ នាក់ ។

**ក្របខ័ណ្ឌសរុប ឆ្នាំ សិក្សា ២០១៦-២០១៧ ចែកជា៖**

-គ្រូបង្រៀនកម្រិតឧត្តម ចំនួន ៦៨០ នាក់ ស្រី ១៨១ នាក់

-គ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ២,៤៥៧ នាក់ ស្រី ៩៥២ នាក់

-គ្រូបង្រៀនកម្រិតកម្រិតបឋម ចំនួន ២,៦៧៧ នាក់ ស្រី ១,៣០០ នាក់ ក្នុងនោះគ្រូមត្តេយ្យសិក្សា ១៧៥ នាក់ ស្រី ១៧៥ នាក់ ។

ដោយខ្វះគ្រូបង្រៀនពិសេសនៅតាមសាលាបឋមសិក្សា ឆ្នាំសិក្សា ២០១៥-២០១៦ យើងបាន ប្រើប្រាស់គ្រូបង្រៀន ០២ ថ្នាក់ ០២ ពេល ចំនួន ៣៣៩ នាក់ និង ថ្នាក់គួប ចំនួន ៥៨ នាក់ ធៀបទៅឆ្នាំសិក្សា ២០១៦-២០១៧ គ្រូបង្រៀន ០២ ថ្នាក់ ០២ ពេល ចំនួន ៣០៩ នាក់ និងថ្នាក់គួប ចំនួន ៦៥ នាក់ ការបែងចែកប៉ុស្តិ៍ បុគ្គលិកចេញថ្មី ចំនួន ១៤៧ នាក់ ស្រី ៧២ នាក់ នឹងចាត់តាំងបុគ្គលិកដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរកន្លងមកសុំចូលបម្រើការងារវិញចំនួន ០៦ នាក់ ស្រី ០១ នាក់ ដាក់ចំគោលដៅសាលាខ្វះគ្រូក្នុងខេត្ត ។

ធ្វើការផ្លាស់ប្តូរទីកន្លែងបម្រើការងារជូនបុគ្គលិកអប់រំក្នុងខេត្តប្រចាំឆ្នាំ ២០១៧ ដើម្បីសម្រួលការលំបាកក្នុងជីវភាពប្រចាំថ្ងៃនឹងទៅតាមតម្រូវការក្របខ័ណ្ឌជាក់ស្តែងនៅមូល. ដ្ឋានចំនួន ១៣៦ នាក់ ស្រី ៦៦ នាក់។

បានយកចិត្តទុកដាក់ធ្វើសំណើសុំប្រាក់ឧបត្ថម្ភជីវភាពជូនបុគ្គលិកអប់រំដែលបម្រើការនៅតាម តំបន់ជួបការលំបាកប្រចាំឆ្នាំសិក្សា ២០១៦-២០១៧ ចំនួន ២១៥៩ នាក់ ស្រី ៨១២ នាក់ ធៀបនឹងឆ្នាំសិក្សា ២០១៥-២០១៦ ចំនួន ២០៧៨ នាក់ ស្រី ៧៤៩ នាក់ ។

**ក្នុងឆ្នាំ សិក្សា ២០១៦-២០១៧**

-ការស្នើតែងតាំងមន្ត្រីគ្រប់គ្រង ឆ្នាំ ២០១៧ ចាប់ពីនាយករងសាលាដល់ ប្រធានការិយាល័យអប់រំយុវជន និង កីឡា ក្រុង-ស្រុកបានចេញដីកាសម្រេចពីរដ្ឋបាលខេត្តកំពតចំនួន ៣៩ នាក់ ស្រី ០៩ នាក់។

-បានគ្រោងថវិកាប្រចាំឆ្នាំ ២០១៧សម្រាប់បើកបៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗជូន

បុគ្គលិកអប់រំទូទាំងខេត្តចំនួន ៩៧ ០០០ ០០០ ០០០ រៀល ( កៅសិបប្រាំពីរពាន់លានរៀលគត់ ) ដោយមិនគិតចូលប្រាក់សម្រាប់ ដំណើរការអង្គភាព ការិយាល័យ-សាលា និងប្រាក់បេសកកម្មឡើយ។

-បានធ្វើការប្រែប្រួលស្ថានភាពរដ្ឋបាលមន្ត្រីរាជការនិងគ្រួសារមន្ត្រីរាជការទូទាំងខេត្តតាមខែជាប្រចាំ។

-បុគ្គលិកសុំទំនេរគ្មានបៀវត្ស ចំនួន ១១ នាក់ ស្រី ០១ នាក់

-សុំច្បាប់លំហែមាតុភាពចំនួន ២១៦ នាក់ និងសុំច្បាប់ព្យាបាលជំងឺចំនួន ១៤ នាក់ ស្រី ០៥ នាក់ ។

-សុំច្បាប់រៀនបន្តថ្នាក់អធិការអប់រំចំនួន ០៦ នាក់ ស្រី ០០ នាក់

-សុំច្បាប់រៀនបន្តគ្រូបង្រៀនកម្រិតឧត្តមចំនួន០៨ នាក់ ស្រី ០៤នាក់និងគ្រូមូលដ្ឋាន ០២ នាក់ ស្រី ០០ នាក់ ។

-សុំច្បាប់ទៅបម្រើការងារនៅក្រៅក្របខណ្ឌដើមចំនួន ០២ នាក់ ស្រី ០០ នាក់

-ស្នើដំឡើងថ្នាក់ប្រចាំឆ្នាំ ២០១៧ ចំនួន ២៨២ នាក់ ( បុគ្គលិក មានឆ្នាំកំណើត ១៩៥៧ ចំនួន ២០ នាក់ ដែលត្រូវចូលនិវត្តន៍ ) ។

-ស្នើតាំងស៊ប់ជូនបុគ្គលិកអប់រំចេញឆ្នាំ ២០១៦ ចំនួន ១៦៤ នាក់ ស្រី ៨៨ នាក់

-ស្នើតែងតាំងស៊ប់ជូនអតីត បុគ្គលិកអប់រំចេញឆ្នាំ ២០១៧ ចំនួន ១០០ នាក់ ស្រី ៤៧ នាក់ ។

-ស្នើលុបឈ្មោះបុគ្គលិកបោះបង់ការងារ និង ទទួលមរណភាព ចំនួន ១៨ នាក់ ស្រី ០១ នាក់ ។

-ស្នើលុបឈ្មោះបុគ្គលិក ដោយសុំប្រាក់ឧបត្ថម្ភ ចំនួន ០២ នាក់ ស្រី ០០ នាក់

-ស្នើដាក់បុគ្គលិកអប់រំមានឆ្នាំកំណើត ១៩៥៧ ឱ្យចូលនិវត្តន៍ ចំនួន ៤៦ នាក់ ស្រី ២២ នាក់ ។

-ស្នើដាក់បុគ្គលិកអប់រំចូលនិវត្តន៍មុនអាយុកំណត់ចំនួន ០៧ នាក់ ស្រី ០៥ នាក់

-បែងចែកកម្រងសំណួរសម្រាប់បុគ្គលិកអប់រំនិងសម្រាប់នាយកសាលាបំពេញដើម្បីធ្វើបច្ចុប្បន្នភាពក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ។

**លទ្ធផលនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ សិក្សាកន្លងមក**

-ពង្រឹងការគ្រប់គ្រងបុគ្គលិក ដោយធ្វើការត្រួតពិនិត្យចុះវត្តមានជាប្រចាំ និងបូកសរុបវត្តមាន ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ។

-ស្នើលុបឈ្មោះបុគ្គលិក ដោយសុំឈប់សុំប្រាក់ឧបត្ថម្ភ បោះបង់ការងារ ស្លាប់ និងសុំឈប់ ។

-ស្នើតែងតាំងមន្ត្រីគ្រប់គ្រង ជំនួសអ្នកចូលនិវត្តន៍ អ្នកស្លាប់ និង សាលាបើកថ្មីដើម្បីបន្ត និរន្តភាពការងារដឹកនាំ-គ្រប់គ្រងអង្គភាព ។

-គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យានឹងធ្វើបច្ចុប្បន្នភាពទិន្នន័យបុគ្គលិកតាមស្ថានភាពប្រែប្រួលជាប្រចាំ ។

-ចុះតាមដានការប្រើប្រាស់គ្រូគ្រប់ភូមិសិក្សាតាមក្រុង/ស្រុកនិងអង្គភាពសាលារៀន ដោយប្រើប្រាស់ ថវិកា PB ។

-ធ្វើបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការរៀងរាល់ខែ តាមការអនុញ្ញាតរបស់មន្ទីរ និងក្រសួងមុខងារសាធារណៈខេត្តកំពត ។

**បញ្ហាប្រឈម**

- ការស្នើតែងតាំងមន្ត្រីគ្រប់គ្រង ដីកាតែងតាំងមានការយឺតយ៉ាវជាងការចេញប្រកាសដោយក្រសួងអប់រំយុវជន និង កីឡា ។

- មន្ត្រីទទួលបន្ទុកផ្នែកបុគ្គលិក តាមបណ្តា ក្រុង/ស្រុក ខ្វះសម្ភារប្រើប្រាស់ផ្នែកបច្ចេកវិទ្យា ។

- ការពង្រាយគ្រូចាស់តាមគោលការណ៍ស្ម័គ្រចិត្តក្នុងខេត្តមិនបានអនុវត្ត ។

## ១.៦ ការងារបណ្តុះបណ្តាល និងវិក្រឹតការ

### ក-ការបំពេញការងារសំខាន់ៗធៀបទៅនឹងចំណុចដៅប្រចាំឆ្នាំ

-ការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបឋមសិក្សាឆ្នាំ២០១៧ (១២ បូក ២ ) ជំនាន់ទី ៣៤ សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពត ចំនួន ៩៣ នាក់ ស្រី ៥២ នាក់ ដោយមិនគិតក្របខ័ណ្ឌ ខេត្តកែប ។

-បណ្តុះបណ្តាលគរុសិស្សបឋមសិក្សាឆ្នាំទី ២ ជំនាន់ទី ៣៥ ចំនួន ៥៣ នាក់ និង មត្តេយ្យសិក្សា ០៨ នាក់ ដែលប្រឡងជាប់ ក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៦ ។

-បញ្ជូនគ្រូបឋមសិក្សា និង មត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយ. ភូមិទៅបំប៉នជាគ្រូបង្រៀនកម្រិតមូលដ្ឋានជំនាន់ទី ១០វេនទី ២ ចំនួន៨០ នាក់ស្រី៣២នាក់ នៅ មជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគតាកែវ បានបញ្ចប់ជាស្ថាពរ ។

-បញ្ជូនគ្រូបឋមសិក្សានិង មត្តេយ្យសិក្សា ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយ. ភូមិ ទៅបំប៉ន ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ជំនាន់ទី ១១ វេនទី ១ ចំនួន ៨០ នាក់ ស្រី ៣៥ នាក់ នៅមជ្ឈមណ្ឌល គរុកោសល្យ ភូមិភាគតាកែវ ។

**ខ-លទ្ធផលនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ សិក្សាកន្លងមក**

-បានធ្វើការផ្សព្វផ្សាយ និងរៀបចំទទួលសំណុំលិខិត ប្រឡងគ្រូ កម្រិតមូលដ្ឋាន គ្រូបឋមសិក្សា និង មត្តេយ្យសិក្សា សម្រាប់ឆ្នាំសិក្សា ២០១៦-២០១៧ ។

-បញ្ជូនគរុសិស្ស ដែលទើបប្រឡងជាប់ ឱ្យទៅទទួលការបណ្ដុះបណ្ដាលសម្រាប់ឆ្នាំសិក្សា ២០១៧- ២០១៨ ដែលមានគរុសិស្សមត្តេយ្យសិក្សា ចំនួន ០៧ នាក់ គរុសិស្សបឋមសិក្សា ៥៥ នាក់ និង គរុសិស្សមធ្យម សិក្សាចំនួន ៣២ នាក់ ។

**បញ្ហាប្រឈម**

- មុខវិជ្ជាមួយចំនួនពិបាករកឯកសារមកបង្រៀនគរុសិស្ស ប្រវត្តិវិទ្យា គណិតវិទ្យា ភាសាអង់គ្លេស ការលើកកម្ពស់ភាសាជាតិ ។

- ខ្វះអគារវិទ្យាសាស្ត្រ ( យកថ្នាក់រៀនធ្វើជាបន្ទប់វិទ្យាសាស្ត្រ )

- ខ្វះ Internet ក្នុងបន្ទប់សិក្សារបស់គរុសិស្ស ( ក្រុមហ៊ុន Cellcard ) គ្រាន់តែយក Logo មកបិទផ្សាយនៅក្នុងបណ្ណាល័យ ប៉ុន្តែពុំភ្ជាប់ Internet សម្រាប់ប្រើប្រាស់ទេ )

**២- លទ្ធផលតាមអនុវិស័យ**

**២.១ អនុវិស័យអប់រំកុមារតូច**

**ក- ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

- កុមារអាយុ ៥ ឆ្នាំ ក្នុងខេត្តមាន ១១,៨៨៣ នាក់ ស្រី ៦,០៨៨ នាក់ ចូលរៀនចំនួន ៧,៣៩២ នាក់ ស្រី ចំនួន ៣,៥៤២ នាក់ ស្មើនឹង ៦២.០% ( ខ្ពស់ជាងចំណុចដៅ ១.០%)

- កុមារអាយុ ៤ ឆ្នាំ ក្នុងខេត្តមាន ១១,១៣៣ នាក់ ស្រី ៥,៦៥៦ នាក់ ចូលរៀនបានចំនួន ៣,៤៧០ នាក់ ស្រី ១,៧៦២ នាក់ ស្មើនឹង ៣១.០% ( ខ្ពស់ជាងចំណុចដៅ ១.០%)

- កុមារអាយុ ៣ ឆ្នាំ ក្នុងខេត្តមាន ១០,៦២៦ នាក់ ស្រី ៥,៤៤៧ នាក់ ចូលរៀនបាន

ចំនួន ២,២៦៧ នាក់ ស្រី ១,១១៧ នាក់ ស្មើនឹង ២១.0% ( ខ្ពស់ជាងចំណុចដៅ ១.0% )

**ក១-ការប្រែប្រួលស្ថានភាពហេដ្ឋារចនាសម្ព័ន្ធអប់រំ**

| ល.រ | បរិយាយ | ២០១៦-២០១៧ | ២០១៧-២០១៨ | កើន-ថយ |
|---|---|---|---|---|
| ១ | អគារ | ០៥ | ៦ | +១ |
| ២ | ថ្នាក់ | ២៥៣ | ២៥២ | - ១ |

**ក២-ការប្រែប្រួលស្ថានភាពបុគ្គលិកអប់រំ**

| បរិយាយ | ២០១៦-២០១៧ | | ២០១៧-២០១៨ | | កើន-ថយ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| មត្តេយ្យសិក្សារដ្ឋ | ២៥៥ | ២៤៦ | ២៥២ | ២៥២ | - ៣ | + ៦ |
| មត្តេយ្យសិក្សាសហគមន៍ | ១១៣ | ១០៨ | ១៣៦ | ១២៨ | + ២៣ | + ២០ |
| មត្តេយ្យសិក្សាឯកជន | ៣៣ | ៣៣ | ៣៥ | ៣៥ | + ២ | + ២ |
| អប់រំកុមារតាមផ្ទះ | ១៣៥ | ១២៥ | ១៣១ | ១២១ | - ៤ | - ៤ |

**ក៣-ការប្រែប្រួលស្ថានភាព សាលា ថ្នាក់ សិស្សានុសិស្ស**

| បរិយាយ | ២០១៦-២០១៧ | ២០១៧-២០១៨ | កើន-ថយ |
|---|---|---|---|
| **មត្តេយ្យសិក្សារដ្ឋ** | | | |
| សាលារៀន | ១៩២ | ១៩២ | 0 |
| ថ្នាក់រៀន | ២៥៣ | ២៥២ | - ១ |
| កុមារសរុប | ៦,៧៦៧ | ៦,៨៨១ | + ១១៤ |
| ស្រី | ៣,២២៩ | ៣,៣៤៥ | + ១១៦ |
| **មត្តេយ្យសិក្សាសហគមន៍** | | | |
| ចំនួនកន្លែង | ១៣០ | ១៣០ | 0 |
| ថ្នាក់រៀន | ១១២ | ១៣១ | + ១៩ |

| | | | |
|---|---|---|---|
| កុមារសរុប | ២,៣៩១ | ៣,០២៤ | + ៦៨៣ |
| ស្រី | ១,១៥០ | ១,៥៣២ | + ៣៨២ |
| **មត្តេយ្យសិក្សាឯកជន** | | | |
| ចំនួនកន្លែង | ១៣ | ១៣ | ០ |
| ថ្នាក់រៀន | ២៧ | ៣៥ | + ៨ |
| កុមារសរុប | ៩៣៨ | ៩០៧ | - ៣១ |
| ស្រី | ៤៥៩ | ៤៣៨ | - ២១ |
| **អប់រំកុមារតូចតាមផ្ទះ** | | | |
| ស្រុក | ៨ | ៨ | ០ |
| ឃុំ | ៦៩ | ៦៦ | - ៣ |
| ភូមិ | ១៣៥ | ១៣១ | - ៤ |
| ក្រុម | ៦៧៥ | ៦៥៥ | - ២០ |
| ម្ដាយកុមារ | ៣,៣៧៩ | ២,៩៨៩ | - ៣៩០ |
| កុមារ | ៤,១៥៩ | ៤,១០៩ | - ៥០ |
| ក្នុងនោះកុមារី | ២,០១១ | ១,៩៨១ | - ៣០ |
| សរុបរួមៈថ្នាក់ | ៣៩២ | ៤២៣ | + ៣១ |
| កុមារ | ១៤,២០៥ | ១៤,៩២១ | + ៧១៦ |
| ក្នុងនោះកុមារី | ៦,៦១៨ | ៧,២៩៦ | + ៦៧៨ |

**ខ- ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

**ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្តោតលើលទ្ធផល :**

- បានទទួលការបំប៉នសមត្ថភាព ស្តីពីការរៀបចំថ្នាក់រៀន និងការងារបច្ចេកទេសផ្នែកមត្តេយ្យសិក្សារដ្ឋតាមស្តង់ដាគុណភាពនៅខេត្តពោធិ៍សាត់ចំនួន ២០នាក់ ស្រី២០នាក់

- បានចុះជួយការងារតាមក្រុង/ស្រុកទាំង៨ ក្នុងនោះពិនិត្យលើការគ្រប់គ្រងរបស់នាយក/នាយិកាចំនួន ៣៦ សាលា ស្មើនឹង ១៨.៧៥% ការបង្រៀន និង រៀនរបស់គ្រូមត្តេយ្យសិក្សារដ្ឋមានចំនួន៩៥ នាក់ ស្មើនឹង ១៧.៦៥% គ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន ៣២ នាក់ ស្មើនឹង ២៨.៥៧% និងមាតាបិតាបង្គោលចំនួន ៣៧ នាក់ ស្មើនឹង ២៧.៤០% ។

**ការអភិវឌ្ឍសមត្ថភាពអនុវិស័យ**

- ក្រោមកិច្ចសហការជាមួយអង្គការកុមារ និងអភិវឌ្ឍប្រចាំខេត្តបានបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន ១៤ នាក់ ក្នុងនោះ ស្រុកទឹកឈូមាន ៧ នាក់ និង ស្រុកដងទង់ ៧ នាក់ មាតាបិតាបង្គោល ៦ នាក់ ក្នុងនោះស្រុកទឹកឈូ ៣ នាក់ និងស្រុកដងទង់ ៣ នាក់ ។

- បានប្រជុំបច្ចេកទេសមត្តេយ្យសិក្សារដ្ឋចំនួន ១៤ លើក នៅក្នុងក្រុង/ស្រុកទាំង៨ សរុបចំនួន ២៦០ នាក់ ស្រី ២៥១ នាក់ ។

**២.២ អនុវិស័យបឋមសិក្សា**

**ក- ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ ស្ថានភាពអប់រំ យុវជន និងកីឡាក្នុងខេត្តមានការប្រែប្រួល ផ្នែកបឋមសិក្សា បើប្រៀបធៀបទៅនឹងឆ្នាំកន្លងមកមានដូចខាងក្រោម ។

**ការប្រែប្រួលស្ថានភាពហេដ្ឋារចនាសម្ព័ន្ធអប់រំ**

| **បរិយាយ** | ២០១៦-២០១៧ | ២០១៧-២០១៨ | កើន(+) / ថយ(-) |
|---|---|---|---|
| ចំនួនអគារសិក្សា | ៦៨០ | ៦៨៥ | +៥ |
| ចំនួនបន្ទប់ | ២,៩១៨ | ២,៩២៩ | +១៨ |
| ចំនួនបន្ទប់រៀន | ១,៩០០ | ១,៩៦៩ | +៦៩ |

**ការប្រែប្រួលស្ថានភាព ស្ថិតិសាលា ថ្នាក់ សិស្ស និងបុគ្គលិក**

| **បរិយាយ** | **ឆ្នាំសិក្សា** | | %កើន(+) / ថយ(-) |
|---|---|---|---|
| | ២០១៦-២០១៧ | ២០១៧-២០១៨ | |
| សាលារៀន | ៣០៧ | ៣០៩ | +២ |

| | | | |
|---|---|---|---|
| កម្រងសាលារៀន | ៦២ | ៦៣ | +១ |
| សាលាមិនគ្រប់កម្រិត | ១០ | ៨ | - ២ |
| ថ្នាក់រៀន | ២,៤៧១ | ២,៤៥៣ | - ១៨ |
| សិស្សសរុប | ៨១,៨០៩ | ៧៩,២៦១ | - ២,៥៤៨ |
| សិស្សស្រី | ៣៩,១៧១ | ៣៨,១៥១ | - ១,០២០ |
| បុគ្គលិកអប់រំសរុប | ២,៨៣៨ | ២,៨៥៣ | +១៥ |
| បុគ្គលិកអប់រំសរុបស្រី | ១,២៤១ | ១,២៧៤ | +៣៣ |
| បុគ្គលិកបង្រៀនសរុប | ២,៣០០ | ២,៣៣២ | +៣២ |
| បុគ្គលិកបង្រៀនស្រី | ១,១៣៨ | ១,១៨៦ | +៤៨ |
| សិស្សអាហារូបករណ៍ | ៥,០៥០ | ៥,០៥០ | 0 |

**កម្មវិធីពន្លឿនការសិក្សា**

ថ្នាក់ពន្លឿនការសិក្សាបានអនុវត្តក្នុងស្រុកចំនួន ៤ គឺមាន ស្រុកទឹកឈូ ស្រុកអង្គរ. ជ័យ ស្រុកឈូក និងស្រុកជុំគីរី ដែលបានដំណើរការចំនួន១២ សាលា ដែលមាន ២៤ថ្នាក់ ( ថ្នាក់ទី១ ចំនួន ០៧ ថ្នាក់ ថ្នាក់ទី២ ចំនួន ០៨ ថ្នាក់ និងថ្នាក់ទី៣ចំនួន០៩ ថ្នាក់ ) ដែលមាន សិស្សសរុបចំនួន ៦៧៥ នាក់ ស្រី ២៥៩ នាក់ ។

ប្រកាសនេះ បានជួយសិស្សដែលលើសអាយុ រៀនស្របតាមកម្រិតថ្នាក់ និងត្រូវ អាយុ ។

**កម្មវិធីវិន័យបែបវិជ្ជមាន និងការគ្រងថ្នាក់ប្រកបដោយប្រសិទ្ធភាព**

កម្មវិធីវិន័យបែបវិជ្ជមាន បានបំប៉ននាយកសាលា និងគ្រូឈរថ្នាក់នឹងបានឱ្យអនុវត្ត ចំនួន ០៣ ស្រុក គឺ ស្រុកឈូក ស្រុកអង្គរជ័យ និងស្រុកកំពង់ត្រាច ។

ប្រកាសនេះជួយឱ្យសាលារៀននីមួយៗគ្មានអំពើហឹង្សា និងធានាឱ្យមានការអនុវត្ត សិទ្ធិកុមារបានពេញលេញទាំងក្នុងសាលារៀន និងក្នុងសហគមន៍ ។

**កម្មវិធីអប់រំបរិយាប័ន្នសម្រាប់កុមារពិការ**

ថ្នាក់អប់រំបញ្ជូលគ្នាបានអនុវត្តទៅលើទាំង ០៨ ក្រុងស្រុក សម្រាប់ជួយកុមារពិការ

នៅតាមមូលដ្ឋាន ។ តាមស្ថិតិឆ្នាំសិក្សា ២០១៧-២០១៨នេះ កុមារពិការដែលបានមកចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាទូទាំងខេត្តសរុបចំនួន ១,៦៥៩នាក់ ស្រី ៧១៦ នាក់

**ថ្នាក់សមាហរណកម្ម**

សម្រាប់ថ្នាក់សមាហរណកម្ម ( ថ្នាក់អប់រំពិសេស ) ដែលបង្រៀនកុមារពិការធ្ងន់ធ្ងរ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍមួយចំនួនដូចជា អេពិកអាត ម៉ារីណុល អង្គការ KPF មានដំណើរការ ០២ ក្រុង/ស្រុក ( ក្រុងកំពត និងស្រុកឈូក ) មានកុមារពិការសរុបចំនួន ១៣៣ នាក់ ស្រី ៥៣ នាក់ និងមានគ្រូថ្នាក់អប់រំពិសេសក្របខ័ណ្ឌរដ្ឋចំនួន ១០ នាក់ ស្រី ០៨ នាក់ និងបុគ្គលិកអង្គការដៃគូចំនួន ៧២នាក់ ស្រី ៤៧ នាក់ ។

**កម្មវិធីអាហារូបករណ៍**

ដោយអនុវត្តតាមអនុក្រឹតរបស់រាជរដ្ឋាភិបាល ស្តីពីការផ្តល់អាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា និងប្រកាសស្តីពីការកំណត់លក្ខខណ្ឌ និងនិតិវិធីនៃការផ្តល់អាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ។ តាមរយៈការអនុវត្តកម្មវិធីអាហារូបករណ៍បឋមសិក្សា ដែលគាំទ្រដោយថវិកាកម្មវិធី ( BP ) មានសិស្សបឋមសិក្សា ( ថ្នាក់ទី ៤ ទី ៥ និងទី ៦ ) ចំនួន ៥,០៥០ នាក់ ស្រី ២,៦៧៨ នាក់ ទទួលបានអាហារូបករណ៍ក្នុងឆ្នាំសិក្សា ២០១៧-២០១៨នេះ ។

ប្រកានេះ បានជួយបង្កើនលទ្ធភាពដល់កុមារដែលមកពីគ្រួសារក្រីក្រឱ្យបានចូលរៀន និងរៀនទៀងទាត់ ក្នុងន័យដើម្បីបង្កើនការចូលរៀន និងកាត់បន្ថយការបោះបង់ការសិក្សា ។

**សូចនាករ ធានាការអប់រំ មានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត**

| បរិយាយ | ឆ្នាំសិក្សា | | | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|
| | ២០១៦-២០១៧ | | ២០១៧-២០១៨ | | | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អត្រារួមចូលរៀនថ្មី | ១០៥.៥% | ១០២.១% | ១១២.២% | ១១០.៤% | +៦.៧% | +៨.៣% |
| អត្រាពិតចូលរៀនថ្មី | ៨៩.៨% | ៨៨.២% | ៩១.៣% | ៩១.៣% | +១.៥% | +៣.១% |
| អត្រារួមការសិក្សា | ៩៨.៩% | ៩៧.៧% | ១០០.៩% | ១០១.៥% | +២% | +៣.៨% |

| | | | | | | |
|---|---|---|---|---|---|---|
| អត្រាពិតការសិក្សា | ៨៧.០% | ៨៦.៩% | ៩៥.២% | ៩០.៦% | +៧.២% | +៣.៧% |

## ការប្រែប្រួលផ្នែកប្រសិទ្ធភាពផ្ទៃក្នុង

| **បរិយាយ** | **ឆ្នាំសិក្សា** | | | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|
| | **២០១៥-២០១៦** | | **២០១៦-២០១៧** | | | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អត្រាឡើងថ្នាក់ | ៩១.៦% | ៩៣.៤% | ៩២.០% | ៩៤.០% | +០.៤% | +០.៦% |
| អត្រាត្រួតថ្នាក់ | ៤.១% | ៣.០% | ៤.០% | ៣.០% | -០.១% | ០ |
| អត្រាបោះបង់ | ៤.២% | ៣.៦% | ៤.០% | ៣.០% | -០.២% | -០.៦% |
| | **២០១៦-២០១៧** | | **២០១៧-២០១៨** | | | |
| អត្រាបញ្ចប់បឋមសិក្សា | ៨៣.១% | ៨៤.៣% | ៧៥.០% | ៧៨.០% | - ៨.១% | - ៦.៣% |

- **លទ្ធផលនៃការសិក្សា**

| **បរិយាយ** | ២០១៥–២០១៦ | | ២០១៦–២០១៧ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សិស្សជាប់មធ្យមភាគ | ៩០.២% | ៩១.៩% | ៨៨.៦% | ៩០.៩% | - ១.៦% | - ១% |

- **បរិស្ថានសិក្សា**

| **បរិយាយ** | ឆ្នាំសិក្សា | | កើន (+)ថយ (-) | ផ្សេងៗ |
|---|---|---|---|---|
| | ២០១៦-២០១៧ | ២០១៧-២០១៨ | | |
| ចំនួនសាលាកុមារមេត្រី | ៨៥.៤% | ៧០.៣% | - ១៥.១% | |
| ផលធៀបគ្រូ/ថ្នាក់ | ០.៩៣ | ០.៩៥ | +០.០២ | |
| ផលធៀបសិស្ស/ថ្នាក់ | ៣៣.០ | ៣២.០ | -១.០ | |
| ផលធៀបថ្នាក់រៀន/បន្ទប់រៀន | ១.០ | ១.០ | ០ | |
| បណ្ណាល័យ | ២៦១ | ២៣៦ | - ២៥ | |

**បញ្ហាប្រឈមដែលទាក់ទងនឹងការទទួលសេវាអប់រំ**

## ការផ្តល់សេវាអប់រំ

- ការធ្វើបច្ចុប្បន្នភាពផែនទីខ្នងផ្ទះមិនទាន់បានអនុវត្តតាមយន្តការនៃការធ្វើបច្ចុប្បន្នភាពផែនទីខ្នងផ្ទះ ( សាលាភាគច្រើនមានផែនទីខ្នងផ្ទះ ប៉ុន្តែមិនទាន់មានបច្ចុប្បន្ន.ភាព ) ។
- តាមសាលារៀនបឋមសិក្សា និងការិយាល័យអប់រំក្រុង/ស្រុកមិនសូវបានយកចិត្តទុកដាក់លើសូចនាករអប់រំ ។
- សាលាមួយចំនួនតូច ជាពិសេសនៅតំបន់ជួបការលំបាក កង្វះគ្រូបង្រៀន បន្ទប់រៀន បង្គន់អនាម័យមិនទាន់ឆ្លើយតបទៅនឹងតម្រូវការ ។
- កុមារពិការមួយចំនួនមិនទាន់បានចូលរៀននៅអាយុ ៦ឆ្នាំនៅឡើយ ដោយអាណាព្យាបាលមួយចំនួនមិនទាន់យល់ពីការអប់រំបញ្ជូលគ្នា និងគ្រូមួយចំនួនធំ មិនទាន់មានជំនាញគ្រប់គ្រាន់ក្នុងការបង្រៀនកុមារពិការ ។
- កត្តាជីវភាពរបស់ប្រជាពលរដ្ឋ ក៏ជាមូលហេតុបណ្តាលឱ្យសិស្សមិនបានចូលរៀនត្រឹមត្រូវតាមអាយុដែរ ព្រោះត្រូវចំណាកស្រុកតាមឪពុកម្តាយ ឬ នៅជាមួយជីតា ជីដូនគ្មានអ្នកជូនមកសាលារៀន និងមករៀនមិនសូវទៀងទាត់ ។

## ការទទួលសេវាអប់រំ

- ដោយកត្តាគ្រួសារ និងសាលារៀន ពុំទាន់បានគាំទ្រពេញលេញដល់កុមារជួបការលំបាក ជាពិសេសកុមារពិការ និងកុមារមកពីគ្រួសារក្រីក្រ ឱ្យទទួលបានសេវាអប់រំល្អប្រសើរនៅឡើយ (ការយល់ដឹងរបស់គ្រួសារ បញ្ហាជីវភាព បរិស្ថានសាលារៀន និងជំនាញរបស់គ្រូលើការងារអប់រំបញ្ជូលគ្នា ) ។

## ២.៣-អនុវិស័យមធ្យមសិក្សា និងអប់រំបច្ចេកទេស

### ក- ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

### ការប្រែប្រួលស្ថានភាពហេដ្ឋារចនាសម្ព័ន្ធអប់រំ

| ល.រ | **បរិយាយ** | ២០១៦-២០១៧ | ២០១៧-២០១៨ | កើន(+)ថយ(-) |
|---|---|---|---|---|
| ១ | អគារ | ២៦៦ | ២៦៧ | + ០១ |
| ២ | បន្ទប់ | ១,៣៦៦ | ១,៣៧៦ | + ១០ |

## ការប្រែប្រួលស្ថានភាពបុគ្គលិកអប់រំ

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | កើន(+) | មធ្យមសិក្សាទុតិយភូមិ | | កើន(+) |
|---|---|---|---|---|---|---|
| | ២០១៦-២០១៧ | ២០១៧-២០១៨ | ថយ(-) | ២០១៦-២០១៧ | ២០១៧-២០១៨ | ថយ(-) |
| **បុគ្គលិកអប់រំសរុប** | | | | | | |
| សរុប | ២,៤៦៥ | ២,៤៨៤ | + ១៩ | ១,២៩០ | ១,៣៤១ | + ៥១ |
| ស្រី | ៩៣៧ | ៩៤៤ | + ៧ | ៤១០ | ៤៨៨ | + ៧៨ |
| **បុគ្គលិកបង្រៀន** | | | | | | |
| សរុប | ២,០៤៦ | ២,០៨២ | + ៣៦ | ១,១១៣ | ១,១៦៣ | + ៥០ |
| ស្រី | ៨៥៣ | ៨៥៨ | + ៥ | ៤៣១ | ៤៤៧ | + ១៦ |
| **បុគ្គលិកមិនបង្រៀន** | | | | | | |
| សរុប | ៤១៩ | ៤០២ | - ១៧ | ១៧៧ | ១៧៨ | + ១ |
| ស្រី | ៨៤ | ៨៦ | + ២ | ៣៩ | ៤១ | + ២ |

## ការប្រែប្រួល ស្ថានភាព ស្ថិតិ សាលា ថ្នាក់ និងសិស្ស

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | កើន(+) | មធ្យមសិក្សាទុតិយភូមិ | | កើន(+) |
|---|---|---|---|---|---|---|
| | ២០១៦-២០១៧ | ២០១៧-២០១៨ | ថយ(-) | ២០១៦-១៧ | ២០១៧-១៨ | ថយ(-) |
| សាលារៀន | ៩៧ | ៩៧ | ០ | ២២ | ២៣ | + ១ |
| ថ្នាក់រៀន | ៦៨០ | ៦៦៤ | - ១៦ | ៣២៤ | ៣៣៣ | + ៩ |
| សិស្សសរុប | ៣១,៣៥៣ | ៣០,១៩០ | - ១,១៦៣ | ១៤,៤០១ | ១៥,៦០០ | + ១,១៩៩ |
| ក្នុងនោះសិស្សស្រី | ១៥,០៧១ | ១៥,២៤៥ | + ១៧៤ | ៧,២០០ | ៧,៩៤៨ | + ៧៤៨ |

- កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ:

បានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រពីថ្នាក់ទី៧ ដល់ ថ្នាក់ទី៩ សរុបចំនួន ៤,៨១១ នាក់ ក្នុងនោះស្រី ២,៨៥៥ នាក់ នៅវិទ្យាល័យ និងអនុវិទ្យាល័យចំនួន ៥៤ សាលា ផ្តល់អាហារូបករណ៍មធ្យមសិក្សាទុតិយភូមិនៅតាមវិទ្យាល័យមានចំនួន ៦ សាលា សិស្សសរុប ៣៦០ នាក់ ស្រី ២១៨ នាក់ ។

ដោយឡែកគម្រោងមូលនិធិអភិវឌ្ឍន៍វិស័យអប់រំកម្ពុជា ( EDF ) បានផ្តល់អាហារូប. ករណ៍ដល់សិស្សក្រីក្រចំនួន២ស្រុកគឺស្រុកទឹកឈូ និងស្រុកឈូក អនុវិទ្យាល័យដែលមានសិស្សសរុប ៣៤៥ នាក់ ស្រី ១៩៥ នាក់ ។ ហើយបានផ្តល់ជាកង់ សំលៀកបំពាក់ និងសម្ភារសិក្សា ។

## សូចនាករ ធានាការអប់រំ មានគុណភាព ប្រកបដោយសមធម៌ និង បរិយាប័ន្ននិង លើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | កើន(+) | មធ្យមសិក្សាទុតិយភូមិ | | កើន(+) |
|---|---|---|---|---|---|---|
| | ២០១៦-២០១៧ | ២០១៧-២០១៨ | ថយ(-) | ២០១៦-២០១៧ | ២០១៧-២០១៨ | ថយ(-) |
| អត្រារួមនៃការសិក្សា | | | | | | |
| សរុប | ៦៣.៤% | ៦៣.០% | - ០.៤% | ២៩.៦% | ៣២.០% | + ២.៤% |
| ស្រី | ៦៥.២% | ៦៦.០% | + ០.៨% | ៣១.១% | ៣៤.០% | + ២.៩% |
| អត្រាឆ្លងភូមិសិក្សា | ( ២០១៥-១៦ ) | ( ២០១៦-១៧ ) | | ( ២០១៥-១៦ ) | ( ២០១៦-១៧ ) | |
| សរុប | ៨៨.៥% | ៨៨.០% | - ០.៥% | ៧៥.៩% | ៧៥.០% | - ០.៩% |
| ស្រី | ៩១.១% | ៩២.០% | + ០.៩% | ៨០.០% | ៧៩.០% | - ១.០% |

## ការប្រែប្រួលលើផ្នែកប្រសិទ្ធភាពផ្ទៃក្នុង

| **បរិយាយ** | មធ្យមសិក្សាបឋមភូមិ | | កើន(+) | មធ្យមសិក្សាទុតិយភូមិ | | កើន(+) |
|---|---|---|---|---|---|---|
| | ២០១៥-១៦ | ២០១៦-១៧ | ថយ(-) | ២០១៥-១៦ | ២០១៦-១៧ | ថយ(-) |
| ឡើងថ្នាក់ | | | | | | |
| សរុប | ៨២.៦% | ៨១.០% | - ១.៦% | ៧៧.៩% | ៨០.០% | + ២.១% |
| ស្រី | ៨៤.៥% | ៨៥.០% | + ០.៥% | ៨០.២% | ៨០.០% | - ០.២% |
| ត្រួតថ្នាក់ | | | | | | |
| សរុប | ២.០% | ៣.០% | + ១.០% | ២.៩% | ២.០% | - ០.៩% |
| ស្រី | ១.០% | ១.០% | ០ | ១.៩% | ២.០% | + ០.១% |

| | | | | | | |
|---|---|---|---|---|---|---|
| បោះបង់ | | | | | | |
| សរុប | ១៥.៤% | ១៦.០% | + ០.៦% | ១៩.២% | ១៩.០% | - ០.២% |
| ស្រី | ១៤.៥% | ១៤.០% | - ០.៥% | ១៧.៩% | ១៨.០% | + ០.១% |

**ការប្រែប្រួលលើផ្នែកគុណភាពនៃសេវាអប់រំ**

**ការលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅគ្រប់កម្រិត**

- ចុះជួយពង្រឹងសមត្ថភាពការដឹកនាំគ្រប់គ្រងរបស់នាយកសាលា

- បានណែនាំនាយកសាលា អោយធ្វើផែនការអភិវឌ្ឍន៍សាលារៀន ដោយមានការចូលរួមពីសហគមន៍ ។

- បានប្រជុំផ្សព្វផ្សាយអំពីគោលការណ៍នៃកម្មវិធីសិស្សអាហារូបករណ៍

- អោយសាលាដែលមានកម្មវិធីអាហារូបករណ៍ ចុះទៅតាមសាលាបឋមសិក្សាចំណុះដើម្បីណែនាំ និងជ្រើសរើសអាហារូបករណ៍សិស្សក្រីក្រនៅកម្រិតមធ្យមសិក្សា ។

- នៅតាមសាលាមធ្យមបានរៀបចំចាក់គ្រួស និង ធ្វើសួនច្បារ ដាំផ្កា ដាំដើមឈើយកម្លប់ ។

- បានដឹកនាំសិស្សអោយធ្វើពលកម្មសំអាតទីធ្លាសាលារៀនជាប្រចាំ

- សាលាមួយចំនួនបានធ្វើរបង ក្លោងទ្វារ បង់សម្រាប់អង្គុយ ដោយមានការចូលរួមពីសប្បុរសជននានា ដើម្បីអភិវឌ្ឍន៍សាលា ។

- ការគ្រប់គ្រងសាលាមធ្យមសិក្សាចំណោះទូទៅឯកជនៈក្នុងឆ្នាំសិក្សា ២០១៦-១៧ ខេត្តកំពតមានសាលាចំណោះទូទៅឯកជនចំនួន០៤សាលា ( វិទ្យាល័យ ០៣ និងអនុវិទ្យាល័យ០១ )ដែលមានសិស្សសរុបចំនួន ១,៥៤៤ នាក់ស្រី ៦៦១ នាក់ ។ សាលាឯកជនមួយចំនួនមិនបានអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំយុវជន និងកីឡាឲ្យបានត្រឹមត្រូវ ។ វឌ្ឍនភាពនៃសូចនាករផលសម្រេច ។

ការអប់រំនៅមធ្យមសិក្សា ត្រូវបានផ្គត់ផ្គង់ថវិកាដោយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈថវិកាតាមកម្មវិធី (PB ) , ថវិកា SIG និងមានការចូលរួមឧបត្ថម្ភគាំទ្រពីសប្បុរសជនអង្គការជាតិ អន្តរជាតិ បានធ្វើឲ្យគ្រឹះស្ថានមធ្យមសិក្សាមានការអភិវឌ្ឍគួរកត់សម្គាល់:

**ការកែលម្អបរិស្ថានសាលា**

- សាលាមធ្យមសិក្សាទាំងអស់បានកែលម្អបរិស្ថានឲ្យមានសោភ័ណ្ឌភាពល្អជាងឆ្នាំ

មុនៗ ដោយអនុវត្តទៅតាមកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សាបឋមភូមិ ។

**ការប្រែប្រួលលើផ្នែកគុណភាពនៃសេវាអប់រំ**

**លទ្ធផលនៃការសិក្សា**

- ម៉ោង និងកម្មវិធីសិក្សាចំពោះថ្នាក់ប្រឡង ទី៩ និងទី១២ សម្រេចបាន ១០០%លើគ្រប់មុខវិជ្ជា ឯថ្នាក់ទី៧ ,៨ ,១០ , ១១ អនុវត្តបានត្រឹមតែ ៩៥% ប៉ុណ្ណោះ ។

- គុណភាពនៃការបង្រៀននិងរៀនតាមមុខវិជ្ជានីមួយៗមានលក្ខណៈកាន់តែប្រសើរ អាស្រ័យដោយការយកចិត្តទុកដាក់របស់គ្រូ តាមមុខវិជ្ជាព្រមជាមួយ នឹងការប្រើប្រាស់សម្ភារឧបទ្ទេស ក្នុងការបង្រៀន និងការធ្វើអធិការកិច្ចរបស់នាយកសាលា ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក និងមន្ទីរ ។

- គ្រូបង្រៀន៨៥%បានធ្វើការងាររដ្ឋបាល និងកិច្ចតែងការបង្រៀនបានត្រឹមត្រូវ និងមានបទពិសោធន៍ក្នុងការបង្រៀនបានល្អប្រសើរប៉ុន្តែមានគ្រូបង្រៀនមួយចំនួនតូចមិនទាន់អនុវត្តបានល្អនៅឡើយ ។

-សិស្សដែលទទួលចំណាត់ថ្នាក់ការសិក្សាបានល្អភាគច្រើនជាសិស្សនារីដោយសារការព្យាយាមសិក្សា ធ្វើកិច្ចការដែលគ្រូដាក់អោយបានទៀងទាត់ ។

- ឆ្នាំសិក្សា ២០១៦-២០១៧ វិទ្យាល័យទាំងអស់បានបំប៉នសិស្សថ្នាក់ទី១២ ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិលើ៥មុខវិជ្ជាដោយមានការគាំទ្រថវិកាពីឯកឧត្តមបណ្ឌិត ប៉ែន ស៊ីម៉ន ទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាធិតីតេជោហ៊ុន សែននាយករដ្ឋមន្ត្រីនៃព្រះរា.ជាណាចក្រកម្ពុជា និងមានការចូលរួមពីសហភាព សហព័ន្ធយុវជនកម្ពុជាខេត្តកំពត ។

**លទ្ធផលនៃការសិក្សាឆ្នាំនេះបាន**

- លទ្ធផលល្អ: ១៧.០៨ %

- ល្អបង្គួរ: ៣៦.៦៦ %

- មធ្យម: ៣៨.៨៥ %

- ខ្សោយ: ៨.៥៩ %

លទ្ធផលទាំងនេះដោយ:

- សិស្សានុសិស្សបានយកចិត្តទុកដាក់ក្នុងការរៀនសូត្រ គោរពវិន័យបានល្អ ,គោរព

បទបញ្ជាផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

- សាលាខិតខំទប់ស្កាត់បានទាន់ពេលវេលា នូវក្មេងទំនើង ក្រុមបងធំ បងតូចគ្រឿងញៀននិងបានផ្សព្វផ្សាយនូវបទបញ្ញត្តិផ្សេងៗ ។

- ទប់ស្កាត់នូវបាតុភាពអវិជ្ជមានផ្សេងៗនៅពេលប្រឡងឆមាសក៏ដូចជាប្រឡងថ្នាក់ជាតិ ។

**លទ្ធផលប្រឡងសិស្សពូកែ**

ការប្រឡងជ្រើសរើសសិស្សពូថ្នាក់ខេត្តសម្រេចបានចំនួន ២៤ នាក់ ស្រី ០៩ នាក់ ក្នុងនោះ ថ្នាក់ទី១២ មានចំនួន ១២ នាក់ ស្រី ០៤ នាក់ ថ្នាក់ទី៩ មានចំនួន ១២ នាក់ ស្រី ០៥ នាក់ ។

លទ្ធផលប្រឡងសិស្សពូកែទូទាំងប្រទេសចំនួន ០២ នាក់ ស្រី ០១ នាក់ ក្នុងនោះមានសិស្សពូកែអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ និងថ្នាក់ទី៩ ចំនួន ០២ នាក់ ស្រី ០១ នាក់ ( វិ.ឯកជនឧត្តមវិជ្ជ ) បានជាប់ចំណាត់ថ្នាក់លេខ ៤ និង(អនុវិទ្យាល័យតេជោហាសម្រោម) ជាប់ចំណាត់ថ្នាក់លេខ ៧ ទូទាំងប្រទេសប្រទេស ។

**លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សា:**

| **បរិយាយ** | មធ្យមសិក្សាបឋមភូមិ | | កើន(+) | មធ្យមសិក្សាទុតិយភូមិ | | កើន(+) |
|---|---|---|---|---|---|---|
| | ២០១៥-១៦ | ២០១៦-១៧ | ថយ(-) | ២០១៥-១៦ | ២០១៦-១៧ | ថយ(-) |
| បេក្ខជនប្រឡងជាប់ | ៦,១៥២ | ៦,៧៥៤ | + ៦០២ | ២,៧០០ | ៣,៣៩៩ | + ៦៩៩ |
| ភាគរយ | ៩៣.៤៣ | ៩៣.៥៣ | + 0.១ | ៦១.១៩ | ៦៨.៨៣ | + ៧.៦៤ |
| ស្រី | ៣,១៣៩ | ៣,៥៤៥ | + ៤០៦ | ១,៣៦៣ | ១,៦៣៤ | + ២៧១ |
| ភាគរយ | ៩៦.០៨ | ៩៧.០៤ | +0.៩៦ | ៦៤.៩៦ | ៦៩.៨២ | + ៤.៨៦ |

ក្នុងលទ្ធផលខាងលើមាន:

- សិស្សអាហារូបករណ៍បានប្រឡងជាប់មធ្យមសិក្សាបឋមភូមិចំនួន ១,៣៣៥ នាក់ ស្រី ៨១៥ នាក់ ស្មើនឹង ៩៣.០៩% (ធៀបនឹងឆ្នាំមុន ៨៧.៨៣% ) ។

- សាលាមធ្យមសិក្សាចំណោះទូទៅឯកជន

- មធ្យមសិក្សាបឋមភូមិជាប់សរុប: ១៤៦ នាក់ ស្រី ៥០ នាក់

- មធ្យមសិក្សាទុតិយភូមិជាប់សរុបៈ២៦១ នាក់ ស្រី ១១២ នាក់

- សាលារៀន ៨២%បានអនុវត្តការបង្រៀនទៅតាមគោលវិធីសិស្សមជ្ឈមណ្ឌលនៅមានសាលាចំនួនតិចដែលមិនទាន់បានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានល្អ ។

- វិទ្យាល័យចំនួនពីរដែលអនុវត្តគម្រោងការប្រែប្រួលអាកាសធាតុក្នុងវិស័យអប់រំ វិទ្យាល័យសម្តេចជាស៊ីមអង្គរជ័យ និង វិទ្យាល័យព្រះបិតាជាតិ ដែលបានចាប់អនុវត្តក្នុងឆ្នាំសិក្សា ២០១៦-២០១៧ ដែលមានរយៈពេល៣ឆ្នាំ ។

- វិទ្យាល័យចំនួនពីរទៀតបានពង្រីកខ្លួនទៅជាវិទ្យាល័យចំណេះទូទៅ និងបច្ចេក. ទេសវិទ្យាល័យព្រះរាជសម្ភារ ជំនាញអគ្គិសនី និង វិទ្យាល័យនរោត្តមសីហមុនី ជំនាញក្សេត្រសាស្រ្តក្នុងឆ្នាំសិក្សា២០១៧-២០១៨ នេះទៅ ។

- សាលាមួយចំនួនបានអនុវត្តសកម្មភាពបំណិនជីវិតតាមមូលដ្ឋានដោយដឹកនាំសិស្សអោយដាំស្ពៃត្រកួនចិញ្ចឹមសត្វ និង ធ្វើស្រូវនៅរដូវវស្សា ឯសាលាមួយចំនួនបានបង្រៀនសិស្សត្រឹមតែទ្រឹស្តី (មិនទាន់មានឯកសារគ្រប់គ្រាន់)។

- សកម្មភាពកីឡាៈបានហាត់រៀនជាប្រចាំនិងរៀបចំក្រុមកីឡាសិស្សប្រកួតជាលក្ខណៈសាលា ថ្នាក់ស្រុក ថ្នាក់ខេត្ត និងទូទាំងប្រទេស ។

- សកម្មភាពគេហវិជ្ជៈ បានដំណើរការតែទ្រឹស្តី ដោយសារសាលាមួយចំនួនខ្វះសម្ភារ ខ្វះគ្រូឯកទេសឯសាលាដែលមានម៉ាស៊ីនដេរក៏អនុវត្តពុំបានគ្រប់គ្រាន់ដែរ ដោយសារម៉ាស៊ីនដេរខូច ។

- ការបង្រៀនកុំព្យូទ័រៈសាលាដែលបានអនុវត្តជាប្រចាំមានវិ.ព្រះរាជសម្ភារ,វិ.ព្រះ. ន.រណប្ញទ្ធិ,វិ.អង្គសុរភី,វិ.ព្រះនរោត្តមសីហមុនី វិទ្យាល័យហ៊ុន សែនឈូក និងអនុវិទ្យា. ល័យហ៊ុន សែនជុំគ្រៀល សាលាមួយចំនួនបានប្រើប្រាស់ត្រឹមតែការងាររដ្ឋបាល ហើយសាលាមួយចំនួនធំពុំមានកុំព្យូទ័រប្រើប្រាស់ ។

- ការងារបណ្ណាល័យៈ មានដំណើរការល្អ ដោយមានសិស្សចូលអាន ស្រាវជ្រាវជាប្រចាំ ប៉ុន្តែសាលាមួយចំនួនខ្វះបន្ទប់សម្រាប់បណ្ណាល័យបានប្រើប្រាស់បណ្ណាល័យចល័តក្រៅថ្នាក់ ។

- ការងារពិសោធន៍ៈ បានអនុវត្តនៅវិទ្យាល័យព្រះរាជសម្ភារ វិ.ហាសឈូក វិ.នរោត្ត. សីហមុនី ជាប្រចាំ ឯសាលាដ៏ទៃ ទៀតបានអនុវត្តត្រឹមតែពិសោធន៍ងាយៗ ។

- ការងារអធិការកិច្ចៈ នាយកសាលារៀនបានអធិការកិច្ចជាប្រចាំទៅលើគ្រូបង្រៀន

- ការប្រជុំក្រុមបច្ចេកទេសៈ បានប្រជុំជារៀងរាល់ខែនៅតាមសាលារៀន ដោយមានប្រធានបទច្បាស់លាស់ និងមានការចូលរួមពីគណៈគ្រប់គ្រងសាលា ។

- ការអនុវត្តលិខិតបទដ្ឋាននានាៈ បានផ្សព្វផ្សាយ និង ដាក់ឲ្យអនុវត្តនូវលិខិតបទដ្ឋាននានារបស់ក្រសួងក៏ដូចជាលិខិតរបស់អាជ្ញាធរដែនដី ឱ្យមានប្រសិទ្ធភាព ប៉ុន្តែសាលាថ្មី អនុវត្តពុំទាន់បានល្អនៅឡើយ ដោយសារនាយកថ្មីមិនទាន់យល់ច្បាស់ ។

- ការចូលរួមរបស់សហគមន៍ៈ បានចូលរួមជួយអភិវឌ្ឍន៍សាលារៀនតាមរយៈការចូលរួមជួយធ្វើផែនការអភិវឌ្ឍន៍សាលារៀន បានគៀងគរសប្បុរសជននានាអោយជួយជួសជុល និងសាងសង់អគារសិក្សា របង ក្លោងទ្វារ ។ ល។

- សាលារៀនបានចូលរួមជួយសហគមន៍ៈ សាលារៀននៅតាមទីប្រជុំជន ក៏ដូចជានៅតាមជនបទបានចូលរួមក្នុងកម្មវិធីផ្សេងៗដែលសហគមន៍ត្រូវការ។ ជាពិសេសនៅតាមជនបទបានចុះជួយច្រូតស្រូវប្រជាពលរដ្ឋ និងធ្វើពលកម្មផ្សេងៗ ។

**ការដកសាច់ប្រាក់ៈ**

- ថវិកាគាំទ្រសាលាៈ
- ថវិកាសមាមាត្រ
- ថវិកាអគារធនធាន
- ថវិការង្វាន់សិស្សពូកែ
- ថវិកាប្រឡងសិស្សពូកែថ្នាក់ខេត្ត
- ថវិកាសិស្សអាហារូបករណ៍
- ថវិកាតាមដានរបស់ស្រុក/ក្រុង
- ថវិកាតាមដានរបស់ការិយាល័យមធ្យមសិក្សា
- ថវិកាតាមដានរបស់គណៈកម្មការទ្រទ្រង់សិស្សអាហារូបករណ៍

**បញ្ហាប្រឈមៈ**

**ក.ការទទួលសេវាអប់រំ**

ក្រោយពីបញ្ចប់ភូមិសិក្សាសិស្សមួយចំនួនមិនបានទទួលនូវសេវាអប់រំកម្រិតមូលដ្ឋានដោយសារៈ

- មិនមានមធ្យោបាយធ្វើដំណើរ (សាលារៀននៅឆ្ងាយពីផ្ទះ)

- សិស្សមួយចំនួនទៅរកការងារធ្វើនៅតាមរោងចក្រ ទៅរកការងារធ្វើនៅក្នុង និង ក្រៅប្រទេស ។

- ជួយធ្វើការងារបង្កបង្កើនផលឪពុកម្តាយ

- ជីវភាពខ្វះខាតគ្មានលទ្ធភាពបន្តការសិក្សា

- គ្រួសារចំណាកស្រុកទៅស៊ីឈ្នួលឱ្យគេ

- គ្រួសារមានអំពើហឹង្សា

- អាណាព្យាបាលមួយចំនួនពុំយកចិត្តទុកដាក់តាមដានការសិក្សារបស់កូន

- សិស្សមួយចំនួនមិនមានសមត្ថភាពបន្តការសិក្សា

**ខ. គុណភាពនិងប្រសិទ្ធភាពនៃការបង្រៀន និងរៀន:**

- កង្វះគ្រូនៅគ្រឹះស្ថានមធ្យមសិក្សាជាច្រើននៅតាមជនបទ

- គ្រូនៅតាមទីប្រជុំជនមានចំនួនលើស ការបំពេញភារកិច្ចមិនទាន់បានល្អ និងគាបសង្កត់សិស្សទៅតាមវិធីផ្សេងៗដើម្បីផលប្រយោជន៍របស់ខ្លួនដោយខ្វះមនសិការវិជ្ជាជីវៈ ។

- កង្វះបន្ទប់សិក្សានៅតាមសាលាអនុវិទ្យាល័យជនបទ

- ការបែងចែកសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំមិនទាន់បានទៅតាមតម្រូវការសាលា និង មិនបានបើកវគ្គតម្រង់ទិសលើខ្លឹមសារមេរៀនថ្មី ។

- ការងារគ្រប់គ្រងរបស់នាយកសាលាមួយចំនួនតូចនៅមានកម្រិត ជាពិសេសនាយកដែលទើបតែងតាំងថ្មី

- ការទប់ស្កាត់បាតុភាពអវិជ្ជមានមួយចំនួនមិនបានទាន់ពេលវេលា

- ការប្រើប្រាស់ថវិកាPB និងថវិកាSIG មិនទាន់បានចំមុខសញ្ញា

- សាលាមួយចំនួនដែលបានបង្កើតហើយចំនួន ៣ឆ្នាំ មិនទាន់មានបន្ទប់សិក្សាគ្រប់គ្រាន់ ។

- ខ្វះគ្រូតាមមុខវិជ្ជាឯកទេស នៅមធ្យមសិក្សាទុតិយភូមិ និង បឋមភូមិ

**២-៤- អនុវិស័យអប់រំក្រៅប្រព័ន្ធ**

**ក-ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱ.ភាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

កម្មវិធីអប់រំក្រៅប្រព័ន្ធត្រូវបានគ្របដណ្តប់គ្រប់ក្រុង/ស្រុកទាំង៨ របស់ខេត្តរួមមាន៖ ការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ -កម្មវិធីក្រោយអក្ខរកម្ម - កម្មវិធីចូលរៀនឡើងវិញកម្មវិធី

សមមូល(បំពេញវិជ្ជា) កម្មវិធីបង្កើនប្រាក់ចំណូល(តាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍) ដោយប្រើប្រាស់ថវិកាតាមកម្មវិធី (PB ) របស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធរួមមាន ៖

**ក-១- អក្ខរកម្មវិជ្ជាជីវៈ**

គ្រូអក្ខរកម្មជាប់កិច្ចសន្យាចំនួន ៤០ នាក់ ស្រី ១២ នាក់ ត្រូវបាន បង្រៀនថ្នាក់អក្ខរ.កម្ម ៤០ ថ្នាក់ មានអ្នកចូលរៀនសរុប ៨០៣ នាក់ ស្រី ៦៣៥ នាក់ បានបញ្ចប់ ៧២៥ នាក់ ស្រី ៥៧៩ នាក់ប្រៀបធៀបឆ្នាំកន្លងមកកើនឡើង ៨.៣១% ស្រី កើន ២.៩៣% ( ឆ្នាំ២០១៦ មានតែ ៣៩ ថ្នាក់ គ្រូម្នាក់ស្លាប់ ឆ្នាំ២០១៧ មាន ៤០ ថ្នាក់ ) ។

**ក-២-កម្មវិធីចូលរៀនឡើងវិញ**

គ្រូកម្មវិធីចូលរៀនឡើងវិញត្រូវបានជ្រើសរើសចេញពីគ្រូបង្រៀនកម្រិតបឋមសិក្សាក្នុងប្រព័ន្ធចំនួន ១៩ នាក់ ស្រី ៥ នាក់ ដោយបានបើកឱ្យដំណើរការថ្នាក់បំប៉នក្នុងវិស្សម.កាលបានចំនួន១៩ ថ្នាក់ មានសិស្សចូលរៀនសរុប ៣១៣ នាក់ ស្រី ១៥៦ នាក់ និងបានបញ្ជូនចូលសាលាក្នុងប្រព័ន្ធវិញ ២៨០ នាក់ ស្មើ ៨៩.៤៥% ស្រី ១៤៧ នាក់ ស្មើ ៩៥.៤៥% ប្រៀបធៀបឆ្នាំកន្លងមកថយចុះ ៥.០៨% ស្រី កើន ១០.១៥% ។

**ក-៣-មជ្ឈមណ្ឌលសិក្សាសហគមន៍** ( CLC )

មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ២៣ ម.ស.សស្មើនិង៤៦បន្ទប់ មានគណៈគ្រប់គ្រងសរុប១១៥ នាក់ ស្រី ២៣ នាក់ និងគ្រូជំនាញសរុប ៩១ នាក់ ស្រី ៣០ នាក់ បានដំណើរការរៀននិងបង្រៀនរយៈពេល៦ខែ ។

ក្នុងជំនាញនីមួយៗ មានអ្នកចូលរៀនសរុប ៥៥៩ នាក់ ស្រី ៤៣០ នាក់ ។

មុខជំនាញដែលបានបណ្តុះបណ្តាលរួមមាន កាត់ដេរ កាត់សក់ កែសម្ផស្ស តម្បាញភ្លេងប្រពៃណី ភ្លេងពិណពាទ្យ កសិកម្ម កុំព្យូទ័រ អ៊ុតសក់ ។

សិស្សបញ្ចប់សរុបចំនួន ៤៦០ នាក់ ស្រី ៣៥៨ នាក់ប្រៀបធៀបឆ្នាំកន្លងមកកើន៤៣.៨៧% ស្រីកើន៤៤.៦០% (ឆ្នាំ២០១៦ បង្រៀនមិនបានចប់គ្រប់មុខជំនាញ បង្រៀនរយៈពេល ២ខែ ខ្វះថវិកា ឆ្នាំនេះបង្រៀនចប់គ្រប់មុខជំនាញ ) ។

**ក-៤-កម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ**

- កម្មវិធីសមមូលបឋមសិក្សាមានគ្រូកិច្ចសន្យា១៥នាក់ ស្រី ៤ នាក់ បានបើកបង្រៀនថ្នាក់ឆ្នាំទី១ + ២ បានចំនួន១៥ ថ្នាក់ មានសិស្សចូលរៀនសរុប ២៦៣នាក់ ស្រី១៥៥ នាក់សិស្សរៀនបញ្ចប់ថ្នាក់សរុបចំនួន ២៤៣ នាក់ស្រី ១៤៨ នាក់ ។

- មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជាចំនួន ១ ថ្នាក់ គ្រូសរុប ១០ នាក់ស្រី៣ នាក់ មានអ្នកចូលរៀនសរុប ១២៤ នាក់ ស្រី ៣១ នាក់ បានប្រឡងជាប់សរុប ៧១ នាក់ស្រី ១៤ នាក់ ប្រៀបធៀបឆ្នាំកន្លងមកកើន៤០ នាក់ស្មើ៥៦.៣៣ % ស្រីថយ២ នាក់ ស្មើ ១២.៥០ % ។

- សិស្សបំពេញវិជ្ជាស្វៃរិន សរុប ១២ នាក់ ស្រី ២ នាក់ ប្រឡងជាប់ ៥ នាក់ ស្រី ២ នាក់ ។

**ក-៥-កម្មវិធីក្រោយអក្ខរកម្ម**

មានបណ្ណាល័យមួយកន្លែង មានបណ្ណារក្ស ១ នាក់ ស្រី ០ នាក់បានបើកឱ្យដំណើរការជាប្រចាំ មានអ្នកចូលអាន និងខ្ចីសៀវភៅសរុប ៦០ នាក់ ស្រី ៤០ នាក់ ក្នុងមួយថ្ងៃ ។

**ខ-ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

គោលនយោបាយទី២ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំផ្តោតជាសំខាន់ការលើក កម្ពស់គុណភាពអប់រំ និងប្រសិទ្ធភាព ឆ្លើយតបជាមួយគ្នានេះដែរ កម្មវិធីអប់រំក្រៅប្រព័ន្ធបានយកចិត្តទុកដាក់ពិនិត្យបរិមាណ និងភាគរយអ្នកដែលបានបញ្ចប់ការសិក្សា ក្នុងកម្មវិធីផ្សេងៗគ្នា ។

**ខ-១- អក្ខរកម្មវិជ្ជាជីវៈ**

របាយការណ៍បង្ហាញថា អ្នកដែលបានបញ្ចប់ទាំងអស់មានចំនួន ៧២៥ នាក់ ស្មើ ៨៧.៣៤% ស្រី ៥៧៩ នាក់ ស្មើ ៨៧.៩៩% បានបញ្ចប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈមានន័យថា អ្នកបញ្ចប់កម្មវិធីភាគច្រើនជាស្ត្រី ។

| លរ | ឈ្មោះក្រុង /ស្រុក | ចំនួនថ្នាក់ | ចំនួនគ្រូ | | ចំនួនអ្នកចូលរៀន | | បានបញ្ចប់ | | | | ផលធៀបសិស្សគ្រូ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | % | ស្រី | % | |
| ១ | អង្គរជ័យ | ៥ | ៥ | ៣ | ១១០ | ៩៣ | ១១០ | ១០០ | ៩៣ | ១០០ | ២២ |
| ២ | បន្ទាយមាស | ៦ | ៦ | ២ | ១២២ | ១០៧ | ១២១ | ៨៨ | ១០៦ | ៩៩ | ២០ |
| ៣ | ឈូក | ៦ | ៦ | ១ | ១២០ | ៩៤ | ៩៣ | ៧៨ | ៧៨ | ៨៣ | ២០ |
| ៤ | ជុំគីរី | ៥ | ៥ | ០ | ៩១ | ៧៦ | ៨៥ | ៩៣ | ៧៤ | ៩៧ | ១៨ |
| ៥ | ដងទង់ | ៥ | ៥ | ០ | ១០១ | ៨៥ | ៩៥ | ៩៤ | ៨០ | ៩៤ | ២០ |
| ៦ | កំពង់ត្រាច | ៥ | ៥ | ១ | ៨៨ | ៧០ | ៨៨ | ១០០ | ៧០ | ១០០ | ១៧ |
| ៧ | ទឹកឈូ | ៦ | ៦ | ៣ | ១៣៦ | ៧៦ | ១១៣ | ៨៣ | ៥៨ | ៧៦ | ២២ |
| ៨ | ក្រុងកំពត | ២ | ២ | ២ | ៣៥ | ៣៤ | ២០ | ៥៧ | ២០ | ៥៩ | ១៧ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សរុប | ៤០ | ៤០ | ១២ | ៨០៣ | ៦៣៥ | ៧២៥ | ៩០ | ៥៧៩ | ៩១ | ២០ |

លទ្ធផលធៀបឆ្នាំកន្លងទៅមានការកើនឡើង ៨.៥៩ % ស្រី កើន ២.៦៧% ដោយ ឆ្នាំ ២០១៦ មាន ៣៩ ថ្នាក់ ឆ្នាំនេះ ៤០ ថ្នាក់ ។

**ខ-២-កម្មវិធីចូលរៀនឡើងវិញ (Re-entry )**

ក្នុងកម្មវិធីនេះត្រូវបានសម្រឹតសម្រាំងមុខសញ្ញាតាមរយៈផ្តល់លទ្ធផលពីដំណាក់កាលគឺៈ សិស្សរៀនចប់កម្មវិធី និងសិស្សបានបញ្ជូនចូលសាលាក្នុងប្រព័ន្ធវិញ។ ក្នុងករណីសមត្ថភាពសិស្សបំប៉ននោះមិនប្រែប្រួលត្រូវបញ្ជូនត្រួតថ្នាក់( ឧ.សិស្សបំប៉នថ្នាក់ទី៤ បញ្ជូនចូលសាលាក្នុងប្រព័ន្ធវិញថ្នាក់ទី៤ដដែល ) ។

| លរ | ឈ្មោះក្រុង/ស្រុក | ចំនួនថ្នាក់ | ចំនួនគ្រូ | | ចំនួនអ្នកចូលរៀន | | សិស្សបញ្ជូន | | សិស្សបញ្ជូនត្រួត | | ផលធៀបគ្រូសិស្ស |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| ១ | ទឹកឈូ | ១ | ១ | ១ | ២០ | ៩ | ១៥ | ៩ | ៥ | ០ | ២០ |
| ២ | កំពង់ត្រាច | ២ | ២ | ០ | ៣០ | ១១ | ២៨ | ១០ | ២ | ១ | ១៥ |
| ៣ | បន្ទាយមាស | ១ | ១ | ១ | ១៧ | ៦ | ១៧ | ៦ | ០ | ០ | ១៧ |
| ៤ | ដងទង់ | ២ | ២ | ០ | ៣២ | ១៨ | ៣២ | ១៨ | ០ | ០ | ១៦ |
| ៥ | ឈូក | ៧ | ៧ | ១ | ១០៥ | ៤៨ | ១០១ | ៤៨ | ៤ | ០ | ១៥ |
| ៦ | ជុំគីរី | ៦ | ៦ | ២ | ១០៩ | ៦៤ | ៨៧ | ៥៤ | ២២ | ១០ | ១៨ |
| សរុប | | ១៩ | ១៩ | ៥ | ៣១៣ | ១៥៦ | ២៨០ | ១៤៥ | ៣៣ | ១១ | ១៦ |

លទ្ធផលបញ្ជាក់ថាសិស្សដែលបានរៀនចប់ ២៨០ នាក់ ស្រី ១៤៥ នាក់បានបញ្ជូនចូលរៀនសាលាក្នុងប្រព័ន្ធវិញ ប្រឡងឡើងថ្នាក់ (៤.៥.៦.៧ )សរុប ២៨០នាក់ ស្មើនឹង ៨៩.៤៥ % ស្រី ១៤៥ នាក់ ស្មើនឹង ៩២.២៤% នៃសិស្សចូលរៀន ។

**ខ-៣-កម្មវិធីសមមូល អប់រំក្រៅប្រព័ន្ធ**

**ខ.៣.១.កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ**

ប្រមូលសិស្សដែលបានបញ្ចប់ថ្នាក់អក្ខរកម្ម និងសិស្សក្រៅសាលាឱ្យចូលរៀនថ្នាក់ឆ្នាំទី១និងថ្នាក់ឆ្នាំទី២ ដូចខាងក្រោមៈ

| លរ | ឈ្មោះក្រុង/ស្រុក | ចំនួនថ្នាក់ | ថ្នាក់ឆ្នាំទី១ | | ថ្នាក់ឆ្នាំទី២ | | សិស្សបញ្ចប់ឆ្នាំទី២ | | ផលធៀបសិស្សគ្រូ |
|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| ១ | ក្រុងកំពត | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ២ | ទឹកឈូ | ២ | ២៥ | ២០ | ២៥ | ១៧ | ១៧ | ១៥ | ២៥ |
| ៣ | កំពង់ត្រាច | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៤ | បន្ទាយមាស | ១ | ០ | ០ | ១៥ | ៩ | ១៥ | ៩ | ១៥ |
| ៥ | អង្គរជ័យ | ៣ | ១៥ | ៦ | ៣២ | ២៦ | ៣១ | ២៥ | ១៦ |
| ៦ | ដងទង់ | ១ | ០ | ០ | ២០ | ១២ | ២០ | ១២ | ២០ |
| ៧ | ឈូក | ២ | ១៦ | ៤ | ១៦ | ៤ | ១៦ | ៤ | ១៦ |
| ៨ | ជុំគីរី | ៦ | ៥០ | ១៩ | ៤៩ | ៣៨ | ៤៤ | ៣៦ | ១៧ |
| សរុប | | ១៥ | ១០៦ | ៤៩ | ១៥៧ | ១០៦ | ១៤៤ | ១០១ | ១ |

តាមរយៈតារាងលទ្ធផលខាងលើបង្ហាញថា ថ្នាក់កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធអនុវត្តបានដូចខាងក្រោម ៖

- ថ្នាក់ឆ្នាំទី១ មានចំនួនថ្នាក់ ៦ថ្នាក់សិស្សចូលរៀនសរុប ១០៦ នាក់ ស្រី ៤៩ នាក់
- សិស្សបានរៀនចប់ឆ្នាំទី១សរុបចំនួន ៩៩ នាក់ ស្មើនឹង៩៣.៣៩ % ស្រី ៤៧ នាក់ ស្មើនឹង ៩៥.៩១% ។
- ថ្នាក់ឆ្នាំទី២ មានចំនួនថ្នាក់ ៩ថ្នាក់សិស្សចូលរៀនសរុប១៥៧ នាក់ ស្រី ១០៦ នាក់
- សិស្សបានរៀនចប់ឆ្នាំទី២សរុបចំនួន ១៤៤ នាក់ស្មើនឹង ៩១.៧១% ស្រី ១០១នាក់ ស្មើនឹង៩៥.២៨% នៃអ្នកចូលរៀន ។

**ខ-៣-២-ថ្នាក់បំពេញវិជ្ជា**

មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជាថ្នាក់ទី១២

| លរ | ឈ្មោះក្រុង/ស្រុក | សិស្សចូលរៀន | | សិស្សដាក់ពាក្យប្រឡង | | បេក្ខជនមកប្រឡង | | ប្រឡងជាប់ | |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ក្រុងកំពត | ១២៤ | ៣១ | ១១៥ | ២៨ | ១១៥ | ២៨ | ៧១ | ១៤ |

| សរុប | ១២៤ | ៣១ | ១១៥ | ២៨ | ១១៥ | ២៨ | ៧១ | ១៤ |
|---|---|---|---|---|---|---|---|---|

ប្រៀបធៀបឆ្នាំកន្លងមកកើនឡើង ៥៥ នាក់ ស្មើនឹង ៨៤.៣៥% ស្រី ៨ នាក់ស្មើនឹង ២៥.៨០ % សិស្សស្វែរិនបំពេញវិជ្ជាដាក់ពាក្យប្រឡង ១២ នាក់ ស្រី ២ នាក់ ប្រឡងជាប់ ៥ នាក់ ស្រី ២ នាក់ ។

## ២-៤ -មជ្ឈមណ្ឌលសិក្សាសហគមន៍

ក្នុងចំណោមមជ្ឈមណ្ឌលកសិក្សាសហគមន៍ ២៣ កន្លែងដែលបានដំណើរការមានអ្នកចូលរៀនសរុបចំនួន ៥៤៧ នាក់ ស្មើនឹង ៩៧.៨៥% ស្រី ៤២៦ នាក់ ស្មើនឹង៩៩.០៦% ដែលបានបញ្ចប់ជំនាញមុខរបរ ខ្នាតតូច ដើម្បីស្វែងរកការងារ និង បង្កើនជីវភាពរស់នៅរបស់ខ្លួនឱ្យកាន់តែប្រសើរឡើងមួយកម្រិតថែមទៀត ។

| លរ | ឈ្មោះក្រុង/ស្រុក | ចំនួន ម.ស.ស | ចំនួនមុខជំនាញ | ចំនួនគ្រូជំនាញ | | អ្នកចូលរៀន | | បានបញ្ចប់ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | សរុប | ស្រី | សរុប | % | ស្រី | % | |
| ១ | ក្រុងកំពត | ២ | ៣ | ៤ | ៣ | ៥៥ | ៣២ | ៥៤ | ៩៣ | ៣៤ | ១០០ | |
| ២ | ទឹកឈូ | ៣ | ៣ | ៥ | ៥ | ៦៣ | ៦៣ | ៥៣ | ១០០ | ៥៣ | ១០០ | |
| ៣ | កំពង់ត្រាច | ៣ | ២ | ៦ | ៦ | ១០៦ | ១០៤ | ៨៣ | ១០០ | ៨៣ | ១០០ | |
| ៤ | បន្ទាយមាស | ៣ | ៤ | ៦ | ៤ | ៦៦ | ៤៧ | ៥៥ | ១០០ | ៣៩ | ១០០ | |
| ៥ | អង្គរជ័យ | ២ | ៤ | ៤ | ២ | ៤១ | ២២ | ៣៧ | ១០០ | ១៩ | ១០០ | |
| ៦ | ដងទង់ | ៣ | ៣ | ៦ | ៣ | ៦៤ | ៤៣ | ៥៥ | ៩៧ | ៤០ | ៩៥ | |
| ៧ | ឈូក | ៣ | ២ | ៥ | ៥ | ៦៤ | ៦៣ | ៥៦ | ៩៧ | ៤៥ | ៩៧ | |
| ៨ | ជុំគីរី | ៣ | ៣ | ៥ | ២ | ១០០ | ៥៦ | ៦៧ | ៩៦ | ៣៦ | ១០០ | |
| សរុប | | ២២ | ២៤ | ៤១ | ៣០ | ៥៥៩ | ៤៣០ | ៤៦០ | ៩៨ | ៣៥៨ | ៩៩ | |

គ-ធានាភាពស័ក្តសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីនៅគ្រប់លំដាប់ថ្នាក់

| លរ | ខ្លឹមសារ | រយៈពេល | ទីកន្លែង | ចំនួនអ្នកចូលរួម | | សមាសភាពអ្នកចូលរួម |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ១ | បំប៉នគ្រូអក្ខរកម្មកិច្ចសន្យា | ៧ថ្ងៃ | សាលប្រជុំមន្ទីរអប់រំ | ១៤ | ៦ | គ្រូកិច្ចសន្យា |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | បំប៉នគ្រូកម្មវិធីចូលរៀនឡើងវិញ | ៣ថ្ងៃ | ស្រុកបន្ទាយមាស | ១៩ | ៥ | គ្រូបឋមសិក្សាក្នុងប្រព័ន្ធ |
| ៣ | តម្រង់ទិសគ្រូបង្កើនប្រាក់ចំណូល | ៣ថ្ងៃ | ស្រុកឈូក | ៤១ | ៣០ | គ្រូកិច្ចសន្យា |
| សរុប | | | | ៧៤ | ៤១ | |

លទ្ធផលបង្ហាញថាក្នុងឆ្នាំ ២០១៧ ចំនួនអ្នកចូលរួមអនុវត្តការងារអប់រំក្រៅប្រព័ន្ធ ៧៤ នាក់ ស្រី ៤១ នាក់ ទទួលបានចំណេះដឹងតាមរយៈវគ្គបំប៉ន ដើម្បីបង្កើនប្រសិទ្ធភាពការងារ ។

## ២.៥ អនុវិស័យអភិវឌ្ឍយុវជន

### ក-ការរៀបចំក្រុមប្រឹក្សាយុវជន- កុមារៈ

**ក១-ការងារក្រុមប្រឹក្សាយុវជន**

យើងមានក្រុមប្រឹក្សាយុវជន នៅតាមមធ្យមសិក្សាទុតិយភូមិទូទាំងខេត្តចំនួន ២២ ក្រុមប្រឹក្សា ៖

- មាន ៣២៦ សាខា និង ១,៩៣៤ អនុសាខា
- មានសមាជិកសរុប ១៣,៦២៥ នាក់ ស្រី ៦,៩០២ នាក់

**ក២- ការងារក្រុមប្រឹក្សាកុមារៈ**

រៀបចំក្រុមប្រឹក្សាកុមារ នៅតាមគ្រឹះស្ថានមធ្យមសិក្សា និង បឋមសិក្សាទូទាំងខេត្ត មានចំនួន ៤០៤ ក្រុមប្រឹក្សា ដែលចែកចេញជា ២ ផ្នែក ជាផលទ្ធផលយើងមាន ៖

**ផ្នែក ៖ អនុវិទ្យាល័យ និង វិទ្យាល័យ**

- រៀបចំក្រុមប្រឹក្សាកុមារនៅតាមបណ្តាអនុវិទ្យាល័យ មានចំនួន ៩៧ ក្រុមប្រឹក្សា ក្នុងនោះ (៧៧ ក្រុមប្រឹក្សា ស្ថិតនៅក្នុងអនុវិទ្យាល័យដាច់ដោយឡែក ចំណែក ២០ ក្រុមប្រឹក្សាទៀតគឺស្ថិតក្នុង វិទ្យាល័យ )មាន ៦៧៤ សាខា និង ៤,២១២ អនុសាខាមានសមាជិកសរុប ៣៧,៤០៦ នាក់ ស្រី ១៨,៤៦២ នាក់ ។

**ផ្នែក បឋមសិក្សា**

- រៀបចំក្រុមប្រឹក្សាកុមារនៅតាមបណ្តាសាលាបឋមសិក្សាមានចំនួន ៣០៧ ក្រុមប្រឹក្សា មាន១,១៧២ សាខា និង៦,៥០០ អនុសាខា មានសមាជិកសរុប ៣៧,៤០៦ នាក់

ស្រី ១៨,៤៦២ នាក់ ។

**ខ-សកម្មភាពយុវជន និង កុមារ**

**ខ១-សកម្មភាព យុវជន និង កុមារ**

- បានចុះជួយរៀបចំ និង ពង្រឹងរចនាសម្ពន្ធ័ក្រុមប្រឹក្សាយុវជន-កុមារ និងផ្សព្វផ្សាយការងារ ចលនា ប្រលងប្រណាំងពល្អ របស់យុវជន-កុមារតាមបណ្ដុគ្រឹះស្ថានសិក្សា តាមបណ្ដុស្រុក បានចំនួន ១៧ លើក ស្មើ ៥១ សាលាបឋមសិក្សា។

- បានសហការជាមួយសាខាកាបាទក្រហមកម្ពុជាខេត្តកំពតបើកវគ្គបណ្ដុះបណ្ដាលយុវជន កាកបាទ ក្រហមតាមស្រុកចំនួន៤ គឺះស្រុកទឹកឈូ,ឈូក,ជុំគីរី និង ស្រុកអង្គរជ័យ បានចំនួន៨ វគ្គ មាន យុវជនជា សិស្សានុសិស្ស ចូលរួម សរុប ៩៥៣ នាក់ ។

- បានបញ្ជូនមន្ត្រីជំនាញចំនួន ៣ នាក់ទៅចូលរួមសិក្ខាសាលាពិនិត្យឡើងវិញនូវផែនការ និង ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ ២០១៨-២០២០ សម្រាប់អនុវិស័យការអភិវឌ្ឍយុវជននៅក្រសួងអប់រំ យុវជន និងកីឡា (រាជធានីភ្នំពេញ)។

- បានបើកវគ្គបំប៉នការយល់ដឹង និងផ្សព្វផ្សាយ ស្តីពីការអប់រំបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ដល់យុវជនក្រៅសាលា បានចំនួន៥ វគ្គ នៅស្រុកឈូក ជុំគីរី ដងទង់ បន្ទាយមាស និង ស្រុកអង្គរជ័យ មានយុវជនចូលរួមសរុប ២៥០ នាក់ ស្រី ១៥២ នាក់ ។

- បានបើកវគ្គបំប៉ន ស្តីពី ការពង្រឹងក្រុមប្រឹក្សាយុវជន-កុមារ ថ្នាក់សាលារៀន ចំនួន ៣ វគ្គ នៅស្រុក ដងទង់,ជុំគីរី និង ស្រុកអង្គរជ័យ មានសមាជិកចូលរួមសរុប ១១១ នាក់ ស្រី ២៦ នាក់ ។

- បានប្រារព្ធទិវាអន្តរជាតិសម្រាប់យុវជន ១២ សីហា ២០១៧ មានយុវជនចូលរួមសរុប ៩៥០ នាក់ ស្រី ២១៥ នាក់ ។

- បានសហការមួយសាខាកាកបាទក្រហមកម្ពុជាខេត្តកំពតចុះផ្សព្វផ្សាយការប្រឡងគំនូរកុមារ កាកបាទក្រហមដើម្បីអបអរសាទរទិវាកាកបាទក្រហម ចំនួន២២សាលា

មានក្រុងស្រុកចូលរួមចំនួន ៥ ក្នុងនោះ ក្រុងកំពត ស្រុកកំពង់ត្រាច ទឹកឈូ ឈូក និង ស្រុកបន្ទាយមាស មានកុមារចូលរួមសរុប ១៥៤ នាក់ ។

**ខ២-កាងារបោះជុំរំ និងទស្សនះកិច្ចសិក្សា**

- បានបញ្ជូនប្រតិភូយុវជននិងថ្នាក់ដឹកនាំសរុប ៣១ នាក់ ស្រី ១២ នាក់ ទៅចូលរួមបោះជុំរំ និង ទស្សនៈកិច្ចសិក្សា ថ្នាក់ជាតិ បានចំនួន ៣លើក នៅខេត្តឧត្តរមានជ័យ សៀមរាប និងខេត្តកោះកុង ។

**ខ៣-ការងារកាយរឹទ្ធិ**

- បានផ្សព្វផ្សាយពីគោលការណ៍ និងសហលក្ខន្តិកៈរបស់កាយរឹទ្ធិជាតិកម្ពុជា ដល់ស្នងការ មេកង ឯកភាព និងប្អូនៗសមាជិកកាយរឹទ្ធិជាតិកម្ពុជាថ្នាក់ខេត្ត ក្រុង/ស្រុក ។

- ឆ្នាំ ២០១៦ បានបំផុសជ្រើសរើសយុវជន-កុមារ បញ្ចូលជាសមាជិកកាយរឹទ្ធិជាតិកម្ពុជា តាមបណ្ដា ក្រុង/ស្រុក សរុបចំនួន៤,៩២០ នាក់ ស្រី ២,១៧៦ នាក់ ។

- បានចូលរួមធ្វើសកម្មភាពសង្គមនឹងធ្វើអំពើល្អដែលជាកាតព្វកិច្ចរបស់កាយរឹទ្ធិ ដូចជា៖ ដកស្មូង ច្រូតកាត់ ជួសជុល និង សាងសង់ផ្ទះជូនប្រជាពលរដ្ឋទីទាល់ក្រ ស្ត្រីម៉េម៉ាយដែលខ្វះ កម្លាំងពលកម្ម មិន ត្រឹមតែប៉ុណ្ណោះបានចូលរួមគ្រប់សកម្មភាពសង្គម ។

**ការងារមជ្ឈមណ្ឌលយុវជន**

- ចាក់ដីបំពេញទីធ្លាមជ្ឈមណ្ឌលយុវជន បាន ២ ជុំគឺ៖ ជុំទី៣ និង ជុំទី៤ ចំនួន ១៥០ រថយន្ត ស្មើនិង ៩០០ម៉ែត្រគូប ។

- បានបញ្ជូនប្រតិភូយុវជនក្រៅសាលា និងថ្នាក់ដឹកនាំ ចំនួន០៧ នាក់ ស្រី ០៣ នាក់ ទៅចូលរួម កម្មវិធី ទស្សនកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធន៍លើការងារស្មគ្រ័ចិត្ត និង ស្វែងយល់ពីការថែរក្សា មរតក វប្បធម ខ្មែរ នៅខេត្តសៀមរាប ។

- បានបើកវគ្គជំនាញខ្លី កាត់ដេរ ដល់យុវជនស្ម័គ្រចិត្ត ក្រុង/ស្រុក

**លទ្ធផលធៀបទៅនឹងទិសដៅឆ្នាំសិក្សាកន្លងមក**

**ការអនុវត្តថវិកាតាមកម្មវិធីសកម្មភាព PB-២០១៧**

- បានរៀបចំ និងពង្រឹងការងារក្រុមប្រឹក្សាយុវជន-កុមារនៅតាមបណ្តុគ្រឹះស្ថាន មធ្យមសិក្សា និង បឋម សិក្សា ក្នុងទូទាំងខេត្តកំពត សម្រេចបានលទ្ធផល ១០០ % ។

- បានបើកវគ្គអប់រំផ្សព្វផ្សាយជំងឺអេដស៍ដល់យុវជនក្រៅសាលាបានលទ្ធផលធៀប និង ទិសដៅក្នុង ឆ្នាំសិក្សាកន្លងទៅ ១០០ % ។

- វគ្គបំប៉នការងារអភិវឌ្ឍន៍ក្រុមប្រឹក្សា យុវជន-កុមារ បានលទ្ធផលធៀបនិងទិសដៅក្នុងឆ្នាំសិក្សា កន្លងទៅ ១០០ % ។

- ចុះពិនិត្យតាមដានទទួលបានលទ្ធផលធៀបនិងទិសដៅក្នុងឆ្នាំសិក្សាកន្លងទៅ ១០០ % ។

- បានវគ្គបណ្តុះបណ្តាល និងជំនាញខ្លីៗដល់យុវជនស្ម័គ្រចិត្តក្រុង/ ស្រុកសម្រេចលទ្ធផល បាន ១០០% ។

- បានចូលរួមជួបជុំយុវជនស្ម័គ្រចិត្ត ក្នុងដំណើរទស្សនៈកិច្ចសិក្សាថ្នាក់ជាតិ សម្រេចលទ្ធផល តាម ផែនការ ១០០ % ។

- បានចុះពង្រឹងការងារយុវជនស្មគ្រ័ចិត្ត នៅក្រុង/ស្រុកគោលដៅដែលបានបើកវគ្គរួច សម្រេចបាន លទ្ធផល ១០០ % ។

- បានចាក់ដីបំពេញទីធ្លាមជ្ឈមណ្ឌលយុវជនសម្រេចបានលទ្ធផល៥០%នៃគម្រោងថវិកា ប្រចាំឆ្នាំ ។

**២.៦-អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា**

-បានរៀបចំប្រកួតកីឡាបាល់ទាត់ពានរង្វាន់អបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៨ ទិវាជ័យជំនះ ៧ មករា ១៩៧៩ - ៧មករា ២០១៧ ដែលមាន ក្រុមកីឡាចូលរួម ប្រកួតចំនួន១០ក្រុមធ្វើការប្រកួតវិលជុំមានរយៈពេល១៥ថ្ងៃឧបត្ថម្ភដោយ **ឯកឧត្តម ចាន់ ចេស្តា** អភិបាលនៃគណៈអភិបាល ខេត្តកំពត មន្ទីរជុំវិញខេត្តនិងសប្បុរសជន ពាណិជ្ជករ អាជីវករ ដែលមានទីតាំងនៅក្នុងខេត្ត ។

-បានរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកទូទាំងខេត្ត ប្រចាំឆ្នាំសិក្សា២០១៦- ២០១៧ រយៈពេល ០៥ ថ្ងៃ ដែលមានក្រុមកីឡា ចូលរួមចំនួន ០៨ ក្រុង-ស្រុក មានកីឡាករសរុបចំនួន ៥៩៤ នាក់ ស្រី ២៦៤ នាក់។

-បានរៀបចំការប្រកួតកីឡាសិស្សមធ្យមសិក្សាជ្រើសរើសជើងឯកទូទាំងខេត្ត ប្រចាំឆ្នាំសិក្សា២០១៦- ២០១៧ រយៈពេល ០៥ ថ្ងៃ ដែលមានក្រុមកីឡា ចូលរួមចំនួន ០៨ ក្រុង-ស្រុក មានកីឡាករសរុបចំនួន៦៩៥នាក់ ស្រី ២៦៤ នាក់។

-បានរៀបចំធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាបាល់ទាត់ ពានរង្វាន់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** លើកទី ១១ ប្រចាំឆ្នាំ ២០១៧ ទទួលភ្ញៀវខេត្តត្បូងឃ្មុំ ជើងទី១ លទ្ធផលបច្ចេកទេសយកឈ្នះខេត្តត្បូងឃ្មុំ ៤-១ ។

-បានដឹកនាំកីឡាបាល់ទាត់មួយក្រុមចំនួន ៣០ នាក់ចូលរួមប្រកួតពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** វគ្គ១/៨ នៅខេត្តត្បូងឃ្មុំលទ្ធផលបច្ចេកទេសយកឈ្នះខេត្តត្បូងឃ្មុំ៤-១ ។

-បានដឹកនាំកីឡាបាល់ទាត់មួយក្រុមចំនួន ៣០នាក់ ចូលរួមប្រកួតពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** វគ្គ១/៨ នៅស្តាតចាស់ រាជធានីភ្នំពេញ ឈ្នះយុវជនក្រសួងការពារជាតិលទ្ធផល ១ ទល់នឹង ០ ។

- បានរៀបចំធ្វើជាម្ចាស់ផ្ទះការប្រកួតពាន់រង្វាន់សម្តេចអគ្គមហាសេនាបតីជោ ហ៊ុន សែន ជើងទី២ ទទួលភ្ញៀវយុវជនក្រសួងការពារជាតិ ខេត្តកំពតយកឈ្នះ ៤ ទល់នឹង ០ ។

-បានដឹកនាំកីឡាបាល់ទាត់មួយក្រុមចំនួន៣០នាក់ចូលរួមប្រកួតពានរង្វាន់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជើងទី២ វគ្គ១/៨ នៅខេត្តស្វាយរៀង ។

-បានដឹកនាំកីឡាប៉េតង់ទៅចូលរួមប្រកួតជ្រើសរើសជើងឯកពានរង្វាន់ សម្តេច ក្រឡាហោម **ស ខេង** លើកទី ១៧ នៅ រាជធានីភ្នំពេញ មានរយៈពេល០៥ថ្ងៃ ទទួលបានចំណាត់ថ្នាក់លេខ ៣ ពានសមាគម ។

-បានដឹកនាំកីឡាសិស្សមធ្យមសិក្សាទៅចូលរួមប្រកួតកីឡាជ្រើសរើសជើងឯកទូទាំងប្រទេសប្រចាំឆ្នាំសិក្សា ២០១៦-២០១៧ រយៈពេល១០ថ្ងៃ នៅខេត្តកំពង់ចាម មានកីឡា បាល់ទាត់,បាលទះ,បាល់បោះ,អត្តពលកម្ម, កូនឃ្លីលើតុ, ប៉េតង់ មានកីឡា ចំនួន

១០៨នាក់,ស្រី៥២នាក់, គ្រូដឹកនាំចំនួន២៨នាក់ លទ្ធផលបច្ចេកទេស វិញ្ញាសា អត្តពលកម្ម ចោលដុំដែក(នារី) ទទួលបានមេដាយប្រាក់ ,ចោលថាស(នារី) បានមេដាយ ប្រាក់,រត់ចម្ងាយ៣គីឡូម៉ែត្រ(នារី)ទទួលបានមេដាយសំរិទ្ធ,រត់ចម្ងាយ ៥គីឡូម៉ែត្រ ( បុរស )បាន ទទួលមេដាយសំរិទ្ធ។វិញ្ញាសាបាល់បោះ(បុរស) ទទួលបានបានមេដាយសំរិទ្ធ,និងវិញ្ញាសាបាល់ទះ(នារី)ទទួលបានមេដាយមាស០៥ឆ្នាំជាប់ៗគ្នា ។

-បានដឹកនាំកីឡាសិស្សបឋមសិក្សា កីឡាបាល់ទះ(កុមារា-កុមារី),បាល់ទាត់(កុមារា-កុមារី)និងអត្តពលកម្ម(កុមារា-កុមារី) ទៅចូលរួមប្រកួតជ្រើសរើសជើងឯកទូទាំងប្រទេសប្រចាំឆ្នាំសិក្សា២០១៦- ២០១៧ រយៈពេល០៧ថ្ងៃ នៅរាជធានីភ្នំពេញលទ្ធផលបច្ចេកទេស វិញ្ញាសាអត្តពលកម្ម ៥០ម៉ែត្រ*៤ ទទួលបានមេដាយមាស អត្តពលកម្មក្រុម ទទួលបានមេដាយប្រាក់ និងបាល់ទះ ( កុមារា-កុមារី ) ទទួលបានមេដាយមាស ឈលំដាប់ ថ្នាក់ទូទាំងប្រទេសចំណាត់ថ្នាក់១ ។

-បានបញ្ជូនគ្រូជំនាញ ០១ នាក់ ផ្នែកបាល់បោះទៅបណ្តុះបណ្តាលនៅរាជធានីភ្នំពេញ រយៈពេលចំនួន០៥ថ្ងៃ ។

-បានបញ្ជូនគ្រូជំនាញគ្រូ០៣នាក់ផ្នែកអត្តពលកម្មទៅចូលរួមបណ្តុះបណ្តាល នៅខេត្តកំពង់ឆ្នាំង រយៈពេល០៥ថ្ងៃ ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧។

-បានបញ្ជូនគ្រូជំនាញ០១នាក់ផ្នែកបាល់ទះទៅបណ្តុះបណ្តាលនៅខេត្តពោធិ៍សាត់ រយៈពេល០៥ថ្ងៃ ។

-បានបញ្ជូនគ្រូជំនាញ០១នាក់ផ្នែកបាល់ទាត់ទៅបណ្តុះបណ្តាលនៅរាជធានីភ្នំពេញ ផ្នែកវាយតម្លៃអាជ្ញាកណ្តាល ។

-បានបញ្ជូនគ្រូជំនាញ ០១ នាក់ ផ្នែកទាញព្រ័ត្រទៅបណ្តុះបណ្តាលនៅ រាជធានីភ្នំពេញ រយៈពេល០៦ថ្ងៃ ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី១២ ខែ កុម្ភៈ ឆ្នាំ២០១៧។

-បានទទួលធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាបាល់ទាត់ ពានរង្វាន់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** រវាងខេត្តកំពតប្រកួតជាមួយខេត្តស្វាយរៀង ។

-បានដឹកនាំកីឡាករ-ការនីទាញព្រ័ត្រចំនួន២០នាក់ទៅចូលរួមប្រកួតជ្រើសរើសជើងឯកថ្នាក់ជាតិប្រចាំឆ្នាំ២០១៧ រយៈពេល ០៦ថ្ងៃ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ លទ្ធផលបច្ចេកទេស (បុរស)បានមេដាយប្រាក់

(នារី)បានចំណាត់ថ្នាក់លេខ៤ ។

-បានបញ្ជូនគ្រូជំនាញ០១នាក់ផ្នែកបាល់បោះកម្រិតមូលដ្ឋានទៅចូលរួមវគ្គបណ្តុះ. បណ្តាលនៅរាជធានីភ្នំពេញ រយះពេលចំនួន០៧ថ្ងៃ ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០១៧ ។

-បានបញ្ជូនគ្រូជំនាញ០១នាក់ផ្នែកបាល់ទាត់ទៅចូលរួមវគ្គវាយតម្លៃអាជ្ញាកណ្តាល រយះពេល០៧ថ្ងៃ ពីថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៧ នៅរាជធានី ភ្នំពេញ ។

-បានដឹកនាំកីឡាប៉េតង់ទៅចូលរួមប្រកួតថ្នាក់ជាតិនៅរាជធានីភ្នំពេញចំនួន០៥ថ្ងៃ។

-បានដឹកនាំកីឡាទាញព្រ័ត្រ(បុរស-នារី)ចូលរួមប្រកួតតំបន់ឆ្នេរពានរង្វាន់ភូមិភាគ និរតីលើកទី១ ឆ្នាំ២០១៧ លទ្ធផលបច្ចេកទេសមេដាយមាស(បុរស) មេដាយមាស(នារី)។

-បានទទួលធ្វើជាម្ចាស់ផ្ទះពិធីបើកការប្រកួតកីឡាបាល់ទាត់ យុវជនអាយុក្រោម ១៤ ឆ្នាំ និងយុវជនក្រោមអាយុ ១៦ឆ្នាំ និងបាល់ទាត់នារី ។

-បានបញ្ជូនគ្រូ០២នាក់ ទៅបណ្តុះបណ្តាលផ្នែកកីឡាទ្រីយ៉ាត្លុង នៅ រាជធានី ភ្នំពេញ រយះពេល ០៥ថ្ងៃ ចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ ។

-បានរៀបចំការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកទូទាំងខេត្ត ប្រចាំឆ្នាំ២០១៧ ក្រុមកីឡាចូលរួមប្រកួតមានកីឡាបាល់ទាត់មានចំនួន១០ក្រុម,កីឡាបាល់បោះមានចំនួន ០៦ក្រុម, និងប៉េតង់(ប៊ូល) មានចំនួន ១៦ក្រុម ។

-បានដឹកនាំកីឡាប្រដាល់ទៅចូលរួមប្រកួតជ្រើសរើសជើងឯកទូទាំងប្រទេសនៅ ខេត្តកណ្តាល រយះពេល០៧ថ្ងៃ ចាប់ពីថ្ងៃទី២៦ ខែវិច្ឆកា ដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ លទ្ធផលបច្ចេកទេសទទួលបាន មេដាយសំរិទ្ធ ចំនួន០៣នាក់ ក្នុងទម្ងន់៥២គីឡូ,ទម្ងន់ ៦០គីឡូ,ទម្ងន់៦៤គីឡូ ។

-បានដឹកនាំកីឡាបាល់ទះ(បុរស-នារី)ចំនួន០៣ក្រុមទៅចូលរួមប្រកួតពិធីបុណ្យ សមុទ្រនៅខេត្តកែប លទ្ធផលបច្ចេកទេសទទួលបាន(នារី)បានមេដាយមាស(បុរស)បាន មេដាយសំរិទ្ធ ។

**III- វឌ្ឍនភាពនៃសូចនាករផលសម្រេចតាមអនុវិស័យ** ( **ឧបសម្ព័ន្ធទី៤** )

**១ អនុវិស័យអប់រំកុមារតូច**

| | ការអប់រំកុមារតូច | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ស្ថានភាព |
|---|---|---|---|---|---|

| | | ២០១៦-១៧ | ២០១៧-១៨ | ២០១៧-១៨ | |
|---|---|---|---|---|---|
| **គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា** | | | | | |
| ១ | ភាគរយកុមារអាយុ ៥ ឆ្នាំបានចូលរៀន | ៥៥.៩% | ៦១.០% | ៦២.០% | ↑ |
| ២ | ភាគរយកុមារអាយុ ៤ ឆ្នាំបានចូលរៀន | ២៥.៥% | ៣០.០% | ៣១.០% | ↑ |
| ៣ | ភាគរយកុមារអាយុ ៣ ឆ្នាំបានចូលរៀន | ១៧.៥% | ២០.០% | ២១.០% | ↑ |
| ៤ | ភាគរយសេវាអប់រំកុមារតូចគោរពតាមស្តង់ដាគុណភាព | 0% | ៣% | 0% | ↓ |
| ៥ | ភាគរយសេវាអប់រំកុមារតូចអនុវត្តតេស្តទៀងទាត់ | ១៣% | ៥0% | ៧0.៣៥% | ↑ |
| ៦ | ភាគរយកុមារក្នុងគាំពារ និងអភិវឌ្ឍកុមារតូចដែលមានស្ថានភាពអាហារូបត្ថម្ភ | 0% | ៥% | 0% | ↓ |
| ៧ | ភាគរយកុមារនៅសាលាមត្តេយ្យសិក្សាសាធារណៈទទួលបានថ្នាំទម្លាក់ព្រូន | ៩0% | ៩៥% | ៩0% | ↓ |

## ២- អនុវិស័យបឋមសិក្សា

| | ការអប់រំបឋមសិក្សា | ជាក់ស្តែង ២០១៦-១៧ | ចំណុចដៅ ២០១៧-១៨ | ជាក់ស្តែង ២០១៧-១៨ | ស្ថានភាព |
|---|---|---|---|---|---|
| **គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា** | | | | | |
| ១ | ភាគរយសាលាកុមារមេត្រី កម្រិតមធ្យម និង | ៨៥.៤% | ៨៥.៨% | ៧0.៣% | ↓ |

| | | | | | |
|---|---|---|---|---|---|
| | កម្រិតអភិវឌ្ឍ | | | | |
| ២ | អត្រាពិតចូលរៀនថ្មី | ៨៩.៨% | ៩០.២% | ៩១.៣% | ↑ |
| | អត្រាពិតចូលរៀនថ្មី ( ស្រី ) | ៨៨.២% | ៩០.២% | ៩១.៣% | ↑ |
| ៣ | អត្រាពិតនៃការសិក្សា | ៨៧.០% | ៨៩.៥% | ៩៤.០% | ↑ |
| | អត្រាពិតនៃការសិក្សា ( ស្រី ) | ៨៦.៩% | ៨៩.៥% | ៩០.៦% | ↑ |
| ៤ | អត្រាបោះបង់ការសិក្សា | ៤.២០% (២០១៥-១៦) | ៣.៩% | ៤.០% | → |
| | អត្រាបោះបង់ការសិក្សា ( ស្រី ) | ៣.៦០% (២០១៥-១៦) | ៣.៥% | ៣.០% | ↑ |
| ៥ | អត្រាត្រួតថ្នាក់ | ៤.១០% (២០១៥-១៦) | ៣.៨% | ៤.០% | → |
| | អត្រាត្រួតថ្នាក់ ( ស្រី ) | ៣.០% (២០១៥-១៦) | ៣.០% | ៣.០% | ↑ |
| ៦ | អត្រាបញ្ចប់ការសិក្សា | ៨៣.១០% | ៨៤.៨% | ៧៥.០% | ↓ |
| | អត្រាបញ្ចប់ការសិក្សា ស្រី ) | ៨៤.៣០% | ៨៥.៧% | ៧៨.០% | ↓ |
| ៧ | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | ៨៩.០% (២០១៥-១៦) | ៨៩.៧៥% | ៨៨.០% | → |
| | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យម | ៩១.០% | ៩១.៥% | ៩២.០% | ↑ |

| | | | | | |
|---|---|---|---|---|---|
| | សិក្សាបឋមភូមិ ( ស្រី ) | (២០១៥-១៦) | | | |

**៣-អនុវិស័យមធ្យមសិក្សា និងអប់រំបច្ចេកទេស**

| | ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ជាក់ស្តែង ២០១៦-១៧ | ចំណុចដៅ ២០១៧-១៨ | ជាក់ស្តែង ២០១៧-១៨ | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា | | | | | |
| ១ | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ១៥.៤% (២០១៥-១៦) | ១២% | ១៦% | ↓ |
| | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ( ស្រី ) | ១៤.៥% (២០១៥-១៦) | ១២% | ១៤% | → |
| ២ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៦៣.៤% | ៦៥.៤% | ៦៣% | → |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ( ស្រី ) | ៦៥.២% | ៦៧% | ៦៦% | → |
| ៣ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | ២៩.៦% | ៣១.៦% | ៣២% | ↑ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ( ស្រី ) | ៣១.១% | ៣២% | ៣៤% | ↑ |
| ៤ | អត្រាឆ្លងភូមិសិក្សាពីបឋមភូមិទៅទុតិយភូមិ | ៧៥.៩% | ៧៧.៥០% | ៧៥% | → |
| | អត្រាឆ្លងភូមិសិក្សាពីបឋមភូមិទៅទុតិយភូមិ ( ស្រី ) | ៨០.០% | ៨២% | ៧៩% | → |
| ៥ | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៥០.៤០% | ៥២% | ៥២% | ↑ |

| | | | | | |
|---|---|---|---|---|---|
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ( ស្រី ) | ៥២.៥០% | ៥៣.៥០% | ៥៥% | ↑ |
| ៦ | ភាគរយសិស្សមធ្យមសិក្សាបឋមភូមិទទួលអាហារូបករណ៍ | ១៧% | ១៧% | ១៧% | ↑ |
| ៧ | ចំនួនគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រី | ១០០% | ១០០% | ១០០% | ↑ |
| ៨ | ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | 0 | ២ | ២ | ↑ |
| ៩ | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | 0 | ១០០ | ១០០ | ↑ |
| | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស (ស្រី) | 0 | ៤០ | ៣៨ | → |

### ៤-អនុវិស័យអប់រំក្រៅប្រព័ន្ធ

| | ការអប់រំក្រៅប្រព័ន្ធ | ជាក់ស្តែង ២០១៦-១៧ | ចំណុចដៅ ២០១៧-១៨ | ជាក់ស្តែង ២០១៧-១៨ | ស្ថានភាព |
|---|---|---|---|---|---|
| **គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា** | | | | | |
| ១ | អត្រាអក្ខរកម្មមនុស្សពេញវ័យអាយុចាប់ពី ១៥-៤៥ ឆ្នាំ | ៨៩.៨៤% | ៩៤.៧៥% | ៩៤.៧៥% | ↑ |
| ២ | ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | ៦៨០ | ៧២០ | ៧២៥ | ↑ |
| ៣ | ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ | ៥៤៧ | ៥៤៧ | ៥៤៧ | ↑ |
| ៤ | ចំនួនកុមារដែលបានបញ្ចប់កម្មវិធីចូល | ២៨០ | ២៨០ | ២៨០ | ↑ |

| | | | | | |
|---|---|---|---|---|---|
| | រៀនឡើងវិញ និងបានបញ្ចូលទៅក្នុងប្រព័ន្ធ | | | | |
| ៥ | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | ២៧៥ | ៣៥៦ | ៣៦២ | ↑ |
| ៦ | រាជធានី ខេត្តរៀបចំបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | ១ | ១ | ១ | ↑ |
| ៧ | ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ | ២៣ | ២៣ | ២៥ | ↑ |

**៥-អនុវិស័យការអភិវឌ្ឍយុវជន**

| | ការអភិវឌ្ឍយុវជន | ជាក់ស្តែង ២០១៦-១៧ | ចំណុចដៅ ២០១៧-១៨ | ជាក់ស្តែង ២០១៧-១៨ | ស្ថានភាព |
|---|---|---|---|---|---|
| **គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា** | | | | | |
| ១ | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ | ១៥ | ១៥ | ១៥ | ↑ |
| ២ | ចំនួនយុវជនដែលបានទទួលការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងសហគ្រិនភាព | ២០ | ៥០ | ០ | ↓ |
| ៣ | ចំនួនយុវជនដែលបានបង្កើតការងារដោយខ្លួនឯងក្នុងមួយមជ្ឈមណ្ឌលក្នុងមួយឆ្នាំ | ២ | ៤ | ៤ | ↑ |
| ៤ | ចំនួនយុវជនដែលទទួលការបណ្តុះបណ្តាលពីការងារស្ម័គ្រចិត្ត | ៥០ | ៥០ | ៥០ | ↑ |
| ៥ | ចំនួនមជ្ឈមណ្ឌលយុវជន | ១ | ១ | ១ | ↑ |
| ៦ | ភាគរយសិស្សថ្នាក់ទី៤-៩ចូលរួមក្នុងក្រុម | ១០០% | ១០០% | ១០០% | ↑ |

| | | | | | |
|---|---|---|---|---|---|
| | ប្រឹក្សាកុមារ | | | | |
| ៧ | ភាគរយសិស្សថ្នាក់ទី១០-១២ចូលរួមក្នុងក្រុមប្រឹក្សាយុវជន | ១០០% | ១០០% | ១០០% | ↑ |

**៦-អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា**

| | ការអប់រំកាយ និងកីឡា | ជាក់ស្តែង ២០១៦-១៧ | ចំណុចដៅ ២០១៧-១៨ | ជាក់ស្តែង ២០១៧-១៨ | ស្ថានភាព |
|---|---|---|---|---|---|
| ១ | ចំនួនគ្រូអប់រំកាយ និងកីឡាបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ០ | ៦ | ០ | ↓ |
| ២ | គ្រឹះស្ថានមធ្យមសិក្សាចំនួន ១០មានទីលានបាលទាត់ ១៥ មានទីលានបាល់បោះ និង ២០ មានទីលានបាល់ទះ | ១៥<br>១១<br>២៣៥ | ១៧<br>១៤<br>២៤៥ | ១៦<br>១៣<br>២៤០ | ↓ |
| ៣ | ចំនួនមេដាយមាសក្នុងការប្រកួតកីឡាស៊ីហ្គេម | មាស៩<br>ប្រាក់ ៩<br>សំរិទ្ធ ១២ | ១២<br>១១<br>១៤ | ១២<br>១៥<br>១៨ | ↑ |

IV- **បញ្ហាប្រឈម**

**១ អនុវិស័យអប់រំកុមារតូច**

- ការប្រមូលកុមារចូលរៀនគ្រប់សេវានៅមិនទាន់ឆ្លើយតបនឹងចំណុចដៅ

- ការចូលរួមរបស់សហគមន៍លើកម្មវិធីមត្តេយ្យសិក្សាសហគមន៍ និងអប់រំកុមារតូចតាមផ្ទះនៅមិនឆ្លើយតបនឹងតម្រូវការជាក់ស្តែង ។

- មិនទាន់មានសមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលគ្រប់លំដាប់ថ្នាក់ ។

- ការប្រមូល និងបញ្ជូនទិន្នន័យមានការយឺតយ៉ាវ

**២- អនុវិស័យបឋមសិក្សា**

- សមាសភាពក្រុម DTMTs ថ្មីពុំទាន់បានឆ្លងកាត់ការបណ្តុះបណ្តាល យន្តការនៃការអនុវត្តរបស់ក្រុម DTMTs និងការិយាល័យជំនាញមិនមានការសហការល្អនៅឡើយ និងមិនមានថវិកាសម្រាប់គាំទ្រ និងដំណើរការប្រតិបត្តិរបស់ក្រុម DTMTs ។
- ខ្វះសៀវភៅសិក្សាគោលសម្រាប់អនុវត្តកម្មវិធីថ្នាក់ពន្លឿនការសិក្សា និងមិនមានប្រាក់ឧបត្ថម្ភសម្រាប់គ្រូដែលបង្រៀនថ្នាក់ពន្លឿនការសិក្សា ។
- កង្វះថវិកាសម្រាប់ការពង្រឹងដំណើការប្រតិបត្តិរបស់កម្រងសាលារៀន
- សាលារៀនមួយចំនួននៅតំបន់ជួបការលំបាក កង្វះខាតគ្រូ បន្ទប់រៀន បង្គន់អនាម័យ ( ឬ មានបង្គន់តែមិនដំណើរការល្អ ) ។
- សាលាមួយចំនួន មានបណ្ណាល័យ ប៉ុន្តែខ្វះបណ្ណារក្ស ជាហេតុមិនអាចដំណើរការបានល្អប្រសើរ ( ពិបាកក្នុងការធ្វើប្រាក់ឧបត្ថម្ភ ២ ថ្នាក់ ២ ពេល ) ។
- ខ្វះថវិកាសម្រាប់ក្រុមបណ្តាញចុះរកកុមារក្រៅសាលា និងកុមារពិការ និងធ្វើយុទ្ធ. នាការប្រមូលកុមារឱ្យចូលរៀន និងផ្សព្វផ្សាយឯកសារសំខាន់ៗ ។

**៣-អនុវិស័យមធ្យមសិក្សា និងអប់រំបច្ចេកទេស**

**ក.ការទទួលសេវាអប់រំ**

ក្រោយពីបញ្ចប់ភូមិសិក្សាសិស្សមួយចំនួនមិនបានទទួលនូវសេវាអប់រំកម្រិតមូលដ្ឋានដោយសារៈ

- មិនមានមធ្យោបាយធ្វើដំណើរ (សាលារៀននៅឆ្ងាយពីផ្ទះ)
- សិស្សមួយចំនួនទៅរកការងារធ្វើនៅតាមរោងចក្រ ទៅរកការងារធ្វើនៅក្នុង និងក្រៅប្រទេស ។
- ជួយធ្វើការងារបង្កបង្កើនផលឪពុកម្តាយ
- ជីវភាពខ្វះខាតគ្មានលទ្ធភាពបន្តការសិក្សា
- គ្រួសារចំណាកស្រុកទៅស៊ីឈ្នួលឲ្យគេ
- គ្រួសារមានអំពើហឹង្សា
- អាណាព្យាបាលមួយចំនួនពុំយកចិត្តទុកដាក់តាមដានការសិក្សារបស់កូន
- សិស្សមួយចំនួនមិនមានសមត្ថភាពបន្តការសិក្សា

**ខ. គុណភាពនិងប្រសិទ្ធភាពនៃការបង្រៀន និងរៀនៈ**

- កង្វះគ្រូនៅគ្រឹះស្ថានមធ្យមសិក្សាជាច្រើននៅតាមជនបទ

- គ្រូនៅតាមទីប្រជុំជនមានចំនួនលើស ការបំពេញភារកិច្ចមិនទាន់បានល្អ និងគាបសង្កត់សិស្សទៅតាមវិធីផ្សេងៗដើម្បីផលប្រយោជន៍របស់ខ្លួនដោយខ្វះមនសិការវិជ្ជាជីវៈ ។

- កង្វះបន្ទប់សិក្សានៅតាមសាលាអនុវិទ្យាល័យជនបទ

- ការបែងចែកសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំមិនទាន់បានទៅតាមតម្រូវការសាលា និង មិនបានបើកវគ្គតម្រង់ទិសលើខ្លឹមសារមេរៀនថ្មី ។

- ការងារគ្រប់គ្រងរបស់នាយកសាលាមួយចំនួនតូចនៅមានកម្រិតជាពិសេសនាយកដែលទើបតែងតាំងថ្មី

- ការទប់ស្កាត់បាតុភាពអវិជ្ជមានមួយចំនួនមិនបានទាន់ពេលវេលា

- ការប្រើប្រាស់ថវិកាPB និងថវិកាSIG មិនទាន់បានចំមុខសញ្ញា

- សាលាមួយចំនួនដែលបានបង្កើតហើយចំនួន ៣ឆ្នាំ មិនទាន់មានបន្ទប់សិក្សាគ្រប់គ្រាន់ ។

- ខ្វះគ្រូតាមមុខវិជ្ជាឯកទេស នៅមធ្យមសិក្សាទុតិយភូមិ និងបឋមភូមិ

**៤-អនុវិស័យអប់រំក្រៅប្រព័ន្ធ**

- ការប្រមូលសិស្សចូលរៀន

- គ្រូកិច្ចសន្យាអក្ខរកម្មវិជ្ជាជីវៈភាគច្រើនជាប្រជាពលរដ្ឋសហគមន៍

- ការរក្សាស្ថេរភាពសិស្ស

- អគារសិក្សា និងសម្ភារម.ស.សចាស់ទ្រុឌទ្រោម ខូចខាតជាច្រើន

- អនុម័តកញ្ចប់ថវិកាទាបជាងផែនការ

**៥-អនុវិស័យការអភិវឌ្ឍយុវជន**

- មន្ត្រីទទួលបន្ទុកការងារយុវជន-កុមារ តាមបណ្តាក្រុង / ស្រុកនិងបណ្តាសាលារៀនមួយ ចំនួន មិនទាន់យកអស់ស្មារតីបំពេញភារកិច្ចរបស់ខ្លួនឲ្យបានល្អនៅឡើយ ។

- នៅក្នុងថវិកាPB របស់សាលារៀននីមួយៗគ្មានខ្ទង់សម្រាប់ចំណាយទៅលើការងារ ក្រុមប្រឹក្សា យុវជន -កុមារនៅឡើយ ។

- ពុំមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តទៅលើកម្មវិធីរបស់យុវជន-កុមារដូចជា៖ ការរៀបចំប្រារព្ធពិធី ទិវាកុមារ អន្តរជាតិ១មិថុនា ទិវាប្រយុទ្ធប្រឆាំងនិងពលកម្មកុមារ ១២

មិថុនា ទិវាយុវជន ១២សីហា និងការ រៀបចំបូក សរុបលទ្ធផលចលនា៣ល្អ របស់យុវជន-កុមារ ថ្នាក់ខេត្ត ក្រុង/ស្រុក និង សាលារៀននៅ ឡើយ ។

- ពុំទាន់មានកញ្ចប់ថវិកាសម្រាប់បម្រើសកម្មភាពការងារកាយរឹទ្ធិ

- ម្រោងកម្មវិធីសកម្មភាព PB របស់យុវជនសម្រាប់ធ្វើការងារអប់រំផ្សព្វផ្សាយ អំពីសុខភាព ទូទៅ ដល់យុវជនក្នុង និងក្រៅសាលារៀនមានកម្រិតតិចបំផុត ។

- គម្រោងកម្មវិធីសកម្មភាព PB សម្រាប់អនុវត្តទៅលើការងារក្រុមប្រឹក្សាយុវជន-កុមារ ថ្នាក់ ក្រុង / ស្រុក និងថ្នាក់ខេត្ត ពុំឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ។

- ពុំមានខ្ទង់ថវិកាសម្រាប់អនុវត្តកម្មវិធីផ្លាស់ប្តូរបទពិសោធន៍រវាងយុវជន-កុមារថ្នាក់ខេត្ត ដូចជា៖ កម្មវិធីបោះជុំរំ និង កម្មវិធីទស្សនៈកិច្ចសិក្សារបស់យុវជន-កុមារ ។

**ការងារមជ្ឈមណ្ឌលយុវជន**

- មិនទាន់មានមជ្ឈមណ្ឌយុវជនសម្រាប់យុវជន-កុមារធ្វើសកម្មភាពរៀនសូត្រ និងបណ្តុះ បណ្តាល នូវជំនាញខ្លីៗដែលជាបំណិនជីវិតសម្រាប់យុវជន និងលេងកំសាន្តនៅពេលសម្រាកពីការ សិក្សានៅសាលា រៀនចំណោះទូទៅ ។

- ថវិកាសម្រាប់បំរើការការងារបណ្តុះបណ្តាល យុវជនស្ម័គ្រចិត្ត-ជំនាញខ្លីៗ-ចាក់ដីទីតាំង មជ្ឈមណ្ឌល និងចុះពិនិត្យតាមដាន ពុំឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ។

**៦-អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា**

-ការអនុវត្តសកម្មភាពនិងកាប្រើប្រាស់ម៉ោងអប់រំកាយ និងកីឡា នៅតាមសាលារៀនពុំទាន់បានអនុវត្តពេញលេញនៅឡើយ ។

-គ្រូអប់រំកាយ និងកីឡាមួយចំនួនមិនបានធ្វើផែនការហ្វឹកហាត់ប្រចាំឆ្នាំ និងកិច្ចតែងការបង្រៀនប្រចាំថ្ងៃ ។

-គ្រឹះស្ថានមួយចំនួនពុំទាន់មានទីលានកីឡាសម្រាប់អនុវត្តសកម្មភាពអប់រំកាយ និងកីឡា ។

-សម្ភារៈហ្វឹកហាត់ ទីលានហ្វឹកហាត់ មិនទាន់គ្រប់គ្រាន់ឆ្លើយតបតាមនិយាមបច្ចេកទេស ។

-ធនធានមនុស្សមិនទាន់ឆ្លើយតបតាមតម្រូវការ

-សាលារៀនមួយចំនួនពុំទាន់មានទីលាន និងសម្ភារៈគ្រប់គ្រាន់សម្រាប់ហ្វឹកហាត់

-គ្រូបង្រៀននៅតាមសាលាបឋមសិក្សាដែលបានបណ្តុះបណ្តាល អប់រំកាយបែបថ្មី មិនទាន់គ្រប់គ្រាន់តាមតម្រូវការ ។

-សកម្មភាពហាត់ប្រាណរបស់មហាជនមិនទាន់មានស្តង់ដា

-យកម៉ោងអប់រំកាយនិងកីឡាទៅបង្រៀនមុខវិជ្ជាផ្សេងៗ

V- **អនុសាសន៍/ទិសដៅ**

**ក.១-ការងារផែនការ**

- ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៨ ត្រូវបានរៀបចំ និងមានពិន្ទុយ៉ាងតិច ៨៥ ឡើង
- សៀវភៅស្ថិតិ និងសូចនាករអប់រំឆ្នាំសិក្សា ២០១៧-២០១៨ ត្រូវបានរៀបចំ
- របាយការណ៍ស្ថានភាពអប់រំយុវជន និងកីឡា តាមដំណាក់កាលត្រូវបានរៀបចំទាន់ពេល ។
- របាយការណ៍សន្និបាតអប់រំ យុវជន និងកីឡាត្រូវបានរៀបចំ
- ទិន្នន័យស្ថិតិសាលារៀនសាធារណៈ ឯកជន និងមត្តេយ្យសិក្សាសហគមន៍ ១០០% ត្រូវបានប្រមូល ផ្ទៀងផ្ទាត់ និងបូកសរុបបានទាន់ពេល ។
- របាយការណ៍សមិទ្ធកម្មរបស់មន្ទីរត្រូវបានរៀបចំទាន់ពេល

**ក.២-ការងារអធិការកិច្ច**

- ធ្វើអធិការកិច្ចតាមកាលកំណត់សាលាបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅសាធារណៈ និងឯកជនជាមធ្យមចំនួន ៨៥ សាលា ។
- ផ្តល់របាយការណ៍ជូនផ្នែកពាក់ព័ន្ធឱ្យបានពិតប្រាកដ ទៀងទាត់ គ្រប់គ្រាន់ និងទាន់ពេល ។
- សហការល្អ និងតាមលទ្ធភាពជាមួយការិយាល័យជំនាញពាក់ព័ន្ធ និងនាយកដ្ឋានធានាគុណភាពអប់រំ ។

**ក.៣-ការងាររដ្ឋបាល**

- បន្តពង្រឹងសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាលដល់មន្ត្រី
- បន្តការងារគ្រប់គ្រងឯកសារតាមលក្ខណៈបច្ចេកទេសបណ្ណសារ
- បន្តរៀបចំស្នើគ្រឿងឥស្សរិយយស ទង់ជ័យលាភី ប័ណ្ណសរសើរ ជូនបុគ្គលិក និង

អង្គភាព ។

- ចុះពង្រឹងការងារគ្រប់គ្រងរដ្ឋបាល និងបណ្ណសារដល់ថ្នាក់ក្រុង/ស្រុក និង សាលារៀន ។

- ត្រៀមរៀបចំទុកដាក់លិខិតបទដ្ឋាន និងឯកសារផ្សេងៗរបស់អង្គភាពឱ្យមានលក្ខណៈបច្ចេកទេសបណ្ណសារ ។

**ក-៤-ការងារគណនេយ្យសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ**

- មន្ត្រីជំនាញយកចិត្តទុកដាក់អំពីការការបំពេញឯកសារទូទាត់

- រៀបចំឯកសារទូទាត់ឱ្យបានទាន់ពេលវេលា

**ក.៥-ការងារបុគ្គលិក និងនីតិកម្ម**

-ពង្រឹងការគ្រប់គ្រង ដឹកនាំ និង ប្រើប្រាស់បុគ្គលិកឲ្យមានប្រសិទ្ធភាពតាមរយៈការពង្រឹងវិន័យ ការងារ ដោយតាមដានត្រួតពិនិត្យ សម្របសម្រួល និង ចុះវត្តមានជាប្រចាំ ។

-តាមដានការប្រើប្រាស់ក្របខ័ណ្ឌតាមអង្គភាព និងសាលារៀនក្នុងខេត្ត

-ស្នើតែងតាំងឋានៈ/នាទីមន្ត្រីគ្រប់គ្រងជំនួសអ្នកចូលនិវត្តន៍ដើម្បីបន្តនិរន្តរភាពដឹក.នាំ-គ្រប់គ្រង ។

-បញ្ចូលទិន្នន័យព័ត៌មានបុគ្គលិកអប់រំចេញថ្មី និង ផ្លាស់ចូលពីខេត្តក្រៅ កែតម្រូវពិនិត្យផ្ទៀង ផ្ទាត់ ធ្វើបច្ចុប្បន្នភាពព័ត៌មានទិន្នន័យបុគ្គលិកអប់រំ ក្នុងកុំព្យូទ័រជាប្រចាំ ។

-ពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិវិស័យអប់រំដល់គ្រប់អង្គភាពសាលារៀន ។

**ក.៦-ការងារបណ្តុះបណ្តាល និងវក្រឹតការ**

- បន្តការជ្រើសរើស និង បណ្តុះបណ្តាល គ្រូបឋមសិក្សា និងមត្តេយ្យសិក្សាជំនាន់ក្រោយៗ ។

- លើកកម្ពស់សមត្ថភាពគ្រប់គ្រងជូននាយក នាយិកា នាយករង នាយិការងសាលាគ្រប់ភូមិសិក្សា ។

- ជំរុញការអនុវត្តស្តង់ដារគ្រូបង្រៀន

**ការងារគណៈកម្មការសុខភាពសិក្សា**

-ត្រៀមអនុវត្តកម្មវិធីសកម្មភាព PB និង បន្តចុះត្រួតពិនិត្យតាមដានការអនុវត្តកម្មវិធីសុខភាពសិក្សា នៅតាមបណ្តុគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាក្នុងក្រុង/ស្រុកទូទាំង

ខេត្តកំពត ក្នុងឆ្នាំសិក្សា ថ្មី ។

-ជំរុញនិងអនុវត្តឱ្យបានល្អប្រសើរឡើងលើវិស័យការងារ សុខភាពសិក្សា នៅតាមបណ្តុំសាលារៀន ទាំងអស់នៅទូទាំងខេត្តកំពត ។

-ត្រៀមបើកវគ្គបំប៉នស្តីពីសុខភាពអនាម័យអាហារូបត្ថម្ភ ការប្រើប្រាស់សម្ភារនិងវិធីសាស្ត្រ សង្គ្រោះបឋម ដល់សាលាដែលពុំទាន់បានទទួលការបំប៉ននៅតាមបណ្តុំក្រុង/ស្រុកមួយចំនួន ។

-ត្រៀមបើកកិច្ចប្រជុំប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា ។

-សហការជាមួយអង្គការ RHAC បំប៉នគ្រូ អំពីកម្មវិធីអប់រំបំណិនជីវិតស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទថ្នាក់ខេត្ត-ស្រុក និងសាលារៀន ។

-សហការជាមួយអង្គការ RHAC ចុះពិនិត្យតាមដាន ការបង្រៀនអំពីកម្មវិធីអប់រំបំណិនជីវិត ស្តីពី សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ នៅតាមសាលារៀនក្នុងទូទាំងខេត្ត

- សហការជាមួយអង្គការ RHAC រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំត្រីមាស

-សហការជាមួយអង្គការ COCD អប់រំផ្សព្វផ្សាយកម្មវិធីទឹកស្អាត និងអនាម័យតាមសាលា បឋមសិក្សា ក្នុងស្រុកដងទង់ និងស្រុកឈូក ។

**២.១ អនុវិស័យអប់រំកុមារតូច**

- បង្កើនអត្រាចូលរៀនរបស់កុមារអាយុ ៤ឆ្នាំ និង ៥ឆ្នាំឱ្យឆ្លើយតបនឹងចំណុចដៅ

- បង្កើនកិច្ចសហការជាមួយឃុំ/សង្កាត់ក្នុងការគ្រោងថវិកាគាំទ្រមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំមាតាបិតាបញ្ចូលទៅក្នុងផែនការវិនិយោគប្រចាំឆ្នាំ ។

- ពង្រឹងការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល

- ពន្លឿនការប្រមូល និងបញ្ជូនទិន្នន័យឱ្យបានទាន់ពេលវេលា

**២.២ អនុវិស័យបឋមសិក្សា**

- បន្តពង្រឹងការងាររដ្ឋបាលការិយាល័យឱ្យកាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា ។

- បន្តពង្រឹង និងគាំទ្រការអនុវត្តការងាររបស់ក្រុម DTMTs និងកម្រងសាលារៀនក្នុងការចុះជួយលើការងារគ្រប់គ្រង ដឹកនាំ និងការងារបង្រៀន និងរៀន ។
- បន្តចុះពង្រឹងការប្រជុំបច្ចេកទេស ការងារដឹកនាំ គ្រប់គ្រង និងការងារបង្រៀន និងរៀន ។
- បន្តផ្សព្វផ្សាយគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រ សេចក្តីណែនាំផ្សេងៗទៅដល់ការិយាល័យអប់រំក្រុង/ស្រុក និងសាលារៀនបឋមសិក្សា ។
- សហការជាមួយក្រសួង និងអង្គការយូនីសែហ្វ លើការងារពិនិត្យតាមដាន និងពង្រឹងការអនុវត្តកម្មវិធីវិន័យវិជ្ជមាន តាមសាលារៀន និងស្រុកគោលដៅក្នុងខេត្ត ។
- សហការជាមួយនាយកដ្ឋានបឋមសិក្សា ក្នុងការងារពង្រឹងការអនុវត្តកម្មវិធីថ្នាក់ពន្លឿនការសិក្សា និងកម្មវិធីសុខភាពសិក្សានៅបឋមសិក្សា ។

**២.៣-អនុវិស័យមធ្យមសិក្សា និងអប់រំបច្ចេកទេស**

- កាត់បន្ថយអត្រាត្រួតថ្នាក់នៅមធ្យមសិក្សាបឋមភូមិ
- បង្កើនអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- បង្កើនអត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមី
- ជំរុញឱ្យសាលារៀនអនុវត្តកម្មវិធីសាលាកុមារមេត្រីកាន់តែមានប្រសិទ្ធភាព

**២.៤-អនុវិស័យអប់រំក្រៅប្រព័ន្ធ**

- បង្កើនអត្រាអក្ខរកម្មវិជ្ជជីវៈ ( អាយុ១៥-៤៥ឆ្នាំ )
- ពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ និងបណ្ណាល័យដែលមានស្រាប់
- ពង្រឹង និងពង្រីកសកម្មភាពថ្នាក់កម្មវិធីសមមូលបឋមសិក្សា និងជំរុញកម្មវិធីមធ្យមសិក្សាបឋមភូមិឱ្យដំណើរការ ។
- ជំរុញបញ្ជូនសិស្សបោះបង់ការសិក្សាឱ្យចូលរៀនតាមសាលារៀនក្នុងប្រព័ន្ធ។
- ស្រង់ស្ថិតិអនក្ខរជន និងសិស្សបោះបង់ការសិក្សាថ្នាក់ទី៣ - ៦
- ធ្វើសំណើសុំសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍មានលក្ខណៈស្តង់ដាចំនួន១
- ជំរុញគ្រូជំនាញទាំងអស់ ចងក្រងខ្លឹមសារមេរៀនវិជ្ជជីវៈសម្រាប់បង្រៀន
- បណ្តុះបណ្តាល/បំប៉នគ្រូកិច្ចសន្យាដែលទើបជ្រើសរើសថ្មី និងជំរុញគ្រូជំនាញទាំងចងក្រងខ្លឹមសារមេរៀនវិជ្ជជីវៈសម្រាប់បង្រៀន ។
- ត្រៀមផ្ទេរមុខងារអប់រំក្រៅប្រព័ន្ធជូនរដ្ឋបាលក្រុង/ស្រុក

**២.៥-អនុវិស័យការអភិវឌ្ឍយុវជន**

- អនុវត្តកម្មវិធីសកម្មភាព PB បន្តពង្រឹង និង ពង្រីករចនាសម្ព័ន្ធក្រុមប្រឹក្សា យុវជន-កុមារ និង គ្រូត ពិនិត្យតាមដានវាយតម្លៃការងារចលនាប្រលងប្រណាំង ពល្អ របស់ក្រុមប្រឹក្សាយុវជន-កុមារ ដើម្បីធ្វើ ការប្រ ជុំបូក សរុបចលនាប្រលងប្រណាំងពល្អរបស់យុវជនកុមារ នៅថ្នាក់ខេត្ត និងថ្នាក់ ជាតិនៅឆ្នាំសិក្សា ថ្មី ។

- អនុវត្តកម្មវិធីសកម្មភាព PB របស់យុវជនទៅលើកម្មវិធីអប់រំផ្សព្វផ្សាយជំងឺអេដស៍ដល់ យុវជនក្រៅ សាលា និងការបំប៉នការងារអភិវឌ្ឍក្រុមប្រឹក្សាយុវជន-កុមារ ។

- សហការល្អជាមួយបណ្តាអង្គការជាតិ និង អន្តរជាតិ រៀបចំប្រារព្ធទិវាកុមារអន្តរជាតិ ១ មិថុនា ទិវា ប្រយុទ្ធប្រឆាំង និងពលកម្មកុមារ១២មិថុនា និងទិវាយុវជនអន្តរជាតិ១២ សីហា ។

- បន្តការបញ្ជូនប្រតិភូយុវជន-កុមារ ឱ្យទៅចូលរួមដំណើរទស្សនកិច្ចសិក្សានិងបោះជុំរំថ្នាក់ ខេត្ត ថ្នាក់ជាតិ និង អន្តរជាតិ ។

**ការងារមជ្ឈមណ្ឌលយុវជន**

- បន្តរៀបចំហ្វឹកហាត់ការងារអប់រំកាយអ៊ុនដោកីរបស់ជប៉ុនក្នុងក្រុមប្រឹក្សាកុមារនៅតាមបណ្តាគ្រឹះ ស្ថាន មធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិក្នុងខេត្ត ។

- បន្តចាក់ដីបំពេញទីធ្លាមជ្ឈមណ្ឌលយុវជនខេត្តកំពតបន្តទៀត

**ការងារកាយរឹទ្ធិ**

- បន្តផ្សព្វផ្សាយពង្រឹង និងពង្រីកសកម្មភាពការងារកាយរឹទ្ធិឱ្យមានការរីកចម្រើនបន្ថែមទៀត ។

**២.៦-អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា**

-ចុះពិនិត្យតាមដានការបង្ហាត់បង្រៀនគ្រូអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា ។

-ត្រៀមរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកទូទាំងខេត្តប្រចាំ

ឆ្នាំសិក្សា២០១៧-២០១៨ មានរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី ១៥ ដល់ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៨ ខេត្តកំពត ។

-ត្រៀមរៀបចំការប្រកួតកីឡាសិស្សមធ្យមសិក្សាជ្រើសរើសជើងឯកទូទាំងខេត្ត ប្រចាំឆ្នាំសិក្សា២០១៧-២០១៨ មានរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃទី២៨ ខែ កុម្ភៈ ដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ ខេត្តកំពត ។

-ត្រៀមរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកទូទាំងប្រទេស ប្រចាំឆ្នាំសិក្សា២០១៧-២០១៨ មានរយៈពេល ០៧ ថ្ងៃ ចាប់ពីថ្ងៃទី ២៨ ខែ មីនា ដល់ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៨ ខេត្តបាត់ដំបង ។

-ត្រៀមរៀបចំការប្រកួតកីឡាសិស្សមធ្យមសិក្សាជ្រើសរើសជើងឯកទូទាំងប្រទេស ប្រចាំឆ្នាំសិក្សា២០១៧-២០១៨ មានរយៈពេល ១០ ថ្ងៃ ចាប់ពីថ្ងៃទី ០៥ ដល់ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០១៨ ខេត្តកំពត ។

-ជំរុញការអនុវត្តកម្មវិធីអប់រំកាយនិងកីឡានៅតាមគ្រឹះស្ថានសិក្សាឱ្យបានពេញលេញទាំងបឋមសិក្សា និងមធ្យមសិក្សា ។

- ត្រៀមរៀបចំកីឡាជាតិ ( National Games ) លើកទី ២ ឆ្នាំ ២០១៨ ចាប់ពីថ្ងៃទី២៥ ខែ ឧសភា ដល់ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ខេត្តកែប ខេត្តកំពត និងខេត្តកំពង់ធំ ។

VI- **សេចក្តីសន្និដ្ឋាន**

លទ្ធផលដែលមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពតសម្រេចបាន អាស្រ័យដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា និង សហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី ដៃគូអភិវឌ្ឍ សប្បុរសជននានា ព្រមទាំងមានការខិតខំប្រឹងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ មាតាបិតាសិស្ស សហគមន៍ និង មានការចូលរួមពីសំណាក់សិស្សានុសិស្សទាំងអស់ ធ្វើឱ្យយើងទទួលបានលទ្ធផលល្អទាំងផ្នែកបរិមាណ និង គុណភាព ។

**ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត**

**តាក ហាប់**